សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ តុលា ឆ្នាំ ២០១៨

# លីអាហូណា



## អែលឌើរ ហ្គុង និងអែលឌើរ សូរ៉េស ៖ « សាក្សីនៃព្រះនាមព្រះគ្រីស្ទនៅក្នុងពិភពលោកទាំងអស់ » ទំព័រ ១២, ១៨

ចំណុច ៨ យ៉ាងដើម្បីយល់អំពីប៊ីស្សពរបស់អ្នក ទំព័រ ២៤

យ៉ូសែប ស្ម៊ីធ ៖ « ត្រូវបានបំផុសគំនិតឲ្យប្ដូរទីលំនៅដោយសារតែបុព្វហេតុនៃស៊ីយ៉ូន » ទំព័រ ២៨

រឿងថ្ងៃចុងក្រោយអំពីសេចក្ដីសញ្ញារបស់យើងជាមួយព្រះ ទំព័រ ៣៤



« ការដឹងថា **ព្រះមាតាបិតាសួគ៌របស់យើងបាន ដាក់ផែនការសម្រាប់សុភមង្គល និងភាពតម្កើង ឡើងដ៏សំខាន់បំផុតរបស់យើង** ផ្ដល់ឲ្យយើង នូវទស្សនវិស័យ ផ្ដល់អត្តសញ្ញាណដល់យើង ក្នុងនាមជាបុត្រាបុត្រីជាទីស្រឡាញ់នៃព្រះ មាតាបិតាសួគ៌ ហើយបង្កើនទំនុកចិត្ត របស់យើងលើព្រះអម្ចាស់ » ។

អែលឌើរ ឃ្វីនថិន អិល ឃុក

*ដកស្រង់មកពី « តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណា » ទំព័រ ៣៤ ។*

# លីអាហូណា ខែ តុលា ឆ្នាំ ២០១៨




## អត្ថបទពិសេសៗ


**៦ គោលការណ៍នៃការងារបម្រើ ៖ ការទទួលជំនួយដើម្បីជួយមនុស្សដទៃ**
*តើយើងដឹងពីពេលវេលា និងរបៀបដើម្បីឲ្យមនុស្សដទៃចូលរួមនៅក្នុងការងារបម្រើរបស់យើងដោយរបៀបណា ?*

**១២ អែលឌើរ ដេវីត ដ័បុលយូ ហ្គង ៖ ស្រឡាញ់ព្រះអម្ចាស់ ហើយទុកចិត្តទ្រង់**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន

**១៨ អែលឌើរ អូលីសេស សូរ៉េស ៖ បុរសដែលឥតមានឧបាយកល**
ដោយអែលឌើរ នែល អិល អាន់ឌើរសិន

**២៤ អ្វីដែលប៊ីស្សពគ្រប់រូបចង់ឲ្យសមាជិកវួដរបស់គាត់ដឹង**
ដោយ ម៉ៃឃែល មេយើរស៍
*ជួនកាលយើងភ្លេចថា ប៊ីស្សពគឺជាមនុស្សដូចជាយើងផងដែរ ដោយខំប្រឹងអស់ពីសមត្ថភាពរបស់ពួកលោកដើម្បីបម្រើឲ្យបានល្អនៅក្នុងការហៅបម្រើរបស់ពួកលោក ។*

**២៨ *ពួកបរិសុទ្ធ* ៖ រឿងអំពីសាសនាចក្រ — ជំពូក ៨ ៖ ការកើតឡើងនៃសាសនាចក្ររបស់ព្រះគ្រីស្ទ**
*អំឡុងពេលព្រះគម្ពីរមរមនកំពុងត្រូវបានបោះពុម្ព មនុស្សមួយចំនួនត្រូវបានដឹកនាំឲ្យស្គាល់ព្រះវិហារពិត ។ បន្ទាប់ពីការបោះពុម្ព យ៉ូសែបរៀបចំសាសនាចក្រ ។*

**៣៤ តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណា**
ដោយអែលឌើរ យ៉ឺនធិន អិល យុក
*សមាជិកនឹងត្រូវបានបំផុសគំនិត នៅពេលពួកគេអានអំពីពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់នៅក្នុងភាគថ្មីជាច្រើនស្តីពីប្រវត្តិសាសនាចក្រ ។*


## ការអានខ្លីៗ


**៤ ការបង្ហាញអំពីសេចក្តីជំនឿ: ម៉ៃយើល អ៊ីសាក — ទីក្រុងប៊ីឌើរហ្គោស ប្រទេសប៉ូឡូញ**

**១០ អ្វីដែលយើងជឿ: កន្លែងដែលប្រាក់ដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់**

**៤០ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត: ការទ្រទ្រង់គាំទ្ររបស់យើង**
ដោយ ប្រធាន ដេមស៍ អ៊ី ហ្វោស្ត




**នៅលើក្របមុខ**
តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក ដោយ វ៉ៃតធើរ ផឺន

## យុវមជ្ឈិមវ័យ





**៤៤ ការជំរុញចិត្តរបស់យើងដើម្បីរស់នៅតាមដំណឹងល្អ**
ដោយ មីនឌី សេលូ
*ហេតុផលរបស់យើងដើម្បីរស់នៅដោយសុចរិតគឺពិតជាផ្អែកទៅលើរឿងមួយ ។*

**៤៨ ជំហានទីមួយឆ្ពោះទៅកាន់ការប្រែចិត្ត**
ដោយ អូរីឡាស ភីធើសិន
*ការទៅជួបប៊ីស្សពរបស់ខ្ញុំត្រូវការភាពក្លាហានយ៉ាងខ្លាំង ប៉ុន្តែវាបានធ្វើឲ្យមានការផ្លាស់ប្តូរទាំងស្រុង ។*


## យុវវ័យ


**៥០ ការរៀនសូត្រតាមរបៀបរបស់ព្រះអម្ចាស់**
ដោយអែលឌើរ ដាវីឌ អេ បែដណា
*នៅពេលយើងអនុញ្ញាតឲ្យព្រះវិញ្ញាណធ្វើជាគ្រូបង្រៀន នោះសមត្ថភាពរបស់យើងដើម្បីរៀននឹងកើនឡើង ។*

**៥៤ របៀប ៥ យ៉ាងដើម្បីរៀនអំពីសន្និសីទទូទៅ**
*សូមពិនិត្យមើលយោបល់ទាំងនេះដើម្បីទទួលបានកាន់តែច្រើនពីសារលិខិតសន្និសីទ ។*

**៥៦ បានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ**
*ពួកយុវវ័យទាំងនេះចែកចាយអ្វីដែលពួកគេបានរៀនពីសន្និសីទ ។*

**៥៨ ប័ណ្ណប្រកាស: ប្រសិនបើអ្នកស្តាប់**

**៥៩ សេចក្តីពិតស្តីពីសន្និសីទទូទៅ**

**៦០ សំណួរ និងចម្លើយ**
*តើខ្ញុំអាចយាងព្រះវិញ្ញាណបរិសុទ្ធមកក្នុងគេហដ្ឋានខ្ញុំ ពេលយើងកំពុងមានជម្លោះ ឬការទាស់ទែងគ្នាតាមរបៀបណា ?*

**៦២ មាគ៌ាដែលរៀបចំខ្លួនអ្នកសម្រាប់អនាគតរបស់អ្នក**
*បទពិសោធន៍ទាំងនេះមកពីយុវមជ្ឈិមវ័យបួននាក់ អាចបង្ហាញអ្នកនូវរបៀបស្វែងរកជោគជ័យនៅក្នុងពេលអនាគត ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្នកបញ្ចាំងពន្លឺរបស់អ្នកតាមរបៀបណា ?***




## កុមារ





**៦៦ ការចែកចាយសេចក្តីស្រឡាញ់នៃព្រះ**
ដោយ អាលី ប៊ី
*ពេលយើងបានប្តូរទីលំនៅ ខ្ញុំបានកត់សម្គាល់ឃើញថា ពុំសូវមានសមាជិកច្រើននៅក្នុងសាខាយើងឡើយ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តធ្វើអ្វីមួយអំពីរឿងនោះ ។*

**៦៧ ការអធិស្ឋាននៅឯជ្រលងភ្នំ**
ដោយ ខាសិន ខេ
*ខ្ញុំមានការភ័យខ្លាចដែលយើងពុំអាចរកផ្លូវត្រឡប់ទៅកាន់ឡានវិញ ។*

**៦៨ បញ្ចាំងពន្លឺរបស់អ្នកចេញទៅ: ការបញ្ចាំងពន្លឺនៅក្នុងសាធារណៈរដ្ឋឆែក**

**៧០ ពួកសាវកថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ**
ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន

**៧១ ទំព័ររបស់យើង**

**៧២ សេចក្តីជំនឿ សេចក្តីសង្ឃឹម និងព្រះគុណ — ផ្នែកទី ៣: សេចក្តីសង្ឃឹមនៅក្នុងប្រទេសហូឡង់**
ដោយ មេហ្គាន អាមនិក

**៧៤ ក្លឹបអានព្រះគម្ពីរមរមន**

**៧៥ វីរៈនារីព្រះគម្ពីរសញ្ញាចាស់: ព្រះនាងអេសធើរមានចិត្តក្លាហាន**

**៧៦ រឿងក្នុងព្រះគម្ពីរ: ព្រះនាងអេសធើរ**
ដោយ គីម វិប រៀង

**៧៩ ទំព័រផាត់ពណ៌: ខ្ញុំអាចជួយអ្នកដទៃឲ្យទទួលអារម្មណ៍ថា ពួកគេត្រូវបានគេស្រឡាញ់**

# មានច្រើនទៀតនៅលើអ៊ិនធើរណែត



សូមអាន និងផ្ញើអត្ថបទផ្ទាល់របស់អ្នកតាមគេហទំព័រ **liahona.lds.org**

សូមស្វែងរកសារលិខិតបំផុសគំនិត និងអាចចែកចាយបាន ( ជាភាសាអង់គ្លេស ព័រទុយហ្គាយ និង អេស្ប៉ាញ ) នៅគេហទំព័រ **facebook.com/liahona**





សូមផ្ញើមតិកែលម្អទៅកាន់ **liahona@ldschurch.org**

សូមជាវតាមគេហទំព័រ **store.lds.org** ឬទៅមជ្ឈមណ្ឌលចែកចាយ សួរថ្នាក់ដឹកនាំវួដ ឬទូរសព្ទ ១-៨០០-៥៣៧-៥៩៧១ ( សហរដ្ឋ និងប្រទេសកាណាដា )



រូបតំណាងមកពី GETTY IMAGES

## ប្រធានបទទាំងឡាយក្នុងច្បាប់នេះ

*លេខទាំងឡាយតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*


**ការងារ,** ៦២
**ការងារបម្រើ,** ៦, ២៤
**ការប្រែចិត្ត,** ៤៨
**ការរៀនសូត្រ,** ៥០
**ការអធិស្ឋាន,** ៤, ៤០, ៤១, ៦៧, ៦៨
**ការអភ័យទោស,** ៤៨, ៧២
**កិច្ចការផ្សព្វផ្សាយសាសនា,** ៤៣, ៦៦
**គំរូ,** ៦៨
**ដង្វាយមួយភាគក្នុងដប់,** ១០
**ថ្នាក់ដឹកនាំសាសនាចក្រ,** ១២, ១៨
**ទីបន្ទាល់,** ៥៦, ៦៨, ៧១
**ទុក្ខវេទនា,** ៤
**ប៊ីស្សព,** ២៤, ៤៨
**ប្រវត្តិសាស្ត្ររបស់សាសនាចក្រ,** ២៨, ៣៤
**ពួកព្យាការី,** ៤២, ៧១, ៨០
**ព្រះគម្ពីរមរមន,** ២៨, ៧៤
**ព្រះគម្ពីរសញ្ញាចាស់,** ៧៥, ៧៦
**ព្រះយេស៊ូវគ្រីស្ទ,** ៤៤, ៧០
**ព្រះវរបិតាសួគ៌,** ៣៤, ៤៣
**ព្រះវិញ្ញាណបរិសុទ្ធ,** ៥០, ៥៦, ៦០
**ព្រះវិហារបរិសុទ្ធ,** ៤២, ៧១
**ភាពក្លាហាន,** ៧៥, ៧៦
**ភាពខ្លួនទីពឹងខ្លួន,** ៤០, ៦២
**យ៉ូសែប ស្ម៊ីធ,** ២៨, ៣៤
**វិវរណៈ,** ៤១, ៥០
**សន្និសីទទូទៅ,** ៥៤, ៥៦, ៥៨, ៥៩
**សាមគ្គីភាព,** ២៤, ៤៣, ៦០
**សេចក្តីជំនឿ,** ៤, ៤០, ៤២, ៤៤
**សេចក្តីស្រឡាញ់,** ៦៦, ៧៩



**ខែ តុលា ឆ្នាំ ២០១៨ វ៉ុល 17 លេខ 5**
**លីអាហូណា 14754 258**
ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃ ចុងក្រោយ



**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី. អាវរិង
**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម. រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ. អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថដ គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវិនសុន, ឌេល ជី រេនឡាន់, ហ្គែរិត ដបុលយូ ហ្គង និង អូលីសេស សូរ៉េស
**និពន្ធនាយក ៖** ហ៊ូហ្គូ អ៊ី ម៉ាទីណេ
**ជំនួយការនិពន្ធនាយក ៖** រ៉េនដល ឃេ បិនណ្ណិត, ប៉ែកឃី ក្រាវិន
**អ្នកប្រឹក្សា ៖** ប្រែន ខេ អាស្តុន, ឡឺហ្វ្រង់ ឬ ឌឺធីស ជុញ្ញ័រ, អេដវ៉ូដ ដាប់, ស្សារ៉ុន អិល អើបែង, គ្រីស្ទីណា ប៊ី ហ្វ្រាំងកូ, ដូណាល អិល ហលស្រ្តម, ដូហ្គ្លាស ឌី ហូលមែស
**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រដាម ស៊ី អូស្តុន
**ជំនួយការ ការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខារ
**ជំនួយការបោះពុម្ព ៖** ហ្វ្រាន់ស៊ីស្កា អុលសុន
**និពន្ធ និងកែសម្រួលដោយ ៖** ម៉ារីសា ឌែននី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ឡារី ហ្វូលើរ, ហ្គារ៉េត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ចុន រ៉ាយអែន ជែនសិន, ឆាលឡុត្ត ឡាកាបាល់, មែឃល អរ ម៉ូរីស, អ៊ីរីក ប៊ី ម៉ាដុក សាលី ចនសុន អូដេឃីក, យ៉ូស្វេ ដេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាខែល វ៉ូដទ្បេ ម៉ារីសា វីឌីសុន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ស៊ី ឃីមបឺល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្វ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កុត អិម ម៉ូយ, អេមីលី ឈីកូ រេម៉ុងតុន, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហូស
**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វែន អាឌៀ, ខេទី ដានខាន, ថូម៉ាស ជី ក្រូនីន, ប្រែអិន ដបុលយូ ដឹជឹ, ជីន្នី ជេ និលសុន, រីក វីឆាតសុន
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស
**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ជី លេវីស
**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាកឃើរ



សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬតាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។



*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាម៉ៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ុអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណឺម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វ៊ីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ូឌូ នឹង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។



© 2018 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា ៖ លុះត្រាមានការបញ្ជាក់ បុគ្គលម្នាក់ៗអាចថតចម្លងឯកសារចេញពីលីអាហូណានេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ពុំមែនដើម្បីធ្វើអាជីវកម្ម ( រួមទាំងការហៅបម្រើក្នុងសាសនាចក្រ ) ។ សិទ្ធិនេះអាចត្រូវបានលុបចោលវិញគ្រប់ពេល ។ រូបភាពពុំអាចថតចម្លងបានឡើយ ប្រសិនបើឃើញមានការដាក់បម្រាមបង្ហាញនៅក្នុងជួរបន្ទាត់នៃការដកស្រង់នៃរូបភាពនោះ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិគួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., FL 13, Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។



**For Readers in the United States and Canada:**
October 2018 Vol. 17 No. 5. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.





*ម៉ៃយើលដែលកំពុងមានជំងឺខ្សោយតម្រង់នោមនិយាយថា « ជំងឺអាចធ្វើឲ្យរឿងល្អៗជាច្រើនកើតមានឡើង » ។ ដោយសារតែជំងឺរបស់គាត់បានធ្វើឲ្យគាត់មានអំណរគុណកាន់តែខ្លាំងឡើងទៅលើដំណឹងល្អ នោះគាត់និយាយថា « វាគឺជាការសាកល្បងដ៏ល្អមួយ » ។*

ឡេសលី នីលសុន ជាងថតរូប

# ម៉ៃយើល អ៊ីសាក

*ទីក្រុងប៊ីឌើរហ្គោស ប្រទេសប៉ូឡូញ*

នៅគ្រាដំបូងខ្ញុំមានការខឹងសម្បារ ។

ខ្ញុំបានអធិស្ឋាន « ហេតុអ្វីជារូបខ្ញុំ ? ឱព្រះអម្ចាស់ ទូលបង្គំបានបម្រើទ្រង់ » ។ មួយរយៈពេលក្រោយមក ទើបខ្ញុំបានយល់ ។ ខគម្ពីរចែងថា « អ្នកណាដែលមានសេចក្ដីជំនឿជឿដល់យើង ដើម្បីឲ្យបានជាស្បើយ ហើយដែលពុំបានកំណត់ឲ្យស្លាប់ នោះនឹងត្រូវបានជាស្បើយហើយ » ( គ. និង ស. ៤២:៤៨ ) ។

សមាជិកសាសនាចក្របន្តអធិស្ឋានសម្រាប់ខ្ញុំ ប៉ុន្តែសុខភាពរបស់ខ្ញុំប្រែកាន់តែដុនដាបទៅៗ ។ ពួកគេគិតថា ការអធិស្ឋានរបស់ពួកគេគ្មានការឆ្លើយតបឡើយ ប៉ុន្តែពួកគេបានទទួលចម្លើយ ដោយសារពួកគេក្លាយជាមនុស្សកាន់តែប្រសើរឡើង ហើយដោយសារខ្ញុំទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ដែលពួកគេបានបង្ហាញដល់ខ្ញុំ ។

ទោះបីជាខ្ញុំមានសុខភាពល្អក្ដី តើខ្ញុំនៅរស់បានរយៈពេលយូរប៉ុណ្ណាទៀតនៅក្នុងវ័យដូចខ្ញុំនេះ ? ប៉ុន្តែ ខ្ញុំនៅមានឱកាសជាច្រើននៅទន្ទឹងរង់ចាំខ្ញុំ ។

ខ្ញុំមានព្រះវិហារ ។ ខ្ញុំមានមធ្យោបាយមួយក្នុងការទាក់ទងទៅព្រះតាមរយៈការអធិស្ឋាន តាមរយៈការតមអាហារ តាមរយៈកិច្ចការទាំងអស់ដែលយើងធ្វើ ។ តើខ្ញុំត្រូវការអ្វីទៀត ?

ជួនកាលខ្ញុំនិយាយប្រាប់ខ្លួនខ្ញុំថា « ប្រហែលនោះជាមូលហេតុដែលខ្ញុំឈឺ — ប្រយោជន៍ឲ្យខ្ញុំអាចយល់នូវរឿងដ៏អស្ចារ្យដែលខ្ញុំកំពុងមាន យល់នូវបុព្វហេតុដ៏មហិមានៃកិច្ចការទាំងនេះ » ។

**ស្វែងរកបន្ថែមទៀត**

រៀនបន្ថែមទៀតអំពីការប្រឈមមុខនឹងឧបសគ្គក្នុងជីវិតជាមួយអំណាចនៃសេចក្ដីសង្ឃឹមមកពីប្រធាន រ័សុល អិម ណិលសុន នៅគេហទំព័រ **lds.org/go/10185** ។

ស្វែងរកការបង្ហាញអំពីសេចក្ដីជំនឿបន្ថែមទៀតនៅគេហទំព័រ **lds.org/go/18** ។

# គោលការណ៍នៃការងារបម្រើ

# ការទទួលជំនួយ ដើម្បីជួយមនុស្សដទៃ

*តើយើងអាចឲ្យមនុស្សដទៃចូលរួមនឹងយើង នៅពេលយើងត្រូវការជំនួយក្នុងកិច្ចខិតខំរបស់យើងដើម្បីផ្ដល់ការងារបម្រើយ៉ាងដូចម្ដេច ? ចូលរួមនៅក្នុងការសម្ភាសអំពីការងារបម្រើ និងការប្រជុំក្រុមប្រឹក្សានៅថ្ងៃអាទិត្យសប្ដាហ៍ទីមួយ ។*

នៅពេលជំងឺក្រិនច្រើនកន្លែងបានធ្វើឲ្យខាធីនៅជាប់គាំងតែលើរទេះរុញ នោះគាត់បានឃើញថា គាត់ត្រូវការជំនួយរៀងរាល់យប់ដើម្បីក្រោកចេញពីរទេះរុញទៅកាន់គ្រែដេករបស់គាត់ ។ កិច្ចការនេះវាហួសពីសមត្ថភាពដែលសមាជិកម្នាក់អាចធ្វើបាន ។ ដូច្នេះ កូរ៉ុមអែលឌើរបានប្រឹក្សាអំពីស្ថានភាពរបស់គាត់ ហើយសម្រេចចិត្តធ្វើកាលវិភាគមួយដើម្បីជួយគាត់រៀងរាល់ល្ងាច ។[១]

នៅពេលយើងដឹងអំពីតម្រូវការ និងកម្លាំងនៃអស់អ្នកដែលយើងបម្រើ នោះយើងអាចឃើញថា យើងត្រូវការជំនួយដើម្បីជួយបំពេញតម្រូវការរបស់ពួកគេ ។ ការសម្ភាសអំពីការងារបម្រើ និងការប្រជុំក្រុមប្រឹក្សានៅថ្ងៃអាទិត្យសប្ដាហ៍ទីមួយ គឺជាឱកាសពីរដើម្បីពិភាក្សាអំពីរបៀបឲ្យមនុស្សដទៃចូលរួមដោយសមរម្យ ។

### ការសម្ភាសអំពីការងារបម្រើ

ការសម្ភាសក្នុងរយៈពេលត្រីមាសទាំងនេះ រវាងបងប្អូនស្រីដែលផ្ដល់ការងារបម្រើ និងគណៈប្រធានសមាគមសង្គ្រោះ ឬបងប្អូនប្រុសដែលផ្ដល់ការងារបម្រើ និងគណៈប្រធានកូរ៉ុមអែលឌើរគឺជារបាយការណ៍ *ផ្លូវការ* តែមួយគត់ ដែលយើងធ្វើឡើងទាក់ទងនឹងអស់អ្នកដែលយើងផ្ដល់ការងារបម្រើ ។ ការសម្ភាសយ៉ាងហោចណាស់រៀងរាល់ត្រីមាសគឺជាឱកាសមួយដើម្បី ( ១ ) ប្រឹក្សាអំពីភាពរឹងមាំ សេចក្ដីត្រូវការ និងឧបសគ្គនានារបស់គ្រួសារ និងបុគ្គលទាំងឡាយដែលត្រូវបានចាត់តាំង ( ២ ) កំណត់ថា តើសេចក្ដីត្រូវការណាខ្លះ ដែលកូរ៉ុម និងសមាគមសង្គ្រោះ ឬក្រុមប្រឹក្សាវួដអាចជួយបាន និង ( ៣ ) រៀនពីថ្នាក់ដឹកនាំ និងដើម្បីទទួលការលើកទឹកចិត្តក្នុងកិច្ចខិតខំធ្វើការងារបម្រើ ។

ប្រធានកូរ៉ុមអែលឌើរ និងប្រធានសមាគមសង្គ្រោះទាក់ទងអំពីតម្រូវការសំខាន់ៗដោយផ្ទាល់ទៅកាន់ប៊ីស្សព ហើយនឹងទទួលការទូន្មាន ព្រមទាំងការណែនាំពីលោក ។

អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីការសម្ភាសការងារបម្រើនៅគេហទំព័រ ministering.lds.org ។

### ការធ្វើឲ្យការសម្ភាសអំពីការងារបម្រើកាន់តែមានអត្ថន័យ

នៅក្នុងការគាំទ្រដល់សេចក្ដីថ្លែងការណ៍របស់ប្រធានរ័សុល អិម ណិលសុន ដែលថា កម្មវិធីនៃការងារបម្រើជាកត្តាកំណត់ដែលជះឥទ្ធិពលដល់អនាគតនៃសាសនាចក្រនោះអែលឌើរ ហ្គែរី អ៊ី ស្ទីវ៉េនសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរ

ផ្ដល់អាហារដល់ពួកគេ ដោយ ចច កុកកូ សាន់តាន់ជេឡូ

អត្ថបទ « គោលការណ៍នៃការងារបម្រើ » មានគោលបំណងជួយយើងឲ្យមើលថែគ្នាទៅវិញទៅមក — ពុំមែនយកវាទៅចែកចាយជាសារលិខិតនៅពេលទៅសួរទុក្ខឡើយ ។ នៅពេលយើងស្គាល់អស់អ្នកដែលយើងបម្រើ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិតយើងឲ្យដឹងអំពីសារលិខិតអ្វីខ្លះដែលពួកគេអាចត្រូវការបន្ថែមពីលើការមើលថែ និងសេចក្ដីមេត្តាករុណារបស់យើង ។




## ព្រះយេស៊ូវបានធ្វើឲ្យមនុស្សដទៃចូលរួម

ព្រះយេស៊ូវបានប្រទានអាហារដល់ហ្វូងមនុស្ស ៥០០០ នាក់ជាមួយនឹងនំបុ័ងប្រាំដុំ និងត្រីតូចពីរកន្ទុយ ។ សូមអាន យ៉ូហាន ៦:៥–១៤ ដើម្បីរកមើលចំនួនដងដែលព្រះអង្គសង្គ្រោះបានធ្វើឲ្យមនុស្សដទៃចូលរួមនៅក្នុងទង្វើនៃការងារបម្រើ ។



នាក់បានបង្រៀនថា « ការបំពេញនូវទស្សនវិស័យរបស់លោក . . . អាចផ្អែកទៅលើរបៀបដែលបងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើនឹងត្រូវបានបង្រៀន ព្រមទាំងពាក់ព័ន្ធនឹងការសម្ភាសអំពីការងារបម្រើបានល្អប៉ុណ្ណា » ។[២]

គន្លឹះចំនួនបួនសម្រាប់បងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើ ៖

- ទៅសម្ភាសដោយស្វែងរកការទូន្មាន ។ ត្រៀមខ្លួនរួចជាស្រេចដើម្បីរៀន ។
- រៀបចំខ្លួនដើម្បីពិភាក្សាអំពីតម្រូវការដែលអ្នកអាចត្រូវការជួយការប្រជុំ ។
- ផ្ដោតទៅលើភាពខ្លាំង និងសមត្ថភាពរបស់បុគ្គលម្នាក់ៗ ពុំមែនគ្រាន់តែតម្រូវការនោះទេ ។
- ទាក់ទងទៅគណៈប្រធាននៅចន្លោះពេលការសម្ភាសក្នុងត្រីមាសទាំងឡាយដើម្បីប្រឹក្សាតាមការចាំបាច់ ។

គន្លឹះប្រាំចំណុចសម្រាប់អ្នកដឹកនាំ ៖

- ការសម្ភាសពុំចាំបាច់ប្រើពេលវេលាយូរឡើយ ប៉ុន្តែសូមដាក់កាលវិភាគឲ្យមានពេលគ្រប់គ្រាន់ជួបនៅកន្លែងមួយដែលអនុញ្ញាតឲ្យមានការសន្ទនាមួយដ៏មានអត្ថន័យ ។
- ឆ្លៀតឱកាសធ្វើការងារបម្រើដល់បងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើនោះ ។
- កុំសួរសំណួរដែលហាក់ដូចជាបង្ហាញថា អ្នកកំពុងរាប់ការទៅសួរសុខទុក្ខ ឬគូសចំណាំនៅលើបញ្ជីឈ្មោះដែលត្រូវទាក់ទង ( « តើអ្នកបានធ្វើការងារបម្រើរបស់អ្នកចប់សព្វគ្រប់ហើយឬ ? » ) នោះឡើយ ។ ចូរសួរសំណួរដែលពង្រឹងដល់ឥរិយាបថដែលមានបំណងប្រាថ្នា ( « តើអ្នកទទួលបានការបំផុសគំនិតអ្វីខ្លះ នៅពេលអ្នកបានអធិស្ឋានសម្រាប់ក្រុមគ្រួសារនោះ ? តើមានអ្វីខ្លះបានកើតឡើងនៅពេលអ្នកបានអនុវត្តតាមការបំផុសគំនិតទាំងនោះ ? » )
- ស្ដាប់ដោយចិត្តស្មោះសរ ហើយកត់ត្រា ។
- ប្រឹក្សាជាមួយគ្នា ។ ដៃគូនៃអ្នកផ្ដល់ការងារបម្រើមានសិទ្ធិទទួលវិវរណៈសម្រាប់អស់អ្នកដែលពួកគេត្រូវបានចាត់ឲ្យផ្ដល់ការងារបម្រើ ។[៣]

**សំណួរ និង ចម្លើយស្ដីពីការសម្ភាសអំពីការងារបម្រើ**

*តើការសម្ភាសអំពីការងារបម្រើគឺជាអ្វី ?*

វាគឺជាការពិភាក្សារវាងបងប្អូនប្រុសដែលផ្ដល់ការងារបម្រើ និងសមាជិកម្នាក់នៃគណៈប្រធានកូរ៉ុមអែលឌើរ ឬរវាងបងប្អូនស្រីដែលផ្ដល់ការងារបម្រើ និងសមាជិកម្នាក់នៃគណៈប្រធានសមាគមសង្គ្រោះ នៅក្នុងបរិយាកាសមួយដែលអនុញ្ញាតឲ្យពួកគេស្វែងរក និងទទួលការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ជាលទ្ធផលបងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើអាចត្រូវបានបំផុសគំនិតដើម្បីមើលថែស្រឡាញ់ បង្រៀន និងលួងលោមតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។

*តើការសម្ភាសប្រចាំត្រីមាសទាំងនេះចាំបាច់ត្រូវតែជួបមុខគ្នាផ្ទាល់ដែរឬទេ ?*

ជាធម្មតា ការសម្ភាសទាំងនោះត្រូវធ្វើឡើងដោយជួបមុខគ្នាផ្ទាល់ ប៉ុន្តែវាក៏អាចធ្វើការសម្ភាសតាមទូរសព្ទ ឬតាមអ៊ីនធើរណែត ប្រសិនបើការជួបផ្ទាល់ពុំអាចធ្វើទៅបាននោះ ។ ជាទូទៅ ដៃគូទាំងពីរនាក់នឹងចូលរួមនៅក្នុងការសម្ភាសនៅពេលសមរម្យ ។

*តើអ្វីទៅជាគោលបំណងនៃការសម្ភាសអំពីការងារបម្រើ ?*

ការសម្ភាសអំពីការងារបម្រើគឺជាឱកាសដើម្បីឲ្យបងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើ រំឭកឡើងវិញនូវស្ថានភាពបច្ចុប្បន្ន ដាក់ផែនការសម្រាប់អនាគត ហើយទទួលជំនួយដែលចាំបាច់ដល់បុគ្គលម្នាក់ៗ ឬក្រុមគ្រួសារដែលពួកគេផ្ដល់ការងារបម្រើ ។ វាជាឱកាសមួយដើម្បីពិភាក្សាអំពីធនធានអ្វីខ្លះដែលកូរ៉ុម និងសមាគមសង្គ្រោះអាចផ្ដល់ឲ្យ ។

*តើខ្ញុំអាចដោះស្រាយបញ្ហាដែលសម្ងាត់ ឬបញ្ហាដែលងាយនឹងប៉ះពាល់អារម្មណ៍យ៉ាងដូចម្ដេច ?*

បងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើចែកចាយព័ត៌មានសម្ងាត់តែជាមួយប្រធានកូរ៉ុមអែលឌើរ ឬប្រធានសមាគសង្គ្រោះប៉ុណ្ណោះ — ឬដោយផ្ទាល់ជាមួយប៊ីស្សព ។ ព័ត៌មានសម្ងាត់ ឬដែលងាយនឹងប៉ះពាល់អារម្មណ៍គួរតែពុំត្រូវបានចែកចាយនៅក្នុងការប្រជុំក្រុមប្រឹក្សានៅថ្ងៃអាទិត្យសប្ដាហ៍ទីមួយឡើយ ។

*អ្នកអាចមើលវីដេអូបំពាក់បំប៉នដែលបង្ហាញអំពីការសម្ភាសការងារបម្រើនៅគេហទំព័រ ministering.lds.org ។*

**ការប្រឹក្សាអំពីតម្រូវការរបស់មនុស្សដទៃគឺជាចំណុចសំខាន់នៃការសម្ភាសអំពីការងារបម្រើ ។ សូមមើលផងដែរអត្ថបទគោលការណ៍នៃការងារបម្រើ « ប្រឹក្សាអំពីតម្រូវការរបស់ពួកគេ » នៅក្នុងច្បាប់ចេញផ្សាយខែ កញ្ញា ឆ្នាំ ២០១៨ ។**



### ការប្រជុំក្រុមប្រឹក្សានៅថ្ងៃអាទិត្យសប្ដាហ៍ទីមួយ

ក្រៅពីការសម្ភាសអំពីការងារបម្រើ ការប្រជុំក្រុមប្រឹក្សានៅថ្ងៃអាទិត្យសប្ដាហ៍ទីមួយគឺជារបៀបមួយទៀតដើម្បីឲ្យមនុស្សដទៃចូលរួមនៅក្នុងការងារបម្រើ ។ នៅក្នុងការប្រជុំសមាគមសង្គ្រោះ និងអែលឌើរកូរ៉ុម នោះការបំផុសគំនិតអាចកើតឡើងដល់អស់អ្នកដែលចូលរួមតាមរយៈព្រះវិញ្ញាណ និងពីអ្នកដទៃនៅក្នុងក្រុមនោះ ។

គោលបំណងនៃការប្រជុំក្រុមប្រឹក្សាគឺដើម្បី ៖

- « ប្រឹក្សារួមគ្នាអំពីការទទួលខុសត្រូវ ឱកាស និងឧបសគ្គនានាក្នុងមូលដ្ឋាន
- រៀនពីការយល់ដឹង និងបទពិសោធន៍របស់គ្នាទៅវិញទៅមក ព្រមទាំង
- ដាក់គោលដៅដើម្បីអនុវត្តតាមការបំផុសគំនិតដែលបានទទួលមកពីព្រះវិញ្ញាណ » ។[៤]

ការប្រជុំក្រុមប្រឹក្សាគឺលើសពីការពិភាក្សាមួយទៅទៀត ៖ ការប្រជុំទាំងនេះនាំយើងឲ្យអនុវត្តជាបុគ្គលម្នាក់ៗ ឬអនុវត្តជាក្រុមនៅពេលត្រូវបានបំផុសគំនិតពីព្រះវិញ្ញាណ ។ សមាជិកអាចទទួលអារម្មណ៍នូវបំណងប្រាថ្នាដើម្បីសម្រេចបាននូវកិច្ចការរបស់ព្រះអម្ចាស់ដែលជាលទ្ធផលនៃការប្រជុំទាំងនេះ ។

### ការអញ្ជើញឲ្យអនុវត្ត

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ការអធិស្ឋានរបស់យើងថ្ងៃនេះ គឺសូមឲ្យបុរសស្ត្រីគ្រប់រូប — នឹងយុវជនយុវនារីរបស់យើង — នឹង [ មាន ] ការតាំងចិត្តកាន់តែខ្លាំងចំពោះការថែទាំដោយអស់ពីចិត្តចំពោះគ្នាទៅវិញទៅមក ដែលជំរុញទឹកចិត្តតែតាមរយៈសេចក្ដីស្រឡាញ់សុទ្ធសាធរបស់ព្រះគ្រីស្ទដើម្បីធ្វើដូច្នោះប៉ុណ្ណោះ » ។[៥] ■

កំណត់ចំណាំ

១. សូមមើល Mormon Messages វីដេអូ « Lift » គេហទំព័រ lds.org/media-library ។
២. ហ្គែរី អ៊ី ស្ទីវ៉ែនសុន នៅក្នុង ( វីដេអូ ) « Ministering Interviews » គេហទំព័រ ministering.lds.org ។
៣. រ៉ុសុល អិម ណិលសុន « ការងារបម្រើ » *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០០ ។
៤. *កម្មវិធីចូរមកតាមខ្ញុំ — សម្រាប់ការប្រជុំថ្នាក់បព្វជិតភាពមិលគីស្សាដែក និងថ្នាក់សមាគមសង្គ្រោះ* នៅក្នុង *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១៤០ ក៏មានផងដែរនៅលើគេហទំព័រ comefollowme.lds.org ។
៥. ជែហ្វ្រី អ័រ ហូឡិន « នៅជាមួយ និង ចម្រើនកម្លាំងពួកគេ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៣ ។

# កន្លែងដែលប្រាក់ដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់

*តើមានអ្វីកើតឡើងចំពោះប្រាក់ដង្វាយមួយភាគក្នុងដប់ដែលអ្នកបានថ្វាយនោះ ?*



*អ្នករកប្រាក់ ។*



*អ្នកបានបរិច្ចាគ ១០ ភាគរយនៃប្រាក់ចំណូលរបស់អ្នកសម្រាប់ដង្វាយមួយភាគក្នុងដប់ ( សូមមើល គ. និង ស. ១១៩ ) ។*



*អ្នកឲ្យដង្វាយមួយភាគក្នុងដប់ឲ្យទៅកាន់សមាជិកម្នាក់ក្នុងគណៈប៊ីស្សព ឬគណៈប្រធានសាខារបស់អ្នក ឬផ្ញើវាតាមអ៊ិនធើរណែតទៅកាន់ donations.lds.org ។*



*នៅឯទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងគណៈប៊ីស្សពជាអធិបតី គឺជាក្រុមប្រឹក្សារៀបចំដង្វាយមួយភាគក្នុងដប់ ( សូមមើល គ. និង ស. ១២០ ) ។ ដូចបានណែនាំដោយព្រះអម្ចាស់ ពួកលោកធ្វើការសម្រេចចិត្តដោយការបំផុសគំនិតស្ដីពីរបៀបដែលមូលនិធិដង្វាយមួយភាគក្នុងដប់ដ៏ពិសិដ្ឋទាំងនេះនឹងត្រូវបានប្រើប្រាស់ ។*

# ដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ដើម្បី ៖



*ការសាងសង់ និងការថែទាំព្រះវិហារបរិសុទ្ធ អគារព្រះវិហារ និងអគារដទៃទៀតដែលសាសនាចក្រមាន*



*ដំណើរការកម្មវិធីអប់រំសាសនាចក្រ*



*បោះពុម្ពព្រះគម្ពីរ និងឯកសារដទៃទៀត*



*ធ្វើការស្រាវជ្រាវពង្សប្រវត្តិ*



*ការផ្តល់ដល់កិច្ចខិតខំនៃសុខុមាលភាព និងសប្បុរសធម៌*



*ធ្វើកិច្ចការផ្សព្វផ្សាយសាសនា*



*ការផ្តល់ដល់សកម្មភាពនានានៃសាសនាចក្រសម្រាប់ការរាប់អាននៅក្នុងចំណោមសមាជិកវួដ និងសាខា*

### រៀនបន្ថែម

- អែលឌើរ ដេវីឌ អេ បែដណា « បង្អួចនៃស្ថានសួគ៌ » សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៣ ។
- ម៉ាឡាគី ៣:៧–១៨
- « ដង្វាយមួយភាគក្នុងដប់ » *ពិតចំពោះសេចក្ដីជំនឿ* ( ឆ្នាំ ២០០៤ ) ទំព័រ ៨៦–៨៨

រូបភាពដោយ ដេវីឌ ហ្គ្រីន



**ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

## អែលឌើរ ដេវីត ដ័បុលយូ ហ្គង ៖

# ស្រឡាញ់ព្រះអម្ចាស់ ហើយទុកចិត្តទ្រង់

សិស្សបញ្ចប់ការសិក្សាដែលទើបរៀបការថ្មីថ្មោងនៅសាកលវិទ្យាល័យអុកហ្វើតនៃប្រទេសអង់គ្លេស ដេវីត ដ័បុលយូ ហ្គង បានរៀនតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនថា នៅពេលយើងស្រឡាញ់ព្រះអម្ចាស់ ហើយទុកចិត្តទ្រង់ នោះទ្រង់នឹងជួយយើង ដឹកនាំយើង និងពង្រឹងយើង ។

ដេវីតគឺជានិសិត្សអាហារូបករណ៍រ៉ូដេសដែលខិតខំរៀនដើម្បីបញ្ចប់បរិញ្ញាបត្រចំនួនពីរ ដែលសញ្ញាបត្រមួយគឺជាថ្នាក់បណ្ឌិត ។ នៅពេលដំណាលគ្នានោះ លោកកំពុងបម្រើនៅក្នុងគណៈប៊ីស្សពវួដអុកហ្វើត ។ លោក និងស៊ូសានភរិយារបស់លោកបានចាំពីការទូន្មានដែលអែលឌើរ ដេវីឌ ប៊ី ហេត ( ១៩០៦–២០០៤ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានផ្ដល់ឲ្យ នៅពេលលោករៀបអាពាហ៍ពិពាហ៍ឲ្យពួកលោកនៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។ អែលឌើរហ្គងថ្លែងថា « លោកបានប្រាប់ពួកយើងថា ត្រូវមានការហៅបម្រើជានិច្ច ។ យើងបានដឹងថា ប្រសិនបើយើងទុកចិត្តលើព្រះ ហើយធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង នោះទ្រង់នឹងជួយយើង » ។

លោកថ្លែងថា ដេវីត និង ស៊ូសាន បានទទួល « ជំនួយ និងសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ពីព្រះ » ។ អំឡុងពេលបន្តបម្រើនៅក្នុងគណៈប៊ីស្សព ដេវីតបានបញ្ចប់តម្រូវការនៃឆ្នាំសិក្សាទាំងអស់សម្រាប់សញ្ញាបត្រថ្នាក់បណ្ឌិតលើកលែងតែនិក្ខេបបទ ។ លោកបានសុំឲ្យប៊ីស្សពនៃវួដអុកហ្វើតឈ្មោះ អាឡេន វ៉េបស្ទើរ ផ្ដល់ការប្រសិទ្ធពរបព្វជិតភាព ។ នៅក្នុងការប្រសិទ្ធពរនោះ ដេវីតបានទទួលការសន្យានេះ ៖ « សូមបន្តធ្វើនូវគ្រប់កិច្ចការដែលអ្នកអាចធ្វើបាន ហើយព្រះអម្ចាស់នឹងប្រទានពរដល់អ្នក » ។

សមាជិកវួដពីរនាក់ដែលមានបទពិសោធន៍ជាលេខាផ្នែកច្បាប់បានស្ម័គ្រចិត្តជួយវាយឯកសារសរសេរដៃរបស់លោក ហើយដេវីតអាចបញ្ចប់និក្ខេបបទរបស់លោកក្នុងរយៈពេលពីរបីខែ ។ ប្រាកដណាស់ លោកបានបញ្ចប់ទាំងថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិតតែក្នុងរយៈពេលជាងបីឆ្នាំប៉ុណ្ណោះ ។ នៅពេលបញ្ចប់ការសិក្សា លោកក៏បានទទួលយកមុខងារស្រាវជ្រាវនៅមហាវិទ្យាល័យមួយនៅឯសាកលវិទ្យាល័យនោះ ។ បទពិសោធន៍របស់លោកនៅអុកហ្វើតបានពង្រឹងសេចក្ដីទុកចិត្តរបស់លោកលើព្រះអម្ចាស់ ជាការទុកចិត្តដែលស៊ូទ្រាំរហូតដល់ថ្ងៃនេះ ហើយនឹងបន្តប្រទានពរដល់ ដេតវីត ដ័បុលយូ ហ្គង កាលលោកបម្រើនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់នាពេលបច្ចុប្បន្ននេះ ។

### នំប៉័ង និងត្រី

អែលឌើរហ្គងថ្លែងថា « ព្រះអម្ចាស់មានព្រះទ័យសប្បុរស ហើយមានក្ដីមេត្តា និងស្វះស្វែងប្រទានពរដល់យើង ។ ប្រសិនបើយើងធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង នោះទ្រង់នឹងធ្វើឲ្យយើងអាចធ្វើកិច្ចការកាន់តែច្រើនឡើងជាងអ្វីដែលយើងអាចធ្វើបានទៀត ។ វាដូចជាការបង្កើនឡើងនូវនំប៉័ង និងត្រីដែរ ។ ព្រះអម្ចាស់យកនូវអ្វីដែលមាន ហើយពង្រីកវាឲ្យហួសឆ្ងាយពីអ្វីដែលយើងអាចធ្វើដោយខ្លួនយើងបាន » ។





អែលឌើរហ្គុងផ្ដល់ជូនសុភមង្គលដ៏ច្រើនរបស់លោកដល់ឪពុកម្ដាយរបស់លោក ជេន និង វ៉លធើរ និងភរិយាលោកគឺស៊ូសាន ។ លោកថ្លែងថា ផ្ទះរបស់ឪពុកម្ដាយលោក « ពោរពេញដោយគារវភាពយ៉ាងខ្លាំងសម្រាប់សេចក្ដីស្រឡាញ់របស់ព្រះសម្រាប់បុត្រាបុត្រីគ្រប់រូបរបស់ទ្រង់ » ។ ពេលអែលឌើរហ្គងជួបភរិយារបស់លោកនាគ្រាដំបូង លោកមានអារម្មណ៍ថា ស៊ូសានគឺជាមនុស្សម្នាក់ដែលលោកស្គាល់យូរណាស់មកហើយ ។

លោកថ្លែងថា គោលការណ៍អំពីនំប៉័ង និងត្រីក៏ពិតជាមួយនឹងការរៀនសូត្រផងដែរ ។ « ទោះបីជាពុំមានការអប់រំជាផ្លូវការក្ដី ក៏វិញ្ញាណនៃការរៀនសូត្រនៅតែមានតម្លៃ ដោយសារការរៀនសូត្រគឺអស់កល្ប ។ យើងទាំងអស់គ្នាអាចស្វែងរកពន្លឺ និងសេចក្ដីពិតបាន មិនថាយើងមានស្ថានភាពបែបណានោះទេ ។ នៅពេលយើងធ្វើដូច្នោះ នោះព្រះអម្ចាស់នឹងជួយយើងឲ្យរកឃើញវា » ។

## កម្មសិទ្ធិនៃសេចក្ដីសញ្ញា

អំឡុងពេលនៅអុកហ្វើត អែលឌើរហ្គងបានរៀនពីគោលការណ៍នៃដំណឹងល្អមួយផ្សេងទៀត ជាអ្វីដែលលោកហៅថា « កម្មសិទ្ធិនៃសេចក្ដីសញ្ញា » ។

លោកបានមានប្រសាសន៍ថា « នៅពេលយើងខិតកាន់តែជិតទៅនឹងព្រះអម្ចាស់ នោះយើងក៏ខិតកាន់តែជិតគ្នាផងដែរ ។ នៅអុកហ្វើត ស៊ូសាន និងខ្ញុំបានទទួលបទពិសោធន៍យ៉ាងល្អជាច្រើនមកពីវួដរបស់យើង ដូចជាយើងទទួលបានពីការសិក្សារបស់យើងផងដែរ ។ មិត្តភក្ដិជាទីស្រឡាញ់ជាច្រើននាក់របស់យើងរហូតមកដល់សព្វថ្ងៃនេះគឺជាអ្នកដែលមកពីវួដអុកហ្វើត » ។

ក្នុងចំណោមមិត្តភក្ដិទាំងនោះ គឺ ធីម និងខាធើរីន វីត ដែលចាំអំពីការទៅព្រះវិហារបរិសុទ្ធជាមួយអែលឌើរ និងស៊ីស្ទើរហ្គង ។ ស៊ីស្ទើរវីតនិយាយថា « ខ្ញុំចាំយ៉ាងច្បាស់ថា បងប្រុសហ្គងបានដោះនាឡិកាដៃរបស់លោកចេញ ដើម្បីកុំឲ្យវារំខានដល់លោក ឬបង្ខំដោយពេលវេលា ពេលលោកសញ្ជឹងគិតអំពីកិច្ចការអស់កល្បជានិច្ច ។ ទង្វើដ៏តូចតាចនោះបានជួយខ្ញុំឲ្យមានភាពឧស្សាហ៍កាន់តែខ្លាំងឡើងនៅក្នុងការថ្វាយបង្គំផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងព្រះវិហារបរិសុទ្ធ » ។

ជារឿយៗ អែលឌើរ និងស៊ីស្ទើរហ្គងជួបមិត្តភក្ដិដែលពួកលោកស្គាល់គឺដោយសារតែដំណឹងល្អ ។ អែលឌើរហ្គងថ្លែងថា « គេនឹងនិយាយបែបនេះថា ‹ យើងបានធ្វើការជាមួយអ្នក កាលអ្នកនៅក្នុងក្រុមប្រឹក្សា › ហើយយើងក៏ដូច្នោះផងដែរ ។ ខ្ញុំមានអំណរគុណសម្រាប់ប្រធានស្តេក និងក្រុមប្រឹក្សាវួដដែលបានជួយខ្ញុំកាលខ្ញុំជាប៊ីស្សពវ័យក្មេងម្នាក់ ។ យើងជំពាក់គុណឪពុកម្ដាយ, សាច់ថ្លៃ, អ្នកជិតខាង, ប្រធានបេសកកម្ម, បងប្អូនស្រី និងថ្នាក់ដឹកនាំបព្វជិតភាពទាំងអស់ដែលមានចិត្តសប្បុរសចំពោះយើងដឹកនាំយើង និងលើកទឹកចិត្តយើងឲ្យមកកាន់ព្រះគ្រីស្ទ » ។

## មរតកគ្រួសារ

ពង្សប្រវត្តិរបស់អែលឌើរហ្គងមាន ៣៤ ជំនាន់រហូតដល់ហ្គងត្រាហ្គន់ទីមួយ ដែលបានកើតនៅក្នុងឆ្នាំ ៨៣៧ នៃគ.ស. ។ តាយាយរបស់អែលឌើរហ្គងបានធ្វើអន្តោប្រវេសន៍មកពីប្រទេសចិនទៅសហរដ្ឋអាមេរិក ។ ជេនដែលជាម្ដាយរបស់លោកបានចូលជា

រូបភាពផ្ទៃខាងក្រោយមកពី GETTY IMAGES

សមាជិកសាសនាចក្រកាលនៅវ័យជំទង់នៅរដ្ឋហាវ៉ៃ ស.រ.អា. ហើយក្រោយមកបានចូលរៀននៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅទីក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ ស.រ.អា. ជាកន្លែងដែលគាត់បានស្នាក់នៅជាមួយគ្រួសារជែរីត ឌី ចុង ជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិចិត្រសិល្បៈ ។ គាត់និយាយថា « គ្រួសារ ឌី ចុង បានជួយខ្ញុំឲ្យយល់អំពីអត្ថន័យនៃគ្រួសារដែលមានដំណឹងល្អ » ។

បន្ទាប់ពីបញ្ចប់ការសិក្សានៅ ប៊ី.វ៉ាយ.យូ. ជេនបានចូលរៀនសាកលវិទ្យាល័យស្ទែនហ្វតនៅទីក្រុងផាឡូ អាលតូ រដ្ឋកាលីហ្វូញ៉ា ស.រ.អា. ជាកន្លែងដែលគាត់បានជួប វ៉ាតធើរ អេ ហ្គង ។ ជេននិយាយថា « គាត់គឺជាគ្រិស្តសាសនិករួចទៅហើយ ហើយគាត់បានយល់ភ្លាមនូវអ្វីដែលដំណឹងល្អដែលបានស្ដារឡើងវិញបានផ្ដល់ឲ្យ » ។ គាត់បានចូលរួមសាសនាចក្រ ហើយមួយឆ្នាំក្រោយមក ពួកគាត់បានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។ ពួកគាត់ទាំងពីរនាក់បានក្លាយជាគ្រូបង្រៀនដ៏មានវិជ្ជាជីវៈ ទាំងពីរនាក់ ពួកគាត់បានចំណាយពេលជាង ៧០ ឆ្នាំក្នុងការបង្រៀន ។

អែលឌើរហ្គងថ្លែងថា « ប៉ាខ្ញុំក៏បានក្លាយជាលោកអយ្យកោ ហើយដោយសារតែពរជ័យនៃលោកអយ្យកោត្រូវបានផ្ដល់ឲ្យនៅក្នុងផ្ទះរបស់យើង នោះផ្ទះរបស់យើងបានពោរពេញដោយគារវភាពយ៉ាងជ្រាលជ្រៅចំពោះសេចក្ដីស្រឡាញ់របស់ព្រះសម្រាប់បុត្រាបុត្រីគ្រប់រូបរបស់ទ្រង់ » ។

នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៥៣ នៅទីក្រុងរ៉េតវ៉ូត ស៊ីធី រដ្ឋកាលីហ្វូញ៉ា កូនដំបូងក្នុងចំណោមកូនទាំងបីរបស់ជេន និង វ៉ាតធើរបានកើត ។ ជេនពន្យល់ថា « ឈ្មោះលោកគឺ ជែរីត ជាភាសាហូឡង់ដើម្បីរំឭកដល់ ជែរីត ឌី ចុង ។ ឈ្មោះកណ្ដាលរបស់លោកគឺ វ៉ាតធើរ ដើម្បីរំឭកចាំដល់ឪពុករបស់លោក ។ ហើយឈ្មោះត្រកូលរបស់យើងគឺជាភាសាចិន ដែលរំឭកចាំពីមរតករបស់លោក » ។

ជេននិយាយថា ជែរីតចេះគិតគូរដល់ប្អូនៗរបស់លោកគឺប្រាយអិន និង ម៉ាហ្គើរីត ។ ជេននិយាយថា « លោកចូលចិត្តជួយពួកគេ ទោះបីជាមានកិច្ចការតូចតាចក្ដី ដូចជាការបង្រៀនពួកគេឲ្យចងស្បែកជើងជាដើម » ។ ជេនចាំពីថ្ងៃមួយពេលចេញពីព្រះវិហារត្រឡប់មកផ្ទះវិញ ហើយបានឮជែរីត និងប្រាយអិននិយាយគ្នាដោយចៃដន្យថា ពួកគេបានគិតថា ការឡើងនិយាយនៅការប្រជុំសាក្រាម៉ង់គួរឲ្យធុញទ្រាន់ ។ ជេននិយាយថា « ដូច្នេះខ្ញុំបានអញ្ជើញពួកគេ ៖ ‹ ដូច្នេះកូនលើកយកការនិយាយដែលល្អប្រសើរជាងនេះមួយមក › ។ ពួកគេបានទទួលយកការអញ្ជើញនោះ ហើយបានចាប់ផ្ដើមផ្ដោតចិត្តទុកដាក់កាន់តែខ្លាំងលើការនិយាយទាំងអស់ » ។





ចាប់ពីឆ្វេង ៖ ម៉ាជូរី និង ហ្វរដុន ប៊ី ហ៊ិងគ្លី ស្វាគមន៍ ជែរីត និង ស៊ូសាននៅភោជនីយអាហារនៃអាពាហ៍ពិពាហ៍របស់គ្រួសារហ្គង ។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនានៅប្រទេសតៃវ៉ាន់ អែលឌើរហ្គងបានបង្រៀនគ្រួសារមួយ ហើយជាច្រើនឆ្នាំក្រោយមក ក្នុងនាមជាអ្នកមានសិទ្ធិអំណាចទូទៅម្នាក់ លោកបានជួបចៅប្រុសរបស់កូនស្រីម្នាក់នៃគ្រួសារនោះ ។ នៅប្រទេសវៀតណាម អែលឌើរ និង ស៊ីស្ទើរហ្គងលាបពណ៌គំនូរនៅលើជញ្ជាំងជារបៀបមួយនាំអំណរដល់ក្មេងៗដែលជួបនូវឧបសគ្គ ។ សមាជិកនៃគ្រួសារហ្គងបានប្រមូលគ្នាជាមួយនឹងអ្នកដែលបានជួយលាបថ្នាំលើជញ្ជាំងនៅប្រទេសវៀតណាម ។

កាលនៅវ័យជំទង់ ជែរីតចូលចិត្តដើរលេងដោយស្ពាយកាតាប ហើយឡើងភ្នំជាមួយយុវជនផ្សេងទៀតនៅក្នុងវួដរបស់លោក ។ វ៉លលី សាលប៉ែកខា ជាមិត្តយូរអង្វែងម្នាក់ចាំអំពីដំណើរបោះជំរំដ៏ពិសេសមួយ ។ « ខ្ញុំបាននៅទីនោះជាមួយជែរីត និងប្អូនប្រុសរបស់លោកគឺប្រាយអិន និងមិត្តម្នាក់ទៀតដែលពុំមែនជាសមាជិកសាសនាចក្ររបស់យើងទេ ។ ដោយហេតុផលមួយចំនួន យើងបានចាប់ផ្ដើមច្រៀងទំនុកតម្កើង ។ ជែរីតបានច្រៀងតុងមេឡូឌី, ប្រាយអិនបានច្រៀងតុងតេណ័រ ហើយខ្ញុំបានច្រៀងតុងបាស ។ ខ្ញុំគិតថា យើងបានច្រៀងទំនុកតម្កើង ១០ ឬ ២០ បទដោយព្រោះតែអំណរនៃការច្រៀង ។ វាជាបទពិសោធន៍មួយដ៏ល្អ ។ មិត្តភក្ដិម្នាក់ដែលពុំមែនជាសមាជិករបស់យើងកោតសរសើរយើងណាស់ » ។

បងប្រុសសាលប៉ែកខាក៏ចាំថា នៅវិទ្យាល័យជែរីតបានសុំឲ្យក្រុមអ្នកស្រែកហ៊ោ ដឹកនាំការអបអរសាទរដ៏ស្វាត់ស្ទៀមមួយសម្រាប់ក្រុមលេងអុក ។ គាត់និយាយថា « លោកបានបញ្ចុះបញ្ចូលពួកគេថា ការគាំទ្រផ្នែកសីលធម៌គឺល្អដល់មនុស្សគ្រប់គ្នា ហើយពួកគេបានមកមើលការប្រកួតមួយ ! »

បន្ទាប់ពីចប់ពីវិទ្យាល័យ អែលឌើរហ្គងបានចូលរៀនសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។ ពីឆ្នាំ ១៩៧៣ ដល់ ១៩៧៥ លោកបានបម្រើនៅក្នុងបេសកកម្មតៃវ៉ាន់ តៃប៉ិ ក្រោយមកបានត្រឡប់ទៅ ប៊ី.វ៉ាយ.យូ. វិញ ជាកន្លែងដែលលោកបានទទួលបរិញ្ញាបត្ររបស់លោកក្នុងការសិក្សាអំពីពួកអាស៊ី និងការសិក្សាអំពីសាកលវិទ្យាល័យនៅឆ្នាំ ១៩៧៧ ។

## សេចក្ដីស្នេហា និងអាពាហ៍ពិពាហ៍

បន្ទាប់ពីបេសកកម្ម អែលឌើរហ្គងបានស្ម័គ្រចិត្តផ្ដល់ការប្រជុំពិសេសពេលល្ងាចនៅថ្ងៃអាទិត្យនៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នក

ផ្សព្វផ្សាយសាសនាប្រ្សូ ។ ការប្រជុំពិសេសនោះបានជួយអ្នកផ្សព្វផ្សាយសាសនាដែលនឹងទៅប្រទេសតៃវ៉ាន់ឲ្យស្គាល់អំពីប្រជាជន ប្រពៃណី និងវប្បធម៌នៅទីនោះ ។ អ្នកផ្សព្វផ្សាយសាសនាម្នាក់គឺស៊ីស្ទើរ ស៊ូសាន លីនសាយ មកពីទីក្រុង ថេលើរស្វីល រដ្ឋយូថាហ៍ ជាកូនស្រីរបស់ រីឆាដ ភី និង ម៉ារៀន ប៊ី លីនសាយ ។ បងប្រុសលីនសាយគឺជាសមាជិកម្នាក់ក្នុងកូរ៉ុមទីពីរនៃពួកចិតសិបនាក់ ។ អែលឌើរហ្គងថ្លែងថា « ខ្ញុំមានអារម្មណ៍ថា ស៊ូសានគឺជាមនុស្សម្នាក់ដែលខ្ញុំស្គាល់យូរមកហើយ » ។

ពីរឆ្នាំក្រោយមក ប៉ុន្មានខែបន្ទាប់ពីស៊ូសានបានត្រឡប់មករៀន ប៊ី.វ៉ាយ.យូ. វិញបន្ទាប់ពីបេសកកម្មរបស់គាត់ ជែរីតបាននៅទីក្រុងប្រ្សូជាមួយគ្រួសាររបស់លោក ។ ឪពុករបស់លោកកំពុងបង្រៀននៅសាកលវិទ្យាល័យ ហើយជែរីតបានដាក់ផែនការទៅសួរសុខទុក្ខគាត់ពីរសប្ដាហ៍ ។ ការទៅសួរសុខទុក្ខនោះត្រូវបានអូសបន្លាយរហូតដល់បួនសប្ដាហ៍ ដោយសារលោក និងស៊ូសានបានដើរលេងជាគូរៀងរាល់ថ្ងៃ ។ បន្ទាប់មក ជែរីតបានចេញទៅធ្វើកម្មសិក្សានៅរដ្ឋហាវ៉ៃ ពីមុនត្រឡប់ទៅកាន់អុកហ្វើតវិញ ។

អែលឌើរហ្គងរំឭកថា « យើងបានចែចង់គ្នាទោះនៅក្នុងអឌ្ឍគោលពីរផ្សេងគ្នាក្ដី ។ ខ្ញុំបានព្យាយាមរៀននៅក្នុងប្រទេសអង់គ្លេស អំឡុងពេលខ្ញុំរៀនអ្វីៗគ្រប់យ៉ាងដែលខ្ញុំអាចរៀនបានអំពីស៊ូសានដែលនៅឯនាយម្ខាងនៃសមុទ្រអាត្លង់ទិច » ។






ស៊ីស្ទើរហ្គងនិយាយថា « យើងបានភ្ជាប់ពាក្យគ្នាតាមទូរសព្ទ ។ លោកបានត្រឡប់មកផ្ទះវិញនៅឱកាសបុណ្យថ្លែងអំណរគុណ ហើយយើងបានរៀបការនៅថ្ងៃដំបូងដែលព្រះវិហារបរិសុទ្ធបានបើកក្រោយពេលចូលឆ្នាំថ្មី » ។ ពីរសប្ដាហ៍ក្រោយមក ពួកយើងបានជិះយន្តហោះទៅប្រទេសអង់គ្លេសដើម្បីចាប់ផ្ដើមជីវិតថ្មីជាមួយគ្នា ។

អែលឌើរហ្គងថ្លែងថា « ពេលមនុស្សរៀបការ ពួកគេនិយាយអំពីគ្រួសារពីរក្លាយទៅជាគ្រួសារតែមួយ ។ ហើយនោះគឺពិតជាអ្វីដែលបានកើតឡើងចំពោះខ្ញុំ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំជាផ្នែកមួយនៃគ្រួសារលីនសាយ គឺដូចរូបខ្ញុំជាផ្នែកមួយនៃគ្រួសារហ្គងផងដែរ » ។

### មុខរបរដ៏លេចធ្លោ

បន្ទាប់ពីលោកបានចំណាយពេលដ៏ខ្លីនៅមហាវិទ្យាល័យនៅអុកហ្វើត មុខរបររបស់ជែរីតបានប្ដូរទៅបម្រើរដ្ឋាភិបាលនៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី ស.រ.អា. ។ ក្នុងឆ្នាំ ១៩៨៤ លោកបានបម្រើជាបុគ្គលិកក្នុងយុទ្ធនាការបោះឆ្នោតឡើងវិញ រៀហ្គាន-ប៊ូស្ស ជាកន្លែងដែលលោកបានធ្វើការរួមការិយាល័យជាមួយ ម៉ៃ លេវីត ដែលក្រោយមកបានក្លាយជាអភិបាលរដ្ឋយូថាហ៍ ។ បងប្រុសលេវីតនិយាយថា « ជែរីតគឺជាមនុស្សដែលចេះសង្កេត និងចេះគិតគូរ ប៉ុន្តែលោកត្រូវបានគេស្គាល់ដោយសារសេចក្ដីសប្បុរសដ៏ឥតឈប់ឈររបស់លោក » ។

នៅក្នុងឆ្នាំ ១៩៨៥ ជែរីតបានបម្រើជាជំនួយការពិសេសម្នាក់ឲ្យអនុរដ្ឋលេខាធិការនៃនាយកដ្ឋានរដ្ឋ ។ នៅក្នុងឆ្នាំ ១៩៨៧ លោកបានក្លាយជាជំនួយការពិសេសម្នាក់ឲ្យអគ្គរាជទូតនៃសហរដ្ឋនៅក្នុងទីក្រុងប៉េកាំង ប្រទេសចិន ។ ហើយចាប់ពីឆ្នាំ ១៩៨៩ ទៅឆ្នាំ ២០០១ លោកបានបំពេញមុខងារជាច្រើននៅមជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រ និងអន្តរជាតិនៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ។ បន្ទាប់មក លោកបានត្រឡប់ទៅពិភពសិក្សាវិញ នៅពេលលោកបានទទួលមុខងារជាជំនួយការប្រធានសម្រាប់ការដាក់ផែនការយុទ្ធសាស្ត្រនៅ ប៊ី.វ៉ាយ.យូ. ។ លោកបានចំណាយពេលប្រាំបួនឆ្នាំនៅក្នុងមុខតំណែងនោះ ។

ខារី ជេនឃីន ជំនួយការឲ្យប្រធានទំនាក់ទំនងនៃសាកលវិទ្យាល័យនៅ ប៊ី.វ៉ាយ.យូ. បានធ្វើការនៅការិយាល័យជាប់នឹងលោក ។ ជេនឃីនចាំអំពីសមត្ថភាពរបស់ជែរីត ហ្គង ក្នុងការលើកទឹកចិត្តដល់អ្នកដែលនៅជុំវិញលោក ។ ជេនឃីននិយាយថា « ប្រសិនបើអ្នកគ្មានទំនុកចិត្តថា អ្នកអាចទទួលយកការចាត់តាំង



ពិបាកណាមួយទេនោះ លោកមានទំនុកចិត្តនោះសម្រាប់អ្នក ។ លោកធ្វើអ្វីៗគ្រប់យ៉ាងនៅក្នុងអំណាចលោកដើម្បីប្រឹក្សាអ្នក ផ្ដល់ក្ដីសង្ឃឹមដល់អ្នក ហើយទុកឲ្យអ្នកបន្តឆ្ពោះទៅមុខ ហើយបញ្ជាក់ដល់ខ្លួនអ្នកផ្ទាល់ » ។

ថូម៉ាស ប៊ី ហ្គ្រីហ្វីស្ស ចៅក្រមសហព័ន្ធ ដែលស្គាល់អែលឌើរហ្គងទាំងនៅវ៉ាស៊ីនតោន និង ប៊ី.វ៉ាយ.យូ. ពិពណ៌នាអំពីទំនាក់ទំនងជាមួយលោកតាមរបៀបនេះ ៖ « នៅចុងបញ្ចប់នៃការសន្ទនា នោះអ្នកដឹងថា ការផ្ដោតចិត្តទុកដាក់បានមានលើរូបអ្នក ។ លោកគឺជាអ្នកដែលពូកែស្ដាប់ ។ ហើយលោកសួរសំណួរដែលធ្វើឲ្យអ្នកគិត » ។

ស៊ីសីល អូ សាំយ៉ូអែលសុន អ្នកមានសិទ្ធិអំណាចទូទៅក្នុងក្រុមចិតសិបនាក់ដែលបានដោះលែងពីតំណែង និងជាអតីតប្រធាន ប៊ី.វ៉ាយ.យូ. ថ្លែងថា អែលឌើរហ្គង « ជាទូទៅស្ងប់ស្ងាត់ ប៉ុន្តែចិត្តរបស់លោកគឺមិនស្ងប់ស្ងាត់ទេ » ។

**ជីវិតគ្រួសារ**

ដេវីត និងស៊ូសាន ហ្គង បានក្លាយជាឪពុកម្ដាយនៃកូនប្រុសបួននាក់ — អ័ប្រាហាំ, សាំយ៉ូអែល, គ្រីស្ទស្តូហ្វើរ, និងម៉ាធ្យូ — ដែលបានធំដឹងក្ដីឡើងនៅក្នុងបរិយាកាសផ្សេងៗ ។

អែលឌើរហ្គងថ្លែងថា « កាលយើងនៅទីក្រុងប៉េកាំង កូនៗរបស់យើងមានពរដោយការក្លាយជាមិត្តភក្ដិជិតស្និទ្ធនឹងគ្នា » ។

ស៊ីស្ទើរហ្គងបន្ថែមថា « ទីមួយ ពួកគេមានឱកាសដើម្បីឃើញទស្សនវិស័យដ៏ទូលំទូលាយនៃពិភពលោក ។ ទីពីរ វាជួយយើងឲ្យមានចំណងរឹងមាំជាគ្រួសារ ។ កូនប្រុសរបស់យើងនៅតែនិយាយថា រឿងដ៏ល្អបំផុតដែលយើងបានធ្វើក្នុងនាមជាឪពុកម្ដាយនោះគឺ បានផ្ដល់បងប្អូនប្រុសដល់ពួកគេ » ។

អែលឌើរហ្គងថ្លែងថា « មានម្ដងនោះ យើងបានប្ដូរពិន្ទុនៃកម្មវិធីជិះយន្តហោះដែលយើងបានប្រមូលជាច្រើន ទៅជាការជិះយន្តហោះដោយឥតគិតថ្លៃ ។ យើងបានអនុញ្ញាតឲ្យពួកគេម្នាក់ៗជ្រើសរើសទិសដៅមួយ ។ យើងបានចាប់ផ្ដើមនៅវ៉ាស៊ីនតោន ឌី.ស៊ី. ជាកន្លែងដែលយើងបានរស់នៅ បន្ទាប់មកទៅប្រទេសអង់គ្លេស, សាធារណៈរដ្ឋឆែក, ក្រិក, តួកគី, ឥណ្ឌា, ចិន និងជប៉ុន ។

ស៊ូសាននិយាយថា « យើងមានច្បាប់តឹងរឹងមួយអំឡុងពេលធ្វើដំណើរនោះ ។ មិនថាយើងទៅទីណានោះទេ នោះយើងបរិភោគអាហារដែលមនុស្សនៅក្នុងតំបន់នោះបរិភោគ » ។ ទីបំផុត នៅក្នុងប្រទេសជប៉ុនជាគោលដៅចុងបញ្ចប់នៃដំណើរនោះ អែលឌើរហ្គងបានប្រាប់កូនប្រុសរបស់លោកថា លោកនឹងនាំពួកគេទៅភោជនីយដ្ឋានមួយដែលល្បីឈ្មោះទូទាំងពិភពលោកខាងសាច់គោ ។ នៅឯហាងម៉ាកដូណាល់ កូនប្រុសទាំងបួននាក់ និងឪពុកម្ដាយទាំងពីរដែលឃ្លានបានបរិភោគហេមបើហ្គើរអស់ចំនួន ១៧ !

អ័ប្រាហាំនិយាយថា « ទាំងប៉ា និងម៉ាក់បានផ្ដល់គុណតម្លៃខ្ពស់លើការរៀនសូត្រតាមរយៈបទពិសោធន៍ ។ ប៉ាគិតយ៉ាងជ្រាលជ្រៅអំពីរបៀបដែលបទពិសោធន៍សម្រួចសម្រាំងមនុស្ស រួមទាំងវប្បធម៌ទាំងមូលផង » ។ អ័ប្រាហាំក៏កត់សម្គាល់ឃើញថា ឪពុករបស់គាត់ « និយាយយ៉ាងប្រុងប្រយ័ត្ន ដោយសារលោកត្រូវតែនិយាយដោយម៉ឺងម៉ាត់ទាំងស្រុង ហើយជឿទាំងស្រុងនូវអ្វីដែលលោកថ្លែង » ។

សាំយ៉ូអែលចាំថា « ទោះបីជាប៉ារវល់កាលគាត់នៅឯនាយកដ្ឋានរដ្ឋក្ដី ក៏ប៉ាឆ្លៀតពេលរៀងរាល់យប់ដើម្បីបង្រៀន និងបំពាក់បំប៉នខ្ញុំសម្រាប់ការប្រឡងប្រកួតប្រជែងផ្នែកគណិតវិទ្យាថ្នាក់ទីបីដែលខ្ញុំចង់ចូលប្រកួតនោះផងដែរ ដែលហៅថា ‹ ការប្រកួតប្រជែង ២៤ › ។ លោកបានមានប្រសាសន៍ថា ប្រសិនបើខ្ញុំឈ្នះ យើងនឹងជប់លៀងជាមួយការ៉េមសាន់ដេ ហើយមានដាក់គ្រឿងបន្ថែម ២៤ មុខ ។ សាំយ៉ូអែលបានប្រឡងជាប់រហូតដល់ថ្នាក់ជាតិចុងក្រោយ ប៉ុន្តែគាត់ពុំបានជាប់នៅថ្នាក់ជាតិទេ ។ ទោះជាយ៉ាងណាក្ដី គ្រួសារហ្គងនៅតែទៅបរិភោគការ៉េមសាន់ដេ ។ ប៉ុន្តែវាពុំងាយស្រួលដើម្បីធ្វើគ្រឿងបន្ថែម ២៤ មុខឡើយ — គ្រឿងដែលពិបាកនោះគឺសាច់គោងៀត ។

គ្រីស្ទស្តូហ្វើរ និង ម៉ាធ្យូ បានថ្លែងយ៉ាងច្រើនអំពី « អំណរគុណចំពោះទំនុកចិត្ត សេចក្ដីស្រឡាញ់ និងការលះបង់របស់ឪពុកម្ដាយរបស់យើងដែលមានសម្រាប់យើង » ។ វាជាសេចក្ដីស្រឡាញ់ដែលអែលឌើរ និងស៊ីស្ទើរហ្គងចែកចាយជាមួយគ្នា



ព្រមទាំងជាមួយកូនប្រុសគ្រប់រូប និងសាច់ញាតិគ្រួសារ ។

ស៊ូសាននិយាយថា « ជេរីតគឺជាកូនប្រុស និងបងប្រុសដែលលះបង់ ព្រមទាំងជាឪពុកដែលមានការលះបង់ផងដែរ ។ ច្បាប់ទាំងនោះសំខាន់ចំពោះលោកណាស់ ។ លោកជួយយើងឲ្យយល់ថា ទំនាក់ទំនងគ្រួសារគឺសំខាន់ជាងអ្វីៗទាំងអស់ » ។

**បទពិសោធន៍សាសនាចក្រ**

ទោះបីជារវល់ជាមួយនឹងការងារ និងគ្រួសារក្ដី អែលឌើរហ្គងបានបន្តដោយមានឆន្ទៈបម្រើនៅក្នុងសាសនាចក្រ បំពេញការហៅបម្រើក្នុងនាមជាទីប្រឹក្សាជាន់ខ្ពស់, អ្នកដឹកនាំក្រុមសង្ឃជាន់ខ្ពស់, ប្រធានសាលាថ្ងៃអាទិត្យស្ដេក, គ្រូបង្រៀនថ្នាក់សិក្ខាសាលា, ប៊ីស្សព, ប្រធានបេសកកម្មស្ដេក, ប្រធានស្ដេក និងពួកចិតសិបនាក់ប្រចាំតំបន់ ។

មិនថាលោកត្រូវបានហៅឲ្យបម្រើក្នុងមុខងារអ្វីក៏ដោយ ហើយមិនថានៅក្នុងជីវិតគ្រួសារលោកនោះទេ លោកតែងបង្ហាញ



បុគ្គលិកលក្ខណៈប្រាកដប្រជាយ៉ាងខ្ជាប់ខ្ជួន ។ ស៊ីស្ទើរហ្គងនិយាយថា « លោកឃើញថា មនុស្សគ្រប់គ្នាគឺជាបុត្រា ឬបុត្រារបស់ព្រះវរបិតាសួគ៌ ។ ប៉ុន្តែលើសពីអ្វីទាំងអស់នោះ លោកស្រឡាញ់ព្រះអម្ចាស់ ។ លោកពិតជាមានបំណងប្រាថ្នាដោយអស់ពីដួងចិត្តលោកដើម្បីស្ដាបនានគរ និងផ្ដល់ពរដល់បុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ » ។

ហើយលោកបានកោតសរសើរភរិយាលោក ។ លោកថ្លែងថា « ទោះជាអ្វីដែលខ្ញុំត្រូវបានហៅឲ្យធ្វើក្ដី ស៊ូសានតែងនៅក្បែរខ្ញុំ ។ គាត់រីករាយជាមួយមនុស្សគ្រប់គ្នា ហើយឈោងទៅរកមនុស្សដទៃទៀត ។ គាត់មានឆន្ទៈទៅកន្លែងថ្មីៗ ហើយសាកល្បងកិច្ចការថ្មីៗជានិច្ច ជាអ្វីដែលខ្ញុំមានអំណរគុណ » ។

រូបថតនៅការប្រជុំធំៗផ្ដល់ជូនដោយ *DESERET NEWS*



ចាប់ពីខាងឆ្វេង ៖ នៅក្នុងប្រទេសថៃ អែលឌើរហ្គង បានជួបជាមួយលោកម្ចាស់ ហ្វ្រាំងស៊ីស សាវៀរ ដែលជាសង្ឃថ្នាក់ខ្ពស់ គ្រៀងសាក់ កូវីថាវ៉ានីយ ជាសង្ឃកាតូលិកនៅទីក្រុងបាំងកក ។ អែលឌើរហ្គងរីករាយក្នុងការធ្វើដំណើរផ្ទាល់ខ្លួនជាមួយពួកកូនប្រុសរបស់លោក នេះជាការធ្វើដំណើរនៅប្រទេសកាណាដាជាមួយកូនប្រុសរបស់លោក សាំយ៉ូអែល ។ អែលឌើរហ្គងបានចែកចាយគំនិតរបស់លោកអំពីនំប៉ុងជីវិតជាមួយគ្រូបង្រៀនថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានក្នុងឆ្នាំ ២០១៧ ។ ស៊ីស្ទើរហ្គងស្វាគមន៍គ្នានៅក្នុងផ្ទះនៃសមាជិកម្នាក់នៅក្នុងប្រទេសកម្ពុជា ។

**ការបម្រើជាមួយពួកចិតសិបនាក់**

អែលឌើរ ជេរីត ជ័បុលយូ ហ្គង ត្រូវបានគាំទ្រជាពួកចិតសិបនាក់ដែលមានសិទ្ធិអំណាចទូទៅនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១០ ។ លោកត្រូវបានចាត់តាំងឲ្យទៅទីស្នាក់ការកណ្ដាលនៃគណៈប្រធានតំបន់អាស៊ីនៅទីក្រុងហុងកុង ។ ក្រោយមកលោកបានក្លាយជាប្រធានតំបន់អាស៊ី ។ អែលឌើរហ្គងត្រូវបានគាំទ្រជាគណៈប្រធាននៃពួកចិតសិបនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៥ ជាពេលដែលបទពិសោធន៍ផ្នែកអន្តរជាតិរបស់លោកបានបន្ត រួមមានការពិនិត្យតំបន់នៅក្នុងផ្នែកផ្សេងៗនៃពិភពលោកដូចជាទ្វីបអាហ្វ្រិក និងអាមេរិកកណ្ដាល ។

លោកថ្លែងថា « អ្នកទៅជួប និងស្រឡាញ់ពួកបរិសុទ្ធនៅក្នុងគ្រប់ទីកន្លែងទាំងអស់នេះ ។ អ្នកមានពរដែលមានមនុស្សប្រាប់អ្នកអំពីសេចក្ដីជំនឿរបស់ពួកគេ ដោយសារបទពិសោធន៍របស់ពួកគេអំពីព្រះធ្វើការនៅក្នុងជីវិតរបស់ពួកគេក្លាយជាផ្នែកនៃការយល់ដឹងអំពីព្រះ និងរបៀបដែលទ្រង់ស្រឡាញ់ពួកយើងម្នាក់ៗ » ។

ប្រធាន រ័សុល អិម ណិលសុន ថ្លែងថា « ពេលយើងបញ្ជូនអែលឌើរហ្គងទៅក្នុងស្ថានភាពណាមួយ នោះអ្នកដែលទាក់ទងលោកទទួលអារម្មណ៍ថា ពួកគេបានជួបមិត្តម្នាក់ ។ លោកមានចំណេះដឹងខ្ពស់ ប៉ុន្តែលោកមានការបន្ទាបខ្លួន ។ លោកទាក់ទងជាមួយមនុស្សគ្រប់ស្រទាប់វណ្ណៈ ហើយតែងតែរៀបចំខ្លួនបានល្អ និងយោគយល់គ្នា » ។

**ការហៅបម្រើជាសាវក**

ពេលប្រធានណិលសុនផ្ដល់ការហៅបម្រើដល់អែលឌើរហ្គងឲ្យបម្រើជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះព្យាការី « ដោយក្ដីស្រឡាញ់ បានចាប់ដៃរបស់ខ្ញុំ [ ជាមួយ ] នឹងភរិយាជាទីស្រឡាញ់របស់ខ្ញុំ ស៊ូសានដែលនៅក្បែរខ្ញុំ ហើយផ្ដល់ការហៅបម្រើក្នុងមុខងារដ៏ពិសិដ្ឋនេះមកពីព្រះអម្ចាស់ ដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល » ( ព្រះគ្រីស្ទទ្រង់បានរស់ឡើងវិញ » *Liahona*, ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៧ ) ។ ដោយបន្ទាបខ្លួន ប៉ុន្តែដោយភាពជឿជាក់នៃសេចក្ដីស្រឡាញ់ និងការទុកចិត្តរបស់លោកលើព្រះអម្ចាស់ នោះអែលឌើរហ្គងបានទទួលយកការហៅបម្រើនោះ ។ លោកត្រូវបានគាំទ្រនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៨ ។ ដោយបានរៀបចំយ៉ាងប្រុងប្រយ័ត្នដោយព្រះអម្ចាស់ ឥឡូវនេះលោកនឹងធ្វើការងារបម្រើក្នុងនាមជា « [ សាក្សី ] ពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក » ( គ. និង ស. ១០៧:២៣ ) ។ ■



**ដោយ អែលឌើរ នែល អិល អាន់ឌើសិន**
ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

## អែលឌើរ អូលីសេស សូរ៉េស ៖

# បុរសដែលឥតមានឧបាយកល

នៅគ្រាដំបូងនៃការងារបម្រើរបស់ទ្រង់ នៅពេលព្រះយេស៊ូវកំពុងជ្រើសរើសពួកសាវករបស់ទ្រង់ នោះទ្រង់បានឃើញណាថាណែលមកឯទ្រង់ ។ រំពេចនោះទ្រង់បានជ្រាបដឹងអំពីសេចក្ដីល្អរបស់ណាថាណែលដោយប្រកាសថា « នុ៎ះន៏ ជាសាសន៍អ៊ីស្រាអែលពិតមែន ដែលឥតមានចិត្តឧបាយ ![១]

ព្រះយេស៊ូវបានដឹងថា ណាថាណែលគឺជាបុរសម្នាក់ដែលមានចិត្តបរិសុទ្ធ មានបំណងស្មោះត្រង់ និងពុំលាក់ពុត ឬចេះបោកបញ្ឆោតឡើយ ។ ព្រះអម្ចាស់សព្វព្រះទ័យនឹងគុណសម្បត្តិនៃសេចក្ដីទៀងត្រង់ដ៏សុចរិតនេះ ហើយទ្រង់បានហៅណាថាណែលឲ្យធ្វើជាសាវក ។[២]

អូលីសេស សូរ៉េស គឺជាដូចជាណាថាណែលកាលពីបុរាណ ហើយព្រះអង្គសង្គ្រោះបានហៅលោកផងដែរ ។

**« គំរូរបស់ឪពុកម្ដាយខ្ញុំ »**

អូលីសេស ដែលជាប្អូនប្រុសពៅគេក្នុងចំណោមបងប្អូនប្រុសបួននាក់ បានកើតនៅទីក្រុង សៅ ប៉ូឡូ ប្រទេស ប្រេស៊ីល នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៥៨ ។ លោកបានកើតមកពីកន្លែងដ៏រាបទាប ប៉ុន្តែឪពុកម្ដាយរបស់លោក អាបប៉ារេស៊ីដូ និង មែសេដេស ការេឆូ សូរ៉េស គឺជាមនុស្សគួរឲ្យគោរព ខិតខំធ្វើការដែលស្ដាប់អ្នកផ្សព្វផ្សាយសាសនាដោយស្មោះត្រង់ ។ ពួកគាត់បានចូលជាសមាជិកសាសនាចក្រនៅក្នុងឆ្នាំ ១៩៦៥ នៅពេលអូលីសេសអាយុប្រាំមួយឆ្នាំ ។

អូស៊ីរីស កាប្រាល ដែលបានបម្រើជាប្រធានស្ដេកកាលអូលីសេសនៅជាយុវជនបាននិយាយថា « ខ្ញុំពុំធ្លាប់ឃើញបងប្រុសអាបប៉ារេស៊ីដូ ខកខានការប្រជុំមួយឡើយ ។ មែសេដេសក៏ស្មោះត្រង់ណាស់ផងដែរ ។ អូលីសេសបានទទួលមរតកនៃការបូជារបស់ឪពុកម្ដាយលោក » ។



ដួងចិត្តដ៏ល្អពីធម្មជាតិរបស់អូលីសេសបានកើនឡើង នៅពេលលោកបានរៀនអំពីមាគ៌ារបស់ព្រះអម្ចាស់ ។ អែលឌើរ សូរ៉េស បានថ្លែងថា « ខ្ញុំធំដឹងក្ដីឡើងនៅក្នុងសាសនាចក្រដោយធ្វើតាមគំរូរបស់ឪពុកម្ដាយខ្ញុំ » ។ នៅពេលលោកបានធ្វើតាមគំរូនោះ ទីបន្ទាល់របស់លោកបានរឹងមាំឡើងទោះបីជាមានការប្រឆាំងក្ដី ។

លោកមានប្រសាសន៍ថា « ខ្ញុំគឺជាសមាជិកតែម្នាក់ឯងគត់នៅក្នុងសាលារៀនរបស់ខ្ញុំ ហើយក្មេងប្រុសផ្សេងទៀតតែងតែព្យាយាមល្បួងខ្ញុំឲ្យធ្វើខុស ហើយទាញខ្ញុំឲ្យធ្វើអ្វីដែលមិនត្រឹមត្រូវ ។ ខ្ញុំត្រូវតែរៀនការពារខ្លួនខ្ញុំនៅក្នុងឧបសគ្គទាំងនេះ ប៉ុន្តែខ្ញុំតែងតែទុកចិត្តលើព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់ខ្ញុំដើម្បីជួយខ្ញុំឲ្យជោគជ័យ ។ ខ្ញុំបានរៀនក្នុងនាមជាយុវជនម្នាក់ថា ប្រសិនបើអ្នកធ្វើផ្នែករបស់អ្នក នោះព្រះអម្ចាស់នឹងធ្វើផ្នែករបស់ទ្រង់ ។ ប៉ុន្តែអ្នកត្រូវតែកាន់ព្រះហស្តទ្រង់ និងដំណឹងល្អរបស់ទ្រង់ឲ្យជាប់ » ។





ពេលអូលីសេសអាយុ ១៥ ឆ្នាំ ប៊ីស្សពរបស់លោកបានសុំឲ្យលោកបង្រៀនថ្នាក់សាលាថ្ងៃអាទិត្យដល់យុវវ័យ ។ មេរៀនមួយដែលលោកបានបង្រៀន បានផ្តោតទៅលើការទទួលបានទីបន្ទាល់មួយអំពីដំណឹងល្អ ។ អូលីសេសបានសិក្សាព្រះគម្ពីរមរមន តែងតែទទួលអារម្មណ៍ថា សាសនាចក្រនេះពិត ហើយបានជឿលើព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។

នៅពេលលោកបានរៀបចំមេរៀន លោកចង់ថ្លែងទីបន្ទាល់យ៉ាងខ្លាំងដល់សិស្សក្នុងថ្នាក់របស់លោកអំពីសេចក្តីពិតដ៏ពោរពេញនៃដំណឹងល្អ ។ អែលឌើរសូរ៉េសរំឭកថា « ខ្ញុំបានសិក្សា ហើយអធិស្ឋានដោយស្មោះសរ ។ បន្ទាប់ពីខ្ញុំបានលុតជង្គង់ចុះរួច នោះមានអារម្មណ៍ដ៏ផ្អែមល្ហែមមួយផុសឡើងក្នុងចិត្តខ្ញុំ ជាសំឡេងតូចមួយដែលបានបញ្ជាក់ដល់ខ្ញុំថា ខ្ញុំនៅលើផ្លូវដែលត្រឹមត្រូវ ។ វាជាអារម្មណ៍ដ៏ខ្លាំងដែលខ្ញុំមិនអាចនិយាយថា ខ្ញុំពុំបានដឹងនោះឡើយ » ។

អែលឌើរសូរ៉េស « បានធំដឹងក្តីឡើងនៅក្នុងសាសនាចក្រដោយធ្វើតាមគំរូ » របស់ឪពុកម្តាយលោក អាបប៉ារេស៊ីដូ និង មែសេដេស សូរ៉េស ( ខាងឆ្វេង ) ។ នៅពេលសូរ៉េសបានទុកចិត្តលើព្រះអម្ចាស់ ទោះបីមានការប្រឆាំងក្តី ក៏លោកបានរៀនតាំងពីក្មេង ឲ្យកាន់ឲ្យខ្ជាប់ទៅនឹងព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ដែរ ។

នៅពេលអូលីសេសមានភាពចាស់ទុំ នោះលោកបានរៀនថា ប្រសិនបើលោកធ្វើកិច្ចការច្រើនជាងអ្វីដែលបានរំពឹងឲ្យលោកធ្វើ ឬសុំឲ្យធ្វើ នោះព្រះអម្ចាស់នឹងប្រទានពរដល់លោកដោយឥតកំណាញ់ឡើយ ។ មេរៀនមួយបែបនោះបានកើតឡើង នៅពេលលោកបានរៀបចំទៅបេសកកម្ម ។ អំឡុងពេលសម្ភាសជាមួយអូលីសេស ប៊ីស្សពរបស់លោកបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការគោរពតាមបទបញ្ញត្តិ និងការរស់នៅដោយភាពសក្តិសម ។ គាត់ក៏បានសង្កត់ធ្ងន់លើការរៀបចំខាងហិរញ្ញវត្ថុផងដែរ ។

សព្វថ្ងៃនេះ អ្នកផ្សព្វផ្សាយសាសនាទាំងអស់មកពីប្រទេសប្រេស៊ីលបរិច្ចាគចំណាយបេសកកម្មរបស់ពួកគេជាមួយនឹងការបរិច្ចាគមកពីក្រុមគ្រួសារជាច្រើនលើចំណាយទាំងអស់ ។ នៅពេលអូលីសេសឈានដល់អាយុបម្រើបេសកកម្ម នោះលោកបានសម្រេចចិត្តថា លោកចង់រកប្រាក់ទាំងអស់ដែលចាំបាច់សម្រាប់បេសកកម្មរបស់លោក ។ ដោយចាប់យកប្រយោជន៍នៃសីលធម៌ការងារខ្ពស់ នោះលោកបានរៀនធ្វើការនៅក្នុងអាជីវកម្មតូចមួយរបស់ឪពុកលោក ហើយមានជំនាញក្នុងការវាយអត្ថបទកុំព្យូទ័របានលឿន នោះអូលីសេសបានរកឃើញការងារប្រចាំថ្ងៃមួយដោយជួយក្រុមហ៊ុនរៀបចំបញ្ជីប្រាក់ខែបុគ្គលិក ។

បន្ទាប់ពីប្រឡងជាប់នូវការប្រឡងចូលដ៏លំបាកមួយមក លោកបានចាប់ផ្តើមសិក្សាផ្នែកគណនីនៅវិទ្យាល័យឯកទេសមួយនៅពេលល្ងាច ។ រៀងរាល់ខែ បន្ទាប់ពីថ្វាយដង្វាយមួយភាគក្នុងដប់រួច លោកបានសន្សំប្រាក់សម្រាប់បេសកកម្ម ។ មួយឆ្នាំក្រោយមក លោកត្រូវបានប្តូរទៅផ្នែកគណនីនៅក្នុងក្រុមហ៊ុនរបស់ឪពុកលោក ។

អែលឌើរសូរ៉េសថ្លែងថា « នោះគឺជារបៀបដែលខ្ញុំបានសន្សំប្រាក់បង់ថ្លៃបេសកកម្មរបស់ខ្ញុំ ។ រៀងរាល់ខែអំឡុងពេលបីឆ្នាំ ពីមុនខ្ញុំ

រូបភាពផ្ទៃខាងក្រោយមកពី GETTY IMAGES

ចេញបេសកកម្ម នោះខ្ញុំទិញតវ៉ាន់ដែលខ្ញុំត្រូវការ — អាវមួយ, ខោមួយ, ស្រោមជើងមួយគូ ក្រវ៉ាត់កមួយ និងវ៉ាលីមួយ » ។ លោកក៏ត្រូវការ ហើយបានទទួលសេចក្ដីស្រឡាញ់ និងការគាំទ្រយ៉ាងខ្លាំងពីឪពុកម្ដាយរបស់លោក និងថ្នាក់ដឹកនាំក្នុងមូលដ្ឋានផងដែរ ។

អូលីសេសត្រូវបានហៅឲ្យបម្រើនៅបេសកកម្ម ប្រេស៊ីល រីយ៉ូ ដេ ចានេរូ ។ លោកបានបម្រើផ្នែកដំបូងនៃបេសកម្មរបស់លោកក្រោមការដឹកនាំរបស់ប្រធាន ហេលីអូ ដា រ៉ូឆា កាម៉ាហ្គូ ដែលក្រោយមក គាត់បានក្លាយជាអ្នកមានសិទ្ធិអំណាចទូទៅដំបូងគេដែលត្រូវបានហៅពីប្រទេសប្រេស៊ីល ។ អូលីសេសបានចាប់ផ្ដើមបេសកកម្មរបស់លោកនៅដើមឆ្នាំ ១៩៧៨ ។ ក្រោយមក ព្រះវិហារបរិសុទ្ធដំបូងគេនៅអាមេរិកឡាទីនត្រូវបានឧទ្ទិសឆ្លងនៅឆ្នាំនោះនៅទីក្រុង សៅ ប៉ូឡូ ដោយប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល ( ១៨៩៥–១៩៨៥ ) ។

នៅខែ មករា ឆ្នាំ ១៩៨០ អូលីសេស និងដៃគូរបស់លោក ដែលពុំទាន់បានទទួលអំណោយទានពិសិដ្ឋរបស់គាត់ដែរនោះ បានជិះឡានក្រុងនៅ រីយ៉ូ ដេ ចានេរូ រយៈពេលប្រាំបីម៉ោងទៅកាន់ព្រះវិហារបរិសុទ្ធ សៅ ប៉ូឡូ ប្រេស៊ីល ។ ឪពុកម្ដាយ និងបងប្អូនបង្កើតរបស់អូលីសេសបានជួបលោកនៅទីនោះ ហើយក្រុមគ្រួសារសូរ៉េសបានផ្សារភ្ជាប់សម្រាប់គ្រានេះ និងអស់កល្បជានិច្ច ។ អូលីសេសពុំភ្លេចពេលវេលានៅជាមួយគ្នាទាំងប្រាំម៉ោងនោះនៅក្នុងព្រះវិហារបរិសុទ្ធ សៅ ប៉ូឡូ ឡើយ ។ ក្រោយមកនៅថ្ងៃដដែលនោះ លោក និងដៃគូរបស់លោកបានត្រឡប់ទៅតំបន់បេសកកម្មវិញ ។

**ទុកព្រះជាទីមួយ**

អូលីសេសបានរីករាយនឹងបេសកកម្មដ៏ជោគជ័យ ដែលបានពង្រឹងទីបន្ទាល់របស់លោកបន្ថែមទៀត ។ នៅពេលលោកត្រឡប់ទៅផ្ទះវិញ លោកបានរកការងារធ្វើ ហើយចាប់ផ្ដើមសិក្សាគណនី និងសេដ្ឋកិច្ចនៅឯសាកលវិទ្យាល័យមួយក្នុងមូលដ្ឋាន ។

គាត់បានមកដល់ផ្ទះវិញប្រហែលជាប្រាំពីរខែ នៅពេលលោកបានជួប « ស៊ីស្ទើរម៉ហ្គាដូ » នៅឯកម្មវិធីរាំពហុស្ដេកមួយ ។ អូលីសេសបានបម្រើជាអ្នកដឹកនាំតំបន់របស់ស៊ីស្ទើរម៉ហ្គាដូអស់មួយរយៈ ហើយពួកលោកទាំងពីរនាក់បានចំណាយពេលល្ងាចនោះជជែកគ្នា និងចែកចាយរឿងនានាមកពីបេសកកម្ម ។ បីសប្ដាហ៍ក្រោយមក ពួកលោកបានចាប់ផ្ដើមដើរលេងជាគូ ។

រ៉ូសាណា ហ្វើរណាដេស ម៉ហ្គាដូ មានអាយុប្រាំបីឆ្នាំ ពេលបងស្រីរបស់គាត់ឈ្មោះម៉ាហ្គារ៉េត បានចាប់ផ្ដើមយកគាត់ទៅព្រះវិហារ ។ ទីបំផុត សាសនាគន់ការីក្មេងៗដ៏ស្មោះត្រង់ទាំងពីរនោះបានទទួលការអនុញ្ញាតពីឪពុករបស់ពួកគេឲ្យជ្រមុជទឹក ប៉ុន្តែ







អែលឌើរសូរ៉េសសរសើររ៉ូសាណាភរិយារបស់លោកនូវពាក្យថា « ជាអ្វីៗទាំងអស់ដែលល្អនៅក្នុងជីវិតខ្ញុំ » ។ គូស្វាមីភរិយាបានរៀបការនៅឆ្នាំ ១៩៨២ ( ខាងស្ដាំដៃគេផុត ) គឺពីរឆ្នាំបន្ទាប់ពីមានឱកាសជួបគ្នាក្រោយពីការបម្រើរបស់ពួកលោកនៅក្នុងបេសកម្មប្រេស៊ីល រីយ៉ូ ដេ ចានេរូ ។

អែលឌើរសូរ៉េសជាមួយរ៉ូសាណាក្នុងឆ្នាំ ២០០០ ( ខាងលើ ) ជាមួយគ្រួសាររបស់លោក ( ខាងក្រោមបន្តិចនៅខាងស្ដាំ ) និងជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្នុងឆ្នាំ ១៩៧៩ ( ខាងលើខាងស្ដាំ ) ជាមួយសមាជិកថ្មី អ៊ីលីស្ស៊ើរ វ៉ាហ្គនើរ ឌី សូស្សា សាន់តុស និងរ៉េជីណាដែលកាលនោះគឺជាគូដណ្ដឹងរបស់លោក ( ឥឡូវនេះជាភរិយា ) ។ បច្ចុប្បន្ននេះ បងប្រុសសាន់តុសបម្រើជាប្រធានស្ដេក វីឡា វេលហាប្រេស៊ីល នៅក្នុងរដ្ឋ អ៊ីស្ពីរីតូ សាន់តូ ។ គីម ភីកខែត ដៃគូរបស់អែលឌើរសូរ៉េសបង្ហាញនៅក្នុងរូបភាពផ្ទៃខាងក្រោយ ។

ពួកគេម្នាក់ៗត្រូវរង់ចាំរហូតដល់ពួកគេមានអាយុ ១៧ ឆ្នាំសិន ។ រ៉ូសាណាបានចូលរួមព្រះវិហារអស់រយៈពេលប្រាំបួនឆ្នាំ ពីមុនបានទទួលការអនុញ្ញាតឲ្យជ្រមុជទឹក ។

អូលីសេសបានរស់នៅទីក្រុង សៅ ប៉ូឡូ ភាគខាងជើង ហើយរ៉ូសាណាបានរស់នៅជាមួយឪពុកម្ដាយគាត់នៅផ្នែកខាងត្បូងនៃទីក្រុងនោះ ។ ការធ្វើដំណើរឆ្លងកាត់ទីក្រុងដ៏ធំនេះត្រូវចំណាយពេលពីរទៅបីម៉ោងដោយជិះឡានក្រុង និងរថភ្លើងផ្លូវក្រោមដី ។ សំណាងល្អណាស់ ម៉ាហ្គារ៉េត និងស្វាមីរបស់គាត់ ក្លូឌីអូ រស់នៅក្បែរផ្ទះរបស់ឪពុកម្ដាយនាង ។

អែលឌើរ ក្លូឌីអូ អរ អែម កូស្តា ជាពួកចិតសិបនាក់ដែលមានសិទ្ធិអំណាចទូទៅដែលជាអនាគតបងប្រុសថ្លៃរបស់លោកបានរំឭកថា « នៅពេលអូលីសេសមកដើរលេងជាគូជាមួយរ៉ូសាណានៅចុងសប្ដាហ៍ វាពិបាកសម្រាប់គាត់ត្រឡប់ទៅផ្ទះវិញដែលនៅឆ្ងាយនៅពេលយប់ ។ ដូច្នេះ គាត់ និងម៉ាហ្គារ៉េតបានអញ្ជើញអូលីសេសឲ្យស្នាក់នៅផ្ទះរបស់ពួកគេនាពេលយប់បន្ទាប់ពីដើរលេងជាគូនោះ » ។ អែលឌើរកូស្តាបន្ថែមថា « យើងបានយកគាត់មកចិញ្ចឹមមួយរយៈ » ។

ស៊ីស្ទើរកូស្តានិយាយថា « គាត់បានសម្រាកលើសាឡុងក្នុងបន្ទប់ទទួលភ្ញៀវរបស់យើង ។ យើងទើបតែរៀបការ ដូច្នេះយើងគ្មានភួយនៅសល់ទេ ។ ប៉ុន្តែគាត់បានយកវាំងននចាស់របស់យើងមកដណ្ដប់ ។ លោកសប្បាយចិត្ត ដោយសារលោកអាចជួបរ៉ូសាណាម្ដងទៀតនៅថ្ងៃបន្ទាប់ ។ គាត់មានចិត្តល្អចំពោះប្អូនស្រីខ្ញុំណាស់ ហើយឪពុកម្ដាយរបស់ខ្ញុំចូលចិត្តគាត់ខ្លាំងណាស់ » ។

អូលីសេស និងរ៉ូសាណាបានរៀបការនៅព្រះវិហារបរិសុទ្ធ សៅ ប៉ូឡូ ប្រេស៊ីល នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៨២ ។

ប្រសិនបើអ្នកចំណាយពេលពីរបីនាទីជាមួយអែលឌើរ និងស៊ីស្ទើរសូរ៉េស នោះអ្នកនឹងឃើញសេចក្ដីស្រឡាញ់ ការកើតសរសើរ និងការគោរពចំពោះគ្នាទៅវិញទៅមករបស់

ពួកលោកទាំងពីរភ្លមៗ ។ សម្រាប់អែលឌើរសូរ៉េស នោះរ៉ូសាណា « គឺជាគំរូមួយនៃសេចក្តីល្អ សេចក្តីស្រឡាញ់ និងការលះបង់ខ្ពស់ចំពោះព្រះអម្ចាស់សម្រាប់ខ្ញុំ និងគ្រួសារខ្ញុំ » ។[៣] សម្រាប់ស៊ីស្ទើរសូរ៉េស នោះអូលីសេសគឺជា « អំណោយមួយមកពីស្ថានសួគ៌ » ។

ស៊ីស្ទើរសូរ៉េសបន្ថែមដូច្នេះ ៖ « លោកតែងតែងទទួលខុសត្រូវ និងសុចរិតយ៉ាងខ្លាំង លោកមើលថែគ្រួសាររបស់យើងបានល្អជានិច្ច ហើយលោកប្រព្រឹត្តល្អចំពោះខ្ញុំជានិច្ច ។ នៅក្នុងគ្រប់ការហៅបម្រើទាំងអស់របស់លោកក្នុងសាសនាចក្រ លោកបានធ្វើវាដោយអស់ពីសមត្ថភាពរបស់លោក ។ លោកចេញទៅ ហើយធ្វើកិច្ចការទាំងនោះ ។ លោកដាក់កិច្ចការរបស់ព្រះជាដំបូងនៅក្នុងជីវិតរបស់លោកជានិច្ច ។ ខ្ញុំបានធ្លាក់ក្នុងអន្លង់ស្នេហ៍លើលោកកាន់តែខ្លាំងឡើងៗ ដោយសារខ្ញុំដឹងថា ប្រសិនបើលោកដាក់កិច្ចការរបស់ព្រះជាដំបូងគេ នោះលោកក៏នឹងដាក់ខ្ញុំជាដំបូងផងដែរ » ។

អែលឌើរសូរ៉េសថ្លែងអំពីភរិយារបស់លោកដូច្នេះ ៖ « ភរិយាខ្ញុំពិតជាវីរៈនារី និងជាការបំផុសគំនិតនៅក្នុងគ្រួសាររបស់យើង ។ គាត់មានក្តីស្រឡាញ់ មានចិត្តល្អ និងអត់ធ្មត់ជាមួយមនុស្សគ្រប់រូប ។ គាត់រួបរួមសាមគ្គីគ្រួសារយើងគាត់មើលឃើញសេចក្តីល្អនៅក្នុងមនុស្សគ្រប់រូប ។ គាត់បានរួមចំណែកយ៉ាងខ្លាំងដល់អ្វីដែលបានកើតឡើងក្នុងជីវិតរបស់ខ្ញុំ ។ ស្តីពីការហៅរបស់ខ្ញុំទៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ខ្ញុំនិយាយលេងប្រាប់គាត់ថា ‹ នេះជាកំហុសរបស់អូន ដោយសារអូនបានបង្កើនអំណាចនៃដំណឹងល្អយ៉ាងខ្លាំងក្លានៅក្នុងជីវិតរបស់បង › » ។



## ចិត្តល្អសប្បុរស

ហ្គូស្តាវ៉ូកូនច្បងបង្អស់របស់គ្រួសារសូរ៉េស ចាំពីយប់មួយកាលនៅក្មេង ពេលគាត់មិនស្តាប់តាមឪពុកម្តាយរបស់គាត់ ហើយដោយគ្មានការអនុញ្ញាត គាត់បានទៅមើលពិធីអបអរសាទរប្រចាំឆ្នាំនៅក្នុងទីក្រុងជិតខាង សៅ ប៉ូឡូ របស់ពួកគេដែលហៅថា បុណ្យ ហ្វេសស្តា ហុនីណា ។

គាត់និយាយថា « ខ្ញុំកំពុងនៅកណ្តាលហ្វូងមនុស្សដ៏ធំមួយកំពុងតែសប្បាយរីករាយ ពេលខ្ញុំបានឮអ្នកប្រកាសហៅឈ្មោះខ្ញុំឲ្យទៅខាងមុខ ។ នៅពេលនោះខ្ញុំបានឃើញឪពុករបស់ខ្ញុំ » ។

ឪពុកម្តាយរបស់គាត់បារម្ភពីគាត់ខ្លាំងណាស់ ប៉ុន្តែជាជាងការជេរស្តីឲ្យហ្គូស្តាវ៉ូ នោះសូរ៉េសបានឱបគាត់យ៉ាងណែន ។

ហ្គូស្តាវ៉ូបានរំឭកថា « យើងបាននិយាយគ្នាយ៉ាងម៉ឺងម៉ាត់អំពីការបាត់រូបខ្ញុំ ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំបានប្រព្រឹត្តដាក់ខ្ញុំដោយការគោរព ។ ខ្ញុំមានអារម្មណ៍ថា បានទទួលការការពារ ហើយខ្ញុំដឹងថា ពួកលោកពិតជាស្រឡាញ់ខ្ញុំណាស់ » ។

សូរ៉េសមានការលះបង់ចំពោះគ្រួសាររបស់លោក ។ ទោះបីជាមានការងារ និងកាលវិភាគធ្វើដំណើរដ៏មមាញឹកអស់ជាច្រើនឆ្នាំក្តី លោកបានញែកពេលវេលាដើម្បីស្ថាបនាទំនាក់ទំនងជាមួយកូនៗរបស់លោក ។

នៅពេលអែលឌើរសូរ៉េសត្រូវបានគាំទ្រឲ្យបម្រើក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៨ ប្រហែលជាគ្មាននរណាម្នាក់ដែលភ្ញាក់ផ្អើលជាងហ្គូស្តាវ៉ូ និងប្អូនស្រីទាំងពីររបស់គាត់គឺលេស្ស៊ីសៀ ខារ៉ាវ៉េឡូ និង ណាថាលៀ សូរ៉េស អាវីឡា ឡើយ ។ ប៉ុន្តែប្រសិនបើសេចក្តីស្រឡាញ់ ការខិតខំធ្វើការ សេចក្តីអាណិតអាសូរ និងសេចក្តីរាបទាបសក្តិសមឲ្យបុគ្គលម្នាក់ធ្វើជាសាវក នោះពួកគេនិយាយថា ពួកគេអាចយល់ពីមូលហេតុដែលព្រះអម្ចាស់បានហៅឪពុករបស់ពួកគេ ។

លេស្ស៊ីសៀនិយាយថា « នៅពេលព្រះយេស៊ូវបានហៅសាវករបស់ទ្រង់ នោះទ្រង់ពុំបានរើសពួកផារិស៊ីដែលមានចំណេះដឹងខ្លាំងនោះទេ ទ្រង់បានរើសយកអ្នកនេសាទត្រីវិញ ។ ឪពុក និងម្តាយរបស់ខ្ញុំគឺដូចនោះផងដែរ ។ ពួកលោកទុកចិត្តលើព្រះអម្ចាស់ទាំងស្រុង ហើយទ្រង់ប្រើពួកលោកដើម្បីបំពេញកិច្ចការរបស់ទ្រង់ ដោយសារទ្រង់ជ្រាបដឹងថា ពួកលោកគ្មានភាពអត្មានិយម មានឆន្ទៈខិតខំធ្វើការ និងរាបសាល្មមដើម្បីទទួលការកែតម្រូវ » ។

ណាថាលៀបន្ថែមថា « ចិត្តល្អសប្បុរស » របស់ឪពុកពួកគេនឹងជួយលោកនៅពេលលោកបានឆ្ពោះទៅមុខក្នុងនាមជាសាក្សីពិសេសម្នាក់របស់ព្រះអង្គសង្គ្រោះ ។ នាងនិយាយថា « លោកមានចិត្តអាណិតអាសូរគ្រប់គ្រាន់ដើម្បីធ្វើ



កិច្ចការនេះ ។ លោកទទួលអារម្មណ៍ពីព្រះចេស្ដាមកពីស្ថានសួគ៌ ហើយលោកស្រឡាញ់មនុស្សគ្រប់រូប ហើយចង់ធ្វើអ្វីដែលត្រឹមត្រូវ » ។

**« អ្វីៗគ្រប់យ៉ាងនឹងដំណើរការល្អ »**

នៅពេលអែលឌើរសូរ៉េសបម្រើជាប្រធានបេសកកម្ម ព័រទុយហ្គាល ព័រតូ ពីឆ្នាំ ២០០០ ដល់ ២០០៣ មានគេស្គាល់លោកច្រើនដោយការប្រើឃ្លាជាភាសាព័រទុយហ្គាល់ថា « Tudo vai dar certo » — អ្វីៗគ្រប់យ៉ាងនឹងដំណើរការល្អ ។

ធី បិនណែត អ្នកផ្សព្វផ្សាយសាសនាម្នាក់របស់លោកបានរំឭកថា « លោកបានបង្រៀនឃ្លានេះដល់យើង ។ លោកបានរស់នៅដោយមានសេចក្ដីជំនឿ និងសុទិដ្ឋិនិយមដែលថា ប្រសិនបើយើងធ្វើអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងធ្វើ នោះអ្វីៗគ្រប់យ៉ាងនឹងដំណើរការល្អ » ។

រីឆាដ ស្មៀដ អ្នកផ្សព្វផ្សាយសាសនាម្នាក់ទៀតរបស់លោកនិយាយថា លោកក៏បានបង្រៀនអ្នកផ្សព្វផ្សាយសាសនារបស់លោកកុំឲ្យប្រើពាក្យ *ពិបាក* ឬ *មិនអាចធ្វើបាន* ឡើយ ។ « យើងហៅរឿងផ្សេងៗថាជា ‹ ឧបសគ្គ › ។ ការទូន្មាននោះបានជួយសម្រួចសម្រាំងជីវិតរបស់ខ្ញុំ នៅពេលខ្ញុំបានមើលទៅរឿងផ្សេងៗថាជា ‹ ឧបសគ្គ › ដើម្បីយកឈ្នះលើ ជាជាងមើលឃើញវាថាជារឿងដែល ‹ ពិបាក › ឬ ‹ មិនអាចធ្វើបាន › » ។



សេចក្ដីជំនឿ និងសុទិដ្ឋិនិយមបែបនោះពុំកើតឡើងមកពីជីវិតដែលងាយស្រួលឡើយ ។ អែលឌើរ និងស៊ីស្ទើរសូរ៉េសស្គាល់ច្បាស់អំពីការខកចិត្តនៃការឈានទៅមុខដោយគ្មានការងារធ្វើ និងការហត់នឿយនឹងការងារ និងការសិក្សាពេញមួយថ្ងៃ ការធ្លាក់ខ្លួនឈឺ និងការខូចចិត្តមកពីការរលូតកូន កូនស្លាប់ក្នុងផ្ទៃ និងការស្លាប់បងប្អូនបង្កើត និងឪពុកម្ដាយ ។

ប៉ុន្តែតាមរយៈដំណើរជីវិត ពួកលោកបានដាក់សេចក្ដីជំនឿរបស់ពួកលោកលើពាក្យនៃខគម្ពីរដែលអែលឌើរសូរ៉េសពេញចិត្ត ៖ « ចូរមានចិត្តរាបសា ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងដឹកដៃអ្នក ហើយប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយរបស់អ្នក » ។[៤]

អែលឌើរសូរ៉េសថ្លែងថា « ឧបសគ្គគឺជាផ្នែកនៃការរីកចម្រើនរបស់យើង ។ ប៉ុន្តែនៅពេលយើងអត់ធ្មត់នៅក្នុងការរងទុក្ខ នៅពេលយើងរៀនរស់នៅក្នុងឧបសគ្គជីវិត នៅពេលយើងបន្តស្មោះត្រង់ នោះព្រះអម្ចាស់កោតសរសើរ និងប្រទានពរដល់យើងនូវពរជ័យដែលទ្រង់បានសន្យា » ។

លោកបន្ថែមទៀតថា ហើយនៅពេលយើងកាន់ដំបងដែកយ៉ាងខ្ជាប់ខ្ជួន នោះព្រះអម្ចាស់នឹងពុំបោះបង់យើងឲ្យនៅឯកោឡើយ ។

អែលឌើរសូរ៉េសថ្លែងទីបន្ទាល់ថា « ការកាន់ខ្ជាប់ទៅនឹងបទបញ្ញត្តិ ដំណឹងល្អ ព្រះគម្ពីរ និងព្រះអម្ចាស់យេស៊ូវគ្រីស្ទយ៉ាងខ្ជាប់ខ្ជួន ជួយយើងឲ្យយកឈ្នះលើឧបសគ្គជីវិត ។ នៅពេលយើងលុតជង្គង់អធិស្ឋាន នោះទ្រង់នឹងគង់នៅជាមួយយើង ហើយទ្រង់នឹងដឹកនាំយើង ។ ទ្រង់នឹងបំផុសគំនិតយើងអំពីកន្លែងដែលត្រូវទៅ និងអ្វីដែលត្រូវធ្វើ ។ នៅពេលយើងគោរពប្រតិបត្តិ និងបន្ទាបខ្លួនយើង នោះព្រះអម្ចាស់ឆ្លើយតបការអធិស្ឋានរបស់យើង » ។

**សិស្សដែលមានការលះបង់**

អូលីសេស សូរ៉េស គឺជាបុរសម្នាក់ដែលមានសមត្ថភាព និងការរៀបចំ ។ ការអប់រំរបស់លោកដែលរួមមានកម្រិតអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម បានរៀបចំលោកឲ្យធ្វើការជាគណនេយ្យករ និងសវនករសម្រាប់ក្រុមហ៊ុនចម្រុះជាតិនៅប្រទេសប្រេស៊ីល ។ បទពិសោធន៍នោះបានរៀបចំលោកឲ្យធ្វើការនៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុរបស់សាសនាចក្រ ដែលបានរៀបចំលោកនៅវ័យ ៣១ ឆ្នាំ ឲ្យក្លាយជានាយកផ្នែកកិច្ចការអាណាចក្រម្នាក់ក្នុងវ័យដ៏ក្មេងបំផុតរបស់សាសនាចក្រ ។ ការរៀបចំនោះក៏បានជួយលោកឲ្យធ្វើជាប្រធានបេសកកម្មម្នាក់ដ៏ល្អ និងជួយការហៅរបស់លោកក្នុងនាមជាពួកចិតសិបនាក់មានសិទ្ធិអំណាចទូទៅនៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៥ ។

ពីមុនការហៅឲ្យបម្រើនៅក្នុងគណៈប្រធាននៃពួកចិតសិបនាក់នៅថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១៣ អែលឌើរសូរ៉េសបានបម្រើជាទីប្រឹក្សា ហើយក្រោយមកបានបម្រើជាប្រធាននៃគណៈប្រធានតំបន់នៃប្រទេសប្រេស៊ីល និងជាទីប្រឹក្សានៅក្នុងគណៈប្រធានតំបន់អាហ្វ្រិកប៉ែកអាគ្នេយ៍ ។ នៅទីនោះ លោកបានបម្រើជាទីប្រឹក្សារបស់



អែលឌើរ ឌេល ជី រេនឡាន់ ដែលកាលនោះនៅបម្រើជាពួកចិតសិបនាក់មានសិទ្ធិអំណាចទូទៅ ។ អែលឌើររេនឡាន់ ដែលឥឡូវនេះគឺជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់មានពេលដ៏រីករាយជាមួយគ្នា ។

អែលឌើររេនឡាន់ថ្លែងថា « អែលឌើរសូរ៉េសគឺជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទដែលរីករាយ មានការតាំងចិត្ត និងមានការលះបង់ ។ ខ្ញុំពុំស្គាល់នរណាដែលទទួលអារម្មណ៍យ៉ាងមោះមុតថា លោកកំពុងធ្វើធុរកិច្ចរបស់ព្រះអម្ចាស់ឡើយ ។ ប្រសិនបើលោកត្រូវបានស្នើសុំឲ្យធ្វើអ្វីមួយ នោះលោកនឹងធ្វើវាដោយអស់ពីពលំរបស់លោក » ។

លោកបានថ្លែងថា អែលឌើរសូរ៉េសបាន « ធ្លាក់អន្លង់ស្នេហ៍ » ជាមួយនឹងពួកបរិសុទ្ធនៅទ្វីបអាហ្វ្រិកលឿនណាស់ ។ ការចាត់តាំងដំបូងរបស់លោកនៅក្នុងតំបន់នោះគឺធ្វើជាអធិបតីលើ

មិនថានៅក្នុងចំណោមពួកបរិសុទ្ធនៃប្រទេសពេរ៉ូ ( ខាងឆ្វេង ), ប្រទេសហ្គាណា ( ខាងក្រោម ) ឬជាតិសាសន៍ដទៃទៀតដែលលោកបានបម្រើ និងធ្វើការងារបម្រើទេ អែលឌើរក្លូឌីអូ អរ អែម កូស្តា ថ្លែងថា អែលឌើរសូរ៉េស « ស្រឡាញ់មនុស្សយ៉ាងងាយ » ។






សន្និសីទស្តេកមួយនៅកាណាន់ហ្គា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។ អែលឌើររេនឡាន់មានប្រសាសន៍ថា « ពេលលោកត្រឡប់មកវិញ លោកពុំឈប់និយាយអំពីសេចក្ដីល្អ និងការលះបង់របស់មនុស្សដែលលោកបានជួបឡើយ » ។

អែលឌើរ អិល វិតនី ក្លេតុន ដែលបានបម្រើជាមួយអែលឌើរសូរ៉េសអស់រយៈពេលប្រាំឆ្នាំកន្លះនៅក្នុងគណៈប្រធានពួកចិតសិបនាក់ហៅអែលឌើរសូរ៉េសថាជា អ្នកជួយបង្កើតឲ្យមានកិច្ចព្រមព្រៀង ។ « លោកស្ដាប់ និងពិចារណាគំនិតរបស់លោក ។ លោកមានការយកចិត្តទុកដាក់លើរបៀបដែលលោកប្រព្រឹត្តខ្លួនលោកនៅក្នុងការប្រជុំនានា ដូច្នេះសំឡេងរបស់យើងបង្កើតបានជាសំឡេងបន្សុះបន្សំគ្នាមួយ ជាជាងសំឡេងតែមួយដែលប្រកួតប្រជែងគ្នា ។

ទោះបីជាមានការងារ និងកាលវិភាគធ្វើដំណើរដ៏មមាញឹកអស់ជាច្រើនឆ្នាំក្ដី ក៏អែលឌើរសូរ៉េសបានដាក់ភរិយា កូនៗ និងចៅៗរបស់លោកមុនជានិច្ចនៅក្នុងជីវិតលោក ( ខាងក្រោមបន្តិចខាងឆ្វេង ) ។ លោកក៏បានឆ្លៀតពេលនៅជាមួយភរិយារបស់លោកដើម្បីក្លាយជាចុងភៅដ៏មានស្នាដៃម្នាក់ផងដែរ ( នៅខាងឆ្វេងដៃផុត ) ។

រូបថតជាមួយភរិយារ៉ូសាណានៅខាងមុខព្រះវិហារបរិសុទ្ធ សលត៍ លេក ដោយ គ្រីស្ទីន ម៉ាហ្វី *DESERET NEWS*

អែលឌើរសូរ៉េសមានការបន្ទាបខ្លួនអំពីសមត្ថភាពរបស់លោកក្នុងការទាក់ទងជាភាសាព័រទុយហ្គាល់, អង់គ្លេស, អេស្ប៉ាញ និងបារាំង ។ អែលឌើរក្លេតុនថ្លែងថា ប៉ុន្តែអំណោយទាននោះ ដែលតម្រូវឲ្យយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួនគឺជាពរជ័យមួយដល់សាសនាចក្រ ។ អែលឌើរសូរ៉េសអាចនិយាយទៅកាន់សមាជិកសាសនាចក្រក្នុងចំនួនយ៉ាងច្រើនជាភាសាផ្ទាល់របស់ពួកគេ ។

អែលឌើរ ក្លូឌីអូ កូស្តា បងប្រុសថ្លៃរបស់លោកសង្កេតឃើញថា « អូលីសេសគឺជាអ្នកដឹកនាំតាំងពីលោកនៅក្មេងម្ល៉េះ ។ លោកមានប្រាជ្ញា និងមានសមត្ថភាពណាស់ ហើយលោកទទួលអារម្មណ៍នៃការទទួលខុសត្រូវថា លោកត្រូវធ្វើឲ្យអស់ពីសមត្ថភាពរបស់លោកជានិច្ច ។ លោកស្រឡាញ់អ្នកដែលនៅជុំវិញលោកដោយងាយ ។ លោកមានដួងចិត្តជាសិស្សពិតរបស់ព្រះអង្គសង្គ្រោះ ហើយលោកមានទីបន្ទាល់រឹងមាំថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ ខ្ញុំស្រឡាញ់លោក ហើយខ្ញុំមានអំណរគុណក្នុងការគាំទ្រលោកឲ្យធ្វើជាសាវកនៃព្រះអម្ចាស់ » ។

ហើយអែលឌើរ ដេវីឌ អេ បែដណា ថ្លែងសម្រាប់កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបន្ថែមដូច្នេះ ៖ « អែលឌើរសូរ៉េសគឺបរិសុទ្ធគ្មានឧបាយកល និងជាសិស្សដ៏ស្លូតត្រង់របស់ព្រះអង្គសង្គ្រោះ ។ តាមរយៈពន្លឺនៅលើផ្ទៃមុខរបស់លោក ស្នាមញញឹមដ៏កក់ក្ដៅរបស់លោក និងអត្តចរិតដ៏រួសរាយរបស់លោក នោះបុគ្គលម្នាក់ៗ និងក្រុមគ្រួសាររាប់មិនអស់បាន កំពុងបាន ហើយនឹងទទួលការបំផុសគំនិតជាមួយនឹងបំណងប្រាថ្នាដ៏ធំធេង ក្នុងការធ្វើតាមព្រះអង្គសង្គ្រោះ ហើយរស់នៅតាមសិក្ខាបទនៃដំណឹងល្អរបស់ទ្រង់ » ។

នៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើង ព្រះអម្ចាស់មានបន្ទូលអំពីអែតវីត ប៉ាទ្រិច ថា « ចិត្តគាត់បរិសុទ្ធនៅចំពោះយើង ដ្បិតគាត់ដូចជា ណាថាណែល ពីបុរាណ ដែលឥតមានចិត្តឧបាយឡើយ » ។[៥] ព្រះអម្ចាស់មានបន្ទូលអំពី ហៃរុម ស៊្មីធ ថា « យើងជាព្រះអម្ចាស់ស្រឡាញ់គាត់ មកពីសេចក្ដីស្មោះនៃចិត្តរបស់គាត់ និងមកពីគាត់បានស្រឡាញ់នូវអ្វីដែលត្រឹមត្រូវចំពោះយើង » ។[៦]

ព្រះអម្ចាស់ក៏នឹងមានបន្ទូលដូចគ្នាអំពីអូលីសេស សូរ៉េសផងដែរ ។ ■

កំណត់ចំណាំ

១. យ៉ូហាន ១:៤៧ ។
២. សូមមើល ជេមស៍ អ៊ី ថាល់មេហ្គ *Jesus the Christ* ( ឆ្នាំ ១៩១៦ ) ទំព័រ ២១៧–២១៨, ២២២ ។
៣. « ពួកព្យាការីថ្លែងដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៨ ។
៤. គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១០ ។
៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១១ ។
៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៥ ។



# អ្វីដែលប៊ីស្សពគ្រប់រូបចង់ឲ្យសមាជិកវួដរបស់គាត់ដឹង

*នេះគឺជាសេចក្ដីពិតប្រាំបីយ៉ាងដែលខ្ញុំបានរៀន អំឡុងពេលការបម្រើរបស់ខ្ញុំក្នុងនាមជាប៊ីស្សព ។*

ដោយ ម៉ៃយែល មេយើរស៍

ខ្ញុំមានឱកាសដ៏អស្ចារ្យដើម្បីបម្រើជាប៊ីស្សព ។ អំឡុងពេលនៃឆ្នាំទាំងនោះ ខ្ញុំបានរៀនមេរៀនច្រើនជាងអ្វីដែលខ្ញុំអាចនិយាយបានទៅទៀត ។ ប៉ុន្តែខ្ញុំពិតជាបានរៀនសេចក្ដីពិតចំនួនប្រាំបីយ៉ាងដែលខ្ញុំជឿថា វាជារឿងសាកល ។ ទោះបីជាបញ្ជីនេះពុំត្រូវបានបញ្ចូលអ្វីៗទាំងអស់ក្ដី វាគឺជាការព្យាយាមរបស់ខ្ញុំក្នុងការចែកចាយអ្វីដែលប៊ីស្សពគ្រប់រូបសង្ឃឹមឲ្យសមាជិកវួដរបស់គាត់ដឹង ។

**១. ប៊ីស្សពស្រឡាញ់សមាជិកគ្រប់រូបក្នុងវួដរបស់គាត់នៅក្នុងរបៀបមួយដ៏ស្មោះស្ម័គ្រ ។**

សេចក្ដីស្រឡាញ់របស់ប៊ីស្សពមានចំពោះសមាជិកវួដរបស់គាត់គឺមានទំនាក់ទំនងទៅនឹងសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទមានចំពោះយើង ។ នៅពេលប៊ីស្សពមើលសមាជិកនៅក្នុងការប្រជុំសាក្រាម៉ង់ សេចក្ដីអាណិតអាសូរ និងការយល់ចិត្តសណ្ដិតមកលើគាត់ក្នុងរបៀបមួយមិនដូចជាអ្វីដែលគាត់ធ្លាប់មានបទពិសោធន៍ឡើយ ។ នៅពេលប៊ីស្សពក្រោកឡើង ហើយចែកចាយពីក្ដីស្រឡាញ់ដ៏ធំដែលគាត់មានចំពោះសមាជិកវួដ នោះអារម្មណ៍របស់គាត់គឺស្មោះត្រង់ និងពិតប្រាកដ ។ សូមដឹងថា ប៊ីស្សពរបស់អ្នកស្រឡាញ់អ្នក ខ្វល់ខ្វាយពីអ្នក និងមើលថែអ្នកជាងអ្វីដែលអ្នកដឹងទៅទៀត ។




**២. ប៊ីស្សពត្រូវបានគាំទ្រផ្នែករូបកាយ ផ្លូវចិត្ត និងខាងវិញ្ញាណដោយសេចក្ដីជំនឿ និងការអធិស្ឋានរបស់សមាជិក ។**

ប៊ីស្សពចំណាយពេលរាប់មិនអស់ក្នុងការបម្រើ ។ គាត់នឹងចំណាយពេលជាច្រើនម៉ោងនៅព្រះវិហារនៅថ្ងៃអាទិត្យ និងការទៅសួរសុខទុក្ខបន្ថែមទៀតនៅពេលយប់បន្ទាប់ពីការងារ សម្ភាស និងការមើលថែសមាជិកវួដរបស់គាត់ ។

ប៊ីស្សពអាចធ្វើកិច្ចការទាំងនេះពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ដោយសារសេចក្ដីជំនឿ និងការអធិស្ឋានរបស់សមាជិកវួដ ។ ក្នុងនាមជាប៊ីស្សពដែលទើបនឹងហៅថ្មី ខ្ញុំបានយំដោយមិនដឹងខ្លួនរាល់ពេលដែលខ្ញុំបានស្ដាប់ឮសមាជិកអធិស្ឋានថា « សូមប្រទានពរដល់ប៊ីស្សព » ។ ការអធិស្ឋានដោយសេចក្ដីជំនឿរបស់អ្នកគឺពិតជា ត្រូវបានឆ្លើយតប ហើយប៊ីស្សពទទួល និងមានអារម្មណ៍នៃឥទ្ធិពលគាំទ្រមកពីការអធិស្ឋានទាំងនោះ ។ ព្រះអម្ចាស់ឆ្លើយតាមការអធិស្ឋានដែលពោរពេញដោយសេចក្ដីជំនឿទាំងនោះទៅលើក្បាលរបស់ប៊ីស្សពនៃសាសនាចក្រ ។

**៣. ជារឿយៗ ប៊ីស្សពមានអារម្មណ៍ថាខ្វះសមត្ថភាពយ៉ាងខ្លាំងចំពោះការហៅបម្រើនោះ ( ទោះបីបន្ទាប់ពីបានហៅបម្រើអស់រយៈពេលបី ឬបួនឆ្នាំក្ដី ) ។**

ខ្ញុំបានស្គាល់ប៊ីស្សពមួយចំនួនតូចដែលមានអារម្មណ៍ថា ពួកគេពិតជាត្រូវបាន « រៀបចំ » សម្រាប់ការហៅបម្រើនេះ ។ ទោះជាយ៉ាងណាក្ដី ខ្ញុំដឹងថា « អ្នកដែលព្រះអម្ចាស់បានហៅ ព្រះអម្ចាស់នឹងធ្វើឲ្យគេសមនឹងកិច្ចការនោះ » ។[1] ទោះបីប៊ីស្សពដឹងថា គាត់ត្រូវបានធ្វើឲ្យសមនឹងកិច្ចការនោះក្ដី គាត់ក៏នៅតែមានអារម្មណ៍លំបាកថា គាត់នឹងមិនអាចធ្វើការហៅបម្រើនោះបានល្អឡើយ ។ គាត់នឹងប្រឹងអស់ពីសមត្ថភាពរបស់គាត់ដើម្បីផ្ដល់ការទូន្មានដ៏ឈ្លាសវៃនៅពេលចាំបាច់ ពុំធ្វើឲ្យមនុស្សអាក់អន់ចិត្ត ហើយងាយនឹងស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែគាត់នៅតែឆ្ងល់នៅគ្រានោះថា តើគាត់កំពុងបំពេញការហៅបម្រើរបស់គាត់គួរឲ្យទទួលយកបានដែរឬទេ ។

ស៊ុមរូបថតមកពី Getty Images

### ៤. ព្រះវិញ្ញាណនៃព្រះអាចធ្វើការតាមរយៈប៊ីស្សព នៅពេលគាត់ទូន្មានសមាជិកវួដ ។

នៅពេលគេសួរថា តើខ្ញុំនឹកអ្វីជាងគេបំផុតអំពីការបម្រើក្នុងនាមជាប៊ីស្សព នោះខ្ញុំប្រាប់គេថា ខ្ញុំនឹកនូវព្រះចេស្ដាដ៏ខ្លាំងក្លារបស់ព្រះវិញ្ញាណដែលកើតមានមកជាមួយនឹងសិទ្ធិអំណាចនៃប៊ីស្សព ។ មិនថាការលួងលោមដល់អស់អ្នកដែលមានមនុស្សជាទីស្រឡាញ់ស្លាប់ ការនិយាយជាមួយអស់អ្នកដែលកំពុងមានការលំបាកជាមួយស្វាមី ឬភរិយាដែលមិនស្មោះត្រង់ ឬការហៅមនុស្សឲ្យប្រែចិត្តក្ដី ព្រះវិញ្ញាណដែលមានចំពោះប៊ីស្សពដ៏ស្មោះត្រង់គឺជាព្រះវិញ្ញាណនៃព្រះ និងជាវិញ្ញាណនៃវិវរណៈ ។

ថ្មីៗនេះ ខ្ញុំមានអតីតសមាជិកវួដម្នាក់សូមឲ្យខ្ញុំជួយដោះស្រាយបញ្ហាផ្ទាល់ខ្លួនមួយចំនួនរបស់គាត់ ។ គាត់បានប្ដូរទៅរស់នៅវួដថ្មី ហើយពុំប្រាកដចិត្តថា តើគាត់ចង់ទៅជួបប៊ីស្សពថ្មីរបស់គាត់ដើម្បីសូមការណែនាំឬទេ ។ ខ្ញុំបានចែកចាយជាមួយគាត់នូវអ្វីដែលខ្ញុំបានចែកចាយជាច្រើនដងចាប់តាំងពីខ្ញុំបានដោះលែងដែលថា ទោះបីខ្ញុំរីករាយដើម្បីជួយក្ដី ខ្ញុំពុំកាន់កូនសោដែលប៊ីស្សពកាន់ឡើយ ហើយកូនសោទាំងនោះគឺជាកូនសោសំខាន់ដើម្បីផ្ដល់ការគាំទ្រដែលគាត់ត្រូវការ ។ ខ្ញុំបានផ្ដល់យោបល់ថា សូមឲ្យគាត់ទៅនិយាយជាមួយប៊ីស្សពគាត់ទៅ ។ ពីរសប្ដាហ៍ក្រោយមក ខ្ញុំបានទៅសួរសុខទុក្ខគាត់ ហើយគាត់បាននិយាយថា គាត់បានជួបជាមួយប៊ីស្សពគាត់ ហើយប៊ីស្សពនោះហាក់ដូចជាបានដឹងរួចទៅហើយនូវបញ្ហារបស់គាត់ និងរបៀបដើម្បីជួយគាត់យ៉ាងល្អបំផុត ។ ទោះប៊ីស្សពក៏អាចធ្វើខុស តែព្រះអម្ចាស់បំផុសគំនិតគាត់ ដឹកនាំគាត់ និងប្រទានពរដល់ជីវិតមនុស្សជាច្រើនតាមរយៈពាក្យសម្ដីរបស់គាត់ ។




### ៥. ប៊ីស្សពគឺជាមនុស្សលោក ជួនកាលគាត់ធ្វើខុស ហើយជួនកាលគាត់ធ្វើកិច្ចការខុសផងដែរ ។

ទោះបីការហៅបម្រើរបស់គាត់ជាប៊ីស្សពក្ដី ប៊ីស្សពគឺជាមនុស្សខាងសាច់ឈាម ។ ពួកគាត់មានភាពពុំគ្រប់លក្ខណ៍ ទន់ខ្សោយ លំអៀង និងមានបញ្ហាផ្ទាល់ខ្លួនរបស់ពួកគាត់ ។ ព្រះវិញ្ញាណធ្វើឲ្យបុរសដែលកាន់តំណែងប៊ីស្សពសក្ដិសម ប៉ុន្តែប៊ីស្សពនៅតែជាមនុស្សដែលទទួលរងនូវបញ្ហា និងភាពទន់ខ្សោយដូចដែលយើងទាំងអស់ជួបប្រទះផងដែរ ។

ការដឹងអំពីរឿងនេះពុំគួរកាត់បន្ថយការគោរពដែលយើងបង្ហាញដល់ការហៅបម្រើរបស់គាត់ ឬពុំស្ដាប់នូវអ្វីដែលគាត់ផ្ដល់ការទូន្មានឡើយ ។ ប៊ីស្សពដឹងយ៉ាងច្បាស់អំពីភាពទន់ខ្សោយរបស់គាត់ ហើយព្យាយាមយកឈ្នះវា ឬយ៉ាងហោចណាស់ទុកភាពទន់ខ្សោយទាំងនោះឲ្យនៅក្រៅពីការបម្រើរបស់គាត់ក្នុងនាមជាប៊ីស្សព ។ ទោះគាត់ព្យាយាមយ៉ាងណាក្ដី គាត់នៅតែពុំគ្រប់លក្ខណ៍ដែរ ។

### ៦. ប៊ីស្សពមានអារម្មណ៍ថា គាត់ពុំអាចឃើញសមាជិកវួដគ្រប់គ្រាន់ ឬធ្វើកិច្ចការនានាបានល្អគ្រប់គ្រាន់ទេ ។

រៀងរាល់ថ្ងៃប៊ីស្សពឆ្ងល់ថា តើនរណាទៀតដែលគាត់អាច ឬគួរតែជួយនៅថ្ងៃនោះ ។ ខ្ញុំចូលចិត្តទៅសួរសុខទុក្ខសមាជិកគ្រប់រូបជាញឹកញាប់ ប៉ុន្តែខ្ញុំមានការងារពេញម៉ោង គ្រួសារ កម្មវិធីយុវវ័យ និងសមាជិកវួដមួយចំនួនដែលមានតម្រូវការសំខាន់ៗ ។ ដូច្នេះខ្ញុំគ្មានពេលគ្រប់គ្រាន់ដើម្បីទៅជួបសមាជិកគ្រប់រូបញឹកញាប់នោះទេ ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងនាមជាប៊ីស្សព ជួនកាលព្រះវិញ្ញាណបំផុសគំនិតខ្ញុំឲ្យសួរសុខទុក្ខសមាជិកមួយចំនួនដែលកំពុងជួបការលំបាក ។ ជាច្រើនដង ការទៅសួរសុខទុក្ខទាំងនោះចាប់ផ្ដើមដោយពួកគេនិយាយថា « ខ្ញុំដឹងថា ប៊ីស្សពនឹងមក » ។ ជារឿយៗ យើងទទួលអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងលើសលុប នៅពេលយើងទាំងពីរនាក់ដឹងថា ការសួរសុខទុក្ខនោះគឺជាភស្ដុតាងថា ព្រះឆ្លើយតបការអធិស្ឋាន ។

ខ្ញុំក៏រីករាយនឹងការទទួលរាក់ទាក់ដែលខ្ញុំបានទទួលនៅផ្ទះនៃសមាជិកដែលសកម្ម « ដែលពុំមានការលំបាក » ទាំងនោះ ។ សមាជិកល្អៗទាំងនេះទៅព្រះវិហាររៀងរាល់សប្ដាហ៍ បម្រើយ៉ាងស្មោះត្រង់ក្នុងការហៅបម្រើ គ្មានឧបសគ្គធំដុំលេចធ្លោឡើង ហើយជាទូទៅថ្នាក់ដឹកនាំបព្វជិតភាពពុំទៅសួរសុខទុក្ខពួកគេជាទៀងទាត់ឡើយ ។ ពួកគេមានអំណរគុណដែលមានពេលជួបផ្ទាល់ជាមួយប៊ីស្សពរបស់ពួកគេ ។ ចំពោះបងប្អូនទាំងអស់គ្នា ខ្ញុំសូមនិយាយថា « សូមអរគុណ » ! សូមបន្តឆ្ពោះទៅមុខទៀត ! សូមដឹងថា ប៊ីស្សពរបស់អ្នកស្រឡាញ់អ្នក ហើយចង់ទៅសួរសុខទុក្ខឲ្យបានច្រើន ប្រសិនបើគាត់អាចធ្វើបាន ។

**៧. ប៊ីស្សពរបស់អ្នកពិតជាត្រូវការអ្នកដើម្បីផ្ដល់ការងារបម្រើដល់គ្នាទៅវិញទៅមក ។**

ក្នុងនាមជាប៊ីស្សព នៅពេលគេប្រាប់ខ្ញុំអំពីសមាជិកវួដម្នាក់ដែលជួបការលំបាក នោះខ្ញុំតែងតែសួរថា « តើនរណាគឺជាគ្រូបង្រៀនតាមផ្ទះ និងគ្រូសួរសុខទុក្ខតាមផ្ទះ ? » នេះគឺជារបៀបមួយនៃការប៉ាន់ប្រមាណថា តើតម្រូវការរបស់សមាជិកត្រូវបានបំពេញទាំងរយៈពេលខ្លី និងវែងដែរឬទេ ។ ប៊ីស្សពធ្វើកិច្ចការដោយគ្មានជំនួយពីសមាជិកវួដផ្សេងទៀតក្នុងវួដ និងស្ដេក នោះគាត់នឹងមានធនធានដែលមានដែនកំណត់ ។ ប្រាកដណាស់គាត់អាច — ហើយនឹង — ទៅសួរសុខទុក្ខសមាជិកដែលមានវិបត្តិ ។ ប៉ុន្តែជាមួយធនធានបព្វជិតភាព និងសមាគមសង្គ្រោះដែលមានសម្រាប់គាត់ នោះគាត់អាចពង្រីកការជួយរបស់គាត់ ។

នេះគឺជាការងារបម្រើ ។ មានគ្រាជាច្រើនដែលពួកយើងមួយចំនួនភ្លេចពីមូលហេតុដែលយើងផ្ដល់ការងារបម្រើដល់គ្នាទៅវិញទៅមក ៖ ព្រះអម្ចាស់បានត្រាស់បង្គាប់យើងឲ្យ « ស្រឡាញ់គ្នាទៅវិញទៅមក » ( យ៉ូហាន ១៣:៣៤ ) ។ សូមដឹងថា ប៊ីស្សពរបស់អ្នកប្រើប្រាស់ការងារបម្រើជាមធ្យោបាយមួយដ៏បំផុសគំនិតដើម្បី « កាន់តែមានវត្តមាន » នៅក្នុងជីវិតសមាជិកក្នុងវួដ ។







**៨. ប៊ីស្សពប្រាថ្នាថា គាត់អាចធ្វើកិច្ចការគ្រប់យ៉ាងដល់សមាជិករបស់គាត់ ។**

គ្រប់ពេលទាំងអស់ ទាំងថ្ងៃ ឬយប់ ទោះជាការប្រសិទ្ធពរបព្វជិតភាព ការទូន្មានដល់ក្មេងរឹងរូស ឬប្រញាប់ទៅកាន់កន្លែងគ្រោះថ្នាក់ក្តី ប៊ីស្សពចង់ធ្វើអ្វីៗទាំងអស់ដែលសមាជិកត្រូវការ ។ គាត់ពុំអាចធ្វើវាទាំងអស់ជានិច្ចនោះទេ ហើយគាត់ពុំអាចធ្វើជាមនុស្សដែលអាចដោះស្រាយរឿងគ្រប់ស្ថានភាពនោះទេ ប៉ុន្តែសូមកុំខ្លាចសូមជំនួយនៅពេលអ្នកត្រូវការឡើយ ។ សូមដឹងថា ប៊ីស្សពរង់ចាំបម្រើនៅគ្រប់ពេលទាំងនោះ ហើយអ្នកទាំងពីរទទួលពរយ៉ាងច្រើនសម្រាប់ការធ្វើការរួមគ្នា ។

ខ្ញុំមានចិត្តរាបទាបចំពោះឱកាសដ៏ពិសិដ្ឋដែលខ្ញុំមានដើម្បីបម្រើនៅក្នុងការហៅដ៏បរិសុទ្ធនេះ ។ នៅក្នុងការបម្រើរបស់ខ្ញុំ ខ្ញុំបានចាប់ផ្តើមជឿរហូតដល់ខ្ញុំបានដឹង ។ ខ្ញុំពុំគ្រាន់តែជឿថា ដំណឹងល្អគឺពិតឡើយ តែខ្ញុំដឹងថា ដំណឹងល្អពិត ។ ខ្ញុំពុំគ្រាន់តែជឿថា ព្រះស្គាល់ខ្ញុំឡើយ ប៉ុន្តែខ្ញុំដឹងថា ព្រះគឺពិតជាស្គាល់ពួកយើងម្នាក់ៗ ស្គាល់ជីវិតរស់នៅប្រចាំថ្ងៃ និងការលំបាកផ្ទាល់ខ្លួនរបស់យើង ។ លើសពីនោះទៀត ខ្ញុំដឹងថា ទ្រង់ធ្វើការតាមរយៈអ្នកបម្រើរបស់ទ្រង់ ជាពិសេសអស់អ្នកដែលកាន់កូនសោបព្វជិតភាព ។ ខ្ញុំដឹងថា ខ្ញុំពុំអាចបម្រើជាប៊ីស្សពដោយគ្មានជំនួយពីព្រះក្នុងកិច្ចការនេះបានឡើយ ។ វាគឺជាដំណឹងល្អដ៏ពោរពេញ និងសេចក្ដីស្រឡាញ់របស់ព្រះចំពោះបុត្រាបុត្រីរបស់ទ្រង់ដែលអាចឲ្យប៊ីស្សពគ្រប់រូបបម្រើ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*



**កំណត់ចំណាំ**

១. ថូម៉ាស អេស. ម៉នសុន « Duty Calls » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៤៤ ។


HOLY BIBLE



ជំពូក ៨

# ការកើតឡើងនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ

*នេះគឺជាជំពូកទី ៨ នៃនិទានកថាទាំងបួនភាគថ្មីអំពីប្រវត្តិសាសនាចក្រដែលមានចំណងជើងថា ពួកបរិសុទ្ធ ៖ រឿងអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយ ។ សៀវភៅនេះមានបោះពុម្ពជា ១៤ ភាសា នៅក្នុងវគ្គប្រវត្តិសាសនាចក្រនៃកម្មវិធី បណ្ណាល័យដំណឹងល្អ និងនៅគេហទំព័រ saints.lds.org ។ ជំពូកមុនៗត្រូវបានបោះពុម្ពនៅក្នុងច្បាប់ចេញផ្សាយកន្លងមក និងមានជា ៤៧ ភាសានៅក្នុងកម្មវិធី Gospel Library ( បណ្ណាល័យដំណឹងល្អ ) និងនៅលើអ៊ិនធើរណែតនៅគេហទំព័រ saints.lds.org ។*

នៅដើមខែ កក្កដា ឆ្នាំ ១៨២៨ ដោយមានអត្ថបទសរសេរដៃជាប់ជាមួយខ្លួន នោះយ៉ូសែប បានដឹងថា ព្រះអម្ចាស់បានមានព្រះទ័យចង់ឲ្យគាត់បោះពុម្ពព្រះគម្ពីរមរមន ហើយចែកចាយដំណឹងនេះឲ្យបានទូលំទូលាយ ។ ប៉ុន្តែគាត់ និងគ្រួសារគាត់ពុំសូវស្គាល់ក្រុមហ៊ុនបោះពុម្ពឡើយ ។ គាត់ត្រូវរក្សាសំណៅសរសេរដៃនោះឲ្យមានសុវត្ថិភាព ស្វែងរកក្រុមហ៊ុនបោះពុម្ព ហើយត្រូវធ្វើឲ្យសៀវភៅនេះមាននៅក្នុងដៃបណ្ដាជនណាដែលស្ម័គ្រចិត្តទទួលស្គាល់ថានេះគឺជាព្រះគម្ពីរថ្មី ។

ការបោះពុម្ពសៀវភៅដែលមានកម្រាស់ក្រាស់ដូចជាព្រះគម្ពីរមរមនគឺមិនមានតម្លៃថោកនោះទេ ។ ស្ថានភាពហិរញ្ញវត្ថុរបស់យ៉ូសែប ក៏មិនមានលក្ខណៈប្រសើរដែរ ចាប់តាំងពីគាត់បានចាប់ផ្ដើមធ្វើការបកប្រែ ហើយប្រាក់កាក់ដែលគាត់រកបានគឺត្រូវឧបត្ថម្ភដល់គ្រួសារគាត់ ។ ឪពុកម្ដាយរបស់គាត់ក៏មានស្ថានភាពដូចគ្នាដែរ ពួកគាត់នៅតែជាកសិករក្រីក្រខំធ្វើចម្ការនៅលើដីដែលជួលពីគេ ។ មិត្តភក្តិរបស់យ៉ូសែប តែម្នាក់គត់ ដែលអាចជួយផ្នែកហិរញ្ញវត្ថុបានគឺ ម៉ាទីន ហារិស ។

យ៉ូសែប ក៏រៀបផែនការធ្វើការងារនេះយ៉ាងឆាប់ហ័ស ។ ពីមុនគាត់បានបកប្រែរួចរាល់ គាត់បានដាក់ពាក្យស្នើសុំរក្សាសិទ្ធិសៀវភៅដើម្បីការពារអត្ថបទពីជនដែលមានចិត្តចង់លួច ឬ ថតចម្លង ។[១] ដោយមានជំនួយពីម៉ាទិន នោះយ៉ូសែប ក៏បានចាប់ផ្ដើមស្វែងរកហាងបោះពុម្ព ដែលយល់ព្រមបោះពុម្ពសៀវភៅនេះ ។

ដំបូងពួកគាត់បានទៅជួបលោក អិកប៊ឺឌ ហ្គ្រានឌីន ជាម្ចាស់ហាងបោះពុម្ពមួយនៅ ប៉ាលម៉ៃរ៉ា ដែលលោកមានអាយុស្របាលនឹងយ៉ូសែប ដែរ ។ លោកហ្គ្រានឌីន បានបដិសេធសំណើរនេះភ្លាមដោយគិតថា សៀវភៅនេះគឺក្លែងក្លាយ ។ ដោយគ្មានការបាក់ទឹកចិត្ត យ៉ូសែប និង ម៉ាទិន នៅតែបន្តស្វែងរក ហើយបានជួបនឹងហាងបោះពុម្ពមួយនៅក្រុងជិតនោះដែលយល់ព្រមទទួលយកការបោះពុម្ព ។ ប៉ុន្តែពីមុនយល់ព្រមនឹងហាងបោះពុម្ពនៅជិតទីក្រុងនេះ ពួកគាត់បានត្រឡប់ទៅប៉ាលម៉ៃរ៉ាវិញ ហើយបានសួរទៅលោកហ្គ្រានឌីន ម្ដងទៀត ក្រែងគាត់យល់ព្រមបោះពុម្ពសៀវភៅឲ្យ ។[២]

លើកនេះ លោកហ្គ្រានឌីន ហាក់ដូចជាមានចិត្តចង់ទទួលយកគម្រោងនេះ ប៉ុន្តែគាត់ចង់ឲ្យបង់ប្រាក់ ៣.០០០ ដុល្លារលើការបោះពុម្ព និងកិបជាសៀវភៅចំនួនប្រាំ ពាន់ក្បាលពីមុនគាត់ចាប់ផ្ដើមធ្វើការងារបោះពុម្ពនេះ ។ ម៉ាទិន

អូលីវើរ ខៅឌើរី តែងតាំង យ៉ូសែប ស្ម៊ីធ ដោយ វលធើរ រេន

បានសន្យាថា គាត់នឹងជួយបង់ថ្លៃបោះពុម្ព ប៉ុន្តែដោយសារចំនួនទឹកប្រាក់យ៉ាងច្រើនបែបនេះ នោះគាត់ចាប់ផ្តើមគិតថា គាត់ប្រហែលជាត្រូវបញ្ចាំកសិដ្ឋានរបស់គាត់ហើយ ។ វាជាបន្ទុកដ៏ធំលើម៉ាទិន ប៉ុន្តែគាត់បានដឹងថា គ្មានមិត្តភក្តិឯណាផ្សេងអាចជួយយ៉ូសែបរឿងលុយកាក់នេះទេ ។

ពេលជួបប្រទះនឹងបញ្ហា ម៉ាទិន ចាប់ផ្តើមព្រួយបារម្ភអំពីហិរញ្ញប្បទានបោះពុម្ពព្រះគម្ពីរមរមន ។ គាត់មានកសិដ្ឋានដ៏ល្អបំផុតនៅក្នុងភូមិ ។ ប្រសិនបើគាត់ដាក់ដីបញ្ចាំ គាត់អាចប្រថុយនឹងការបាត់បង់ដីរបស់គាត់ ។ ទ្រព្យសម្បត្តិដែលគាត់បានចំណាយពេលពេញមួយជីវិតរកបាននោះអាចនឹងត្រូវបាត់បង់ក្នុងមួយរំពេចភ្នែក ប្រសិនបើព្រះគម្ពីរមរមនលក់មិនដាច់ទេនោះ ។

ម៉ាទិន បានប្រាប់យ៉ូសែប អំពីកង្វល់របស់គាត់ ហើយបានសុំឲ្យយ៉ូសែបស្វែងរកវិវរណៈជូនគាត់ ។ ចម្លើយដែលបានទទួល គឺព្រះអម្ចាស់បានមានបន្ទូលអំពីពលិកម្មរបស់ទ្រង់ដើម្បីធ្វើតាមព្រះទ័យព្រះវរបិតា មិនថាត្រូវបង់ថ្លៃប៉ុណ្ណានោះទេ ។ ទ្រង់បានពិពណ៌នាអំពីទុក្ខវេទនាដ៏គ្មានទីបញ្ចប់ដែលទ្រង់បានទទួល ពេលដែលកំពុងអធិស្ឋានលោះថ្លៃអំពើបាប ដើម្បីមនុស្សទាំងអស់អាចប្រែចិត្ត និងទទួលបានការអភ័យទោស ។ បន្ទាប់មកទ្រង់បានបញ្ជាឲ្យម៉ាទិន លះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីនាំមកនូវផែនការរបស់ព្រះ ។

ព្រះអម្ចាស់បានមានបន្ទូលថា « អ្នកកុំលោភទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ប៉ុន្តែចូរចំណាយដោយសេរីសម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន » ។ ព្រះអម្ចាស់បានបញ្ជាក់ដល់ម៉ាទិនថា ព្រះគម្ពីរនេះមានព្រះបន្ទូលពិតប្រាកដរបស់ព្រះ ហើយវានឹងជួយឲ្យមនុស្សដទៃទៀតជឿលើដំណឹងល្អ ។[៣]

*ព្រះអម្ចាស់បានមានបន្ទូលទៅកាន់ម៉ាទិន ហារីសថា « អ្នកកុំលោភទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ប៉ុន្តែសូមចំណាយដោយសេរី សម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន » ។*

ទោះបីជាពួកអ្នកជិតខាងគាត់ពុំយល់ពីការសម្រេចចិត្តរបស់គាត់ក៏ដោយ ក៏ម៉ាទិន នៅតែគោរពតាមព្រះអម្ចាស់ ហើយបានបញ្ចាំកសិដ្ឋានរបស់គាត់ដើម្បីធានាដល់ការបង់ប្រាក់ដែរ ។[៤]

លោកហ្គ្រេនឌីន បានចុះហត្ថលេខាលើកិច្ចសន្យា ហើយបានចាប់ផ្តើមរៀបចំគម្រោងដ៏ធំនេះ ។[៥] យ៉ូសែប បានបកប្រែអត្ថបទព្រះគម្ពីរមរមន ក្នុងរយៈពេលបីខែ ដោយមានជំនួយពីអ្នកកត់ត្រាម្នាក់ក្នុងពេលនោះ ។ វានឹងធ្វើឲ្យលោកហ្គ្រេនឌីន និងមនុស្សជាងដប់នាក់ធ្វើការរយៈពេលប្រាំពីរខែដើម្បីបោះពុម្ព ហើយកិបសំណៅបោះពុម្ពចំនួន ៥៩០ ទំព័រដំបូងនោះ ។[៦]

ក្រោយពីបានជួលអ្នកបោះពុម្ពរួចរាល់ហើយ យ៉ូសែប បានត្រឡប់ទៅភូមិហាម៉ូនីវិញនាខែ តុលា ឆ្នាំ ១៨២៩ ដើម្បីធ្វើការនៅក្នុងកសិដ្ឋាន និងនៅជាមួយ អិមម៉ា ។ នៅគ្រានោះដែរ អូលីវើរ ម៉ាទិន និង ហៃរុម ជាអ្នកមើលខុសត្រូវលើការបោះពុម្ព ហើយរាយការណ៍ជាប្រចាំទៅយ៉ូសែប អំពីបច្ចុប្បន្នភាពទៅលើដំណើរការបោះពុម្ពរបស់លោកហ្គ្រេនឌីន ។[៧]

ដោយចងចាំពីភាពអស់សង្ឃឹមដែលគាត់បានមានបន្ទាប់ពីបាត់បង់ទំព័រដំបូងដែលគាត់បានបកប្រែ នោះយ៉ូសែប បានសុំអូលីវើរឲ្យចម្លងសំណៅព្រះគម្ពីរមរមនសរសេរដៃគ្រប់ទំព័រ ដើម្បីមានពីរក្បាលពេលយកទៅហាងបោះពុម្ព ដើម្បីអាចបន្ថែមការដាក់វណ្ណយុត្តិ និងធ្វើការវាយសំណុំផង ។[៨]

អូលីវើរ បានរីករាយនឹងចម្លងព្រះគម្ពីរ ហើយគាត់ស្កប់ស្កល់នឹងលិខិតដែលគាត់សរសេរនៅពេលនោះ ។ ដោយការឯកភាពនឹង នីហ្វៃ យ៉ាកុប និងអាមូលេកក្នុងព្រះគម្ពីរមរមន អូលីវើរ បានសរសេរទៅយ៉ូសែប អំពីការដឹងគុណរបស់គាត់ចំពោះដង្វាយធួនដ៏គ្មានដែនកំណត់របស់ព្រះគ្រីស្ទ ។

គាត់បានជម្រាបទៅយ៉ូសែបថា « នៅពេលដែលខ្ញុំចាប់ផ្តើមសរសេរអំពីសេចក្តីមេត្តាករុណារបស់ព្រះ ខ្ញុំមិនដឹងថាត្រូវបញ្ចប់នៅពេលណានោះទេ ប៉ុន្តែពេលវេលា និងក្រដាសមិនមានគ្រប់គ្រាន់ទុកឲ្យខ្ញុំសរសេរនោះទេ » ។[៩]

ព្រះវិញ្ញាណដដែលនោះបានទាក់ទាញមនុស្សដទៃទៀតឲ្យមករកព្រះគម្ពីរមរមននៅពេលដែលវាកំពុងបោះពុម្ព ។ លោក ថូម៉ាស ម៉ាស ជាអតីតកូនជាងនៅហាងបោះពុម្ព បានព្យាយាមស្វែងរកកន្លែងដែលគាត់ពេញចិត្តនៅព្រះវិហារផ្សេង ប៉ុន្តែព្រះវិហារទាំងអស់ហាក់ដូចជាគ្មានព្រះវិហារណាដែលផ្សាយដំណឹងល្អ ដែលគាត់បានរកឃើញនៅក្នុងព្រះគម្ពីរប៊ីបឡើយ ។ គាត់ជឿថា ព្រះវិហារថ្មីនឹងរៀបចំឡើងក្នុងពេលឆាប់ៗដែលនឹងបង្រៀនសេចក្តីពិតដែលបានស្តារឡើងវិញ ។

នៅរដូវក្តៅនោះ ថូម៉ាស មានអារម្មណ៍ថាត្រូវបានដឹកនាំដោយព្រះវិញ្ញាណឲ្យធ្វើដំណើររាប់រយគីឡូម៉ែត្រពីផ្ទះរបស់គាត់ទៅកាន់ ប៉ូស្តុន នៅភាគខាងជើងនៃទីក្រុងនូវយ៉ក ។ គាត់បាននៅទីនោះអស់រយៈពេលបីខែពីមុនត្រឡប់មកផ្ទះវិញ ដោយពុំយល់ពីហេតុដែលគាត់ត្រូវធ្វើដំណើរយ៉ាងឆ្ងាយបែបនោះទេ ។ នៅចំណតមួយនៅតាមផ្លូវត្រឡប់មកផ្ទះវិញ ស្រាប់តែម្ចាស់ផ្ទះដែលគាត់ស្នាក់នៅជាមួយនោះបានសួរគាត់ថា តើគាត់ដែលធ្លាប់ឮអំពី « គម្ពីរមាស » របស់យ៉ូសែប ស្ម៊ីធ ដែរឬទេ ? ថូម៉ាស បានប្រាប់ទៅស្ត្រីនោះថាគាត់ពុំដែលបានឮទេ ហើយមានអារម្មណ៍ចង់រៀនបន្ថែមទៀតអំពីគម្ពីរនេះ ។

នាងបានប្រាប់គាត់ថា គាត់គួរសួរទៅ លោក ម៉ាទិន ហារិស ហើយបានណែនាំគាត់ឲ្យទៅភូមិប៉ាលម៉ៃរ៉ា ។ ថូម៉ាស បានទៅទីនោះភ្លាម ហើយបានជួបនឹងម៉ាទិននៅឯហាងបោះពុម្ពរបស់ ហ្គ្រេនឌីន ។ ជាងបោះពុម្ពបានឲ្យព្រះគម្ពីរមរមនដប់ប្រាំមួយសន្លឹកទៅគាត់ ហើយថូម៉ាស បានយកវាទៅ បូស្តុន ទាំងអន្ទះសាដើម្បីចែកចាយនឹងភរិយាគាត់ ដែលមានឈ្មោះថា អេលីស្សាប៉ែត នូវរសជាតិដំបូងនៃជំនឿថ្មី ។

អេលីស្សាប៉ែត បានអានគ្រប់ទំព័រទាំងអស់ ហើយនាងបានជឿថា វាជាកិច្ចការរបស់ព្រះ ។[១០]

នៅរដូវស្លឹកឈើជ្រុះ ខណៈដែលជាងបោះពុម្ពបានខិតខំធ្វើការបោះពុម្ពព្រះគម្ពីរមរមន ស្រាប់តែអតីតចៅក្រមដែលមានឈ្មោះថា អប់ន័រ ខូល បានចាប់ផ្តើមបោះពុម្ពផ្សាយកាសែតមួយនៅរោងពុម្ពរបស់ ហ្គ្រេនឌីន ។ កាលកំពុងធ្វើការនៅក្នុងហាងនាពេលយប់ បន្ទាប់ពីបុគ្គលិករបស់ហ្គ្រេនឌីន បានត្រឡប់ទៅផ្ទះវិញ អប់ន័រ

បានលួចបោះពុម្ពទំព័រខ្លះៗនៃព្រះគម្ពីរមរមន ដែលពុំទាន់កិប ឬពុំទាន់អាចដាក់លក់នោះចេញមក ។

មិនយូរប៉ុន្មាន អប់ន័រ ចាប់ផ្ដើមចំអកឡកឡឺយ « ព្រះគម្ពីរមាស » នៅក្នុងកាសែតរបស់គាត់ ហើយនៅអំឡុងរដូវរងារនោះ គាត់បានបោះពុម្ពសេចក្ដីដកស្រង់ចេញពីព្រះគម្ពីរទាំងមានការអធិប្បាយចំអកឡកឡឺយផង ។[១១]

នៅពេល ហៃរុម និង អូលីវើរ បានដឹងអ្វីដែលអប់ន័រកំពុងធ្វើ ពួកលោកបានប្រឈមមុខនឹងគាត់ ។ « តើលោកមានសិទ្ធិអ្វីដើម្បីបោះពុម្ពព្រះគម្ពីរមរមនតាមរបៀបនេះ ? » ហៃរុម បានសួរ ។ « តើលោកពុំបានដឹងទេឬថាយើងបានទទួលកម្មសិទ្ធិបញ្ញា ? »

អប់ន័រ បានតបថា « វាពុំមែនជារឿងរបស់លោកទេ » ។ « ខ្ញុំបានជួលរោងពុម្ពនេះ ហើយខ្ញុំនឹងបោះពុម្ពអ្វីតាមចិត្តរបស់ខ្ញុំ » ។

ហៃរុម បានតបថា « ខ្ញុំហាមលោកឲ្យឈប់បោះពុម្ពព្រះគម្ពីរនោះបន្តទៀត » ។

អប់ន័រ បានពោលថា « ខ្ញុំមិនខ្វល់ទេ » ។

ដោយពុំដឹងថាត្រូវធ្វើអ្វីទៀត ហៃរុម និងអូលីវើរ បានផ្ញើសំបុត្រទៅយ៉ូសែបនៅក្នុងភូមិហាម៉ូនី នោះគាត់បានត្រឡប់ទៅភូមិបាល់ម៉ៃរ៉ាភ្លាម ។ គាត់បានឃើញអប់ន័រ នៅឯការិយាល័យរោងពុម្ពនោះ កំពុងតែអានសារព័ត៌មានរបស់ខ្លួន ។

យ៉ូសែប បានពោលថា « លោកទំនងជាខិតខំធ្វើការណាស់ » ។

អប់ន័រ បានតបទាំងទឹកមុខស្ងួតថា « សុខសប្បាយជាទេ លោកស្ម៊ីធ » ។

យ៉ូសែប បានពោលថា « លោក ខូល ព្រះគម្ពីរមរមន និងសិទ្ធិបោះពុម្ពព្រះគម្ពីរនេះគឺជារបស់ខ្ញុំ ហើយខ្ញុំសូមហាមលោកកុំឲ្យជ្រៀតជ្រែកក្នុងរឿងនេះ » ។

អប់ន័រ បានបោះអាវធំគាត់ចោល ហើយបានលាត់ដៃអាវឡើង ។ គាត់បានស្រែកខ្លាំងៗទាំងក្ដាប់ដៃថា « តើលោកចង់វ៉ៃគ្នាមែនទេ ? » ។ « បើលោកចង់វ៉ៃគ្នាមែនសូមចូលមក » ។

យ៉ូសែប បានញញឹម ។ គាត់បានពោលថា « លោកគួរយកអាវធំទៅពាក់វិញទៅ » ។ « វាត្រជាក់ណាស់ ហើយខ្ញុំនឹងមិនវ៉ៃគ្នាជាមួយលោកឡើយ » ។ លោកបានបន្តទាំងចិត្តស្ងប់ថា « ប៉ុន្តែលោកត្រូវឈប់បោះពុម្ពព្រះគម្ពីររបស់ខ្ញុំទៀត » ។

អប់ន័រ បានពោលថា « បើលោកគិតថា ខ្លួនលោកជាមនុស្សល្អជាងគេមែនអញ្ជើងដោះអាវធំលោកចេញទៅ ហើយល្បងវ៉ៃគ្នាលមើល » ។

យ៉ូសែប បានតបថា « យើងមានច្បាប់ ហើយលោកនឹងដឹងពីរឿងនោះ បើលោកពុំទាន់ដឹងបាននៅឡើយនោះ ។ ប៉ុន្តែខ្ញុំនឹងពុំវ៉ៃគ្នាជាមួយលោកទេ ពីព្រោះវាគ្មានប្រយោជន៍ទេ » ។

អប់ន័រ បានដឹងថា គាត់គឺជាអ្នកខុសតាមផ្លូវច្បាប់ ។ គាត់បានសម្រួលអារម្មណ៍ ហើយបញ្ឈប់ការបោះពុម្ពសេចក្ដីដកស្រង់ចេញពីព្រះគម្ពីរមរមននៅក្នុងសារព័ត៌មានរបស់គាត់ទៀត ។[១២]

សូឡូម៉ូន ឆាំបើរលីន ដែលជាគ្រូគង្វាលម្នាក់កំពុងធ្វើដំណើរទៅប្រទេសកាណាដា បានឮអំពី « ព្រះគម្ពីរប៊ីបមាស » ជាលើកដំបូង មកពីគ្រួសារមួយដែលគាត់បានស្នាក់នៅជាមួយ នៅក្បែរភូមិបាល់ម៉ៃរ៉ា ។ ដូចជាលោក ថូម៉ាស ម៉ាសដែរ គាត់បានប្ដូរពីព្រះវិហារមួយទៅព្រះវិហារមួយទៀតនៅក្នុងជីវិតរបស់គាត់ ប៉ុន្តែពុំពេញចិត្តនឹងអ្វីដែលគាត់បានឃើញទេ ។ ព្រះវិហារមួយចំនួនបានបង្រៀននូវគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយបានជឿលើអំណោយទានខាងវិញ្ញាណ ប៉ុន្តែពួកគេគ្មានពួកព្យាការីរបស់ព្រះ ឬបព្វជិតភាពរបស់ទ្រង់ឡើយ ។ សូឡូម៉ូន បានទទួលអារម្មណ៍ថា ពេលវេលាបានមកដល់ហើយ ដែលព្រះអម្ចាស់នឹងនាំព្រះវិហាររបស់ទ្រង់ឲ្យចេញមក ។

នៅពេលសូឡូម៉ូន បានស្ដាប់គ្រួសារនោះនិយាយអំពីយ៉ូសែប ស្ម៊ីធ និងផ្ទាំងចំណារមាសហើយ គាត់មានអារម្មណ៍ព្រឺខ្លួនតាំងពីក្បាលរហូតដល់ចុងជើង ហើយគាត់បានតាំងចិត្តស្វែងរកគ្រួសារស្ម៊ីធ ដើម្បីរៀនបន្ថែមទៀតអំពីគម្ពីរនោះ ។

គាត់បានស្វែងរកផ្ទះរបស់គ្រួសារស្ម៊ីធ ហើយបានជួបនឹងហៃរុម នៅឯមាត់ទ្វារ ។ សូឡូម៉ូន បានពោលថា « សូមឲ្យភាពសុខសាន្តកើតមានដល់ផ្ទះនេះ » ។

ហៃរុម បានតបថា « ខ្ញុំសង្ឃឹមថា វានឹងមានភាពសុខសាន្ត » ។

សូឡូម៉ូន បានសួរថា « តើមានមនុស្សក្នុងផ្ទះនេះ ដែលជឿលើការនិមិត្ត ឬវិវរណៈទេ ? »

ហៃរុម បានតបថា « បាទមាន យើងគឺជាគ្រួសារមួយដែលជឿលើការនិមិត្ត » ។

សូឡូម៉ូន បានប្រាប់ហៃរុម អំពីការនិមិត្តមួយដែលគាត់បានឃើញកាលពីច្រើនឆ្នាំកន្លងទៅ ។ នៅក្នុងការនិមិត្តនោះ មានទេវតាមួយអង្គបានមានបន្ទូលថា ព្រះគ្មានព្រះវិហារនៅលើផែនដីនេះទេ ប៉ុន្តែមិនយូរប៉ុន្មាននឹងបង្កើតព្រះវិហារមួយដែលមានអំណាចដូចជាព្រះវិហាររបស់ពួកសាវកកាលពីបុរាណដែរ ។ ហៃរុម និងមនុស្សដទៃទៀតនៅក្នុងផ្ទះបានយល់អ្វីដែលសូឡូម៉ូន បាននិយាយ ហើយប្រាប់គាត់ថា ពួកគេមានជំនឿដូចគាត់ដែរ ។

សូឡូម៉ូន បានពោលថា « ខ្ញុំចង់ឲ្យអ្នកប្រាប់ខ្ញុំនូវអ្វីដែលអ្នកបានរកឃើញ ។ ខ្ញុំគិតថា ខ្ញុំអាចទទួលយកវាបាន »។

ហៃរុម បានអញ្ជើញគាត់ឲ្យស្នាក់នៅឯកសិដ្ឋានរបស់គ្រួសារស្ម៊ីធ ក្នុងនាមជាភ្ញៀវ ហើយបានបង្ហាញគាត់នូវសំណៅព្រះគម្ពីរមរមនដែលសរសេរដៃ ។ សូឡូម៉ូន បានសិក្សាព្រះគម្ពីរនោះអស់រយៈពេលពីរថ្ងៃ ហើយបានទៅជាមួយនឹងហៃរុម ទៅការិយាល័យបោះពុម្ពរបស់ហ្គ្រានឌីន ដែលនៅទីនោះអ្នកបោះពុម្ពម្នាក់បានឲ្យព្រះគម្ពីរចំនួនហុកសិបបួនទំព័រដែលបោះពុម្ពរួចដល់គាត់ ។ សូឡូម៉ូន បានបន្តដំណើរទៅប្រទេសកាណាដា ទាំងប្រកាសពីអ្វីគ្រប់យ៉ាងដែលគាត់បានដឹងអំពីជំនឿថ្មីនេះនៅតាមផ្លូវ ដោយមានគម្ពីរមិនទាន់កិបទាំងនោះនៅក្នុងដៃ ។[១៣]

លុះដល់ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៨៣០ ច្បាប់ដំបូង នៃព្រះគម្ពីរមរមនត្រូវបានផ្គុំចូលគ្នា ហើយមានដាក់លក់នៅជាន់ផ្ទាល់ដីនៃការិយាល័យបោះពុម្ពរបស់ហ្គ្រានឌីន ។ ព្រះគម្ពីរទាំងនោះត្រូវបានគេចងក្រងជាសៀវភៅដោយស្បែកគោ ហើយមានធុំក្លិនស្បែក និងកាវ ក្រដាស និងទឹកថ្នាំ ។ ពាក្យ*ព្រះគម្ពីរមរមន* បានលេចឡើងនៅលើខ្នងសៀវភៅនោះជាអក្សរពណ៌មាស ។[១៤]

លូស៊ី ស្ម៊ីធ បានរក្សាទុកព្រះគម្ពីរថ្មីនេះ ហើយបានចាត់ទុកថា វាគឺជាទីសម្គាល់មួយដែលព្រះនឹងប្រមូលផ្ដុំកូនចៅរបស់ទ្រង់ និងស្ដារឡើងវិញនូវសេចក្ដីសញ្ញារបស់ទ្រង់កាលពីបុរាណក្នុងពេលឆាប់ៗនេះ ។ ទំព័រចំណងជើងបានប្រកាសថា គោលបំណងរបស់ព្រះគម្ពីរមរមនគឺដើម្បីបង្ហាញរឿងដ៏អស្ចារ្យដែលព្រះបានធ្វើ

សម្រាប់រាស្ត្ររបស់ទ្រង់កាលពីមុន ហើយប្រទានពរជ័យដូចគ្នាដល់រាស្ត្ររបស់ទ្រង់នៅសព្វថ្ងៃនេះ ហើយធ្វើឲ្យពិភពលោកទាំងមូលជឿថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះនៃពិភពលោកនេះ ។[១៥]

នៅផ្នែកខាងក្រោយនៃព្រះគម្ពីរនោះគឺជាទីបន្ទាល់នៃពួកសាក្សីបីរូប និងពួកសាក្សីប្រាំបីរូប ថ្លែងប្រាប់ទៅកាន់ពិភពលោកថា ពួកគាត់បានឃើញផ្ទាំងចំណារនោះ ហើយបានដឹងថា ការបកប្រែនោះគឺជាការពិត ។[១៦]

ទោះជាមានទីបន្ទាល់ទាំងនេះក្តី ក៏លូស៊ីបានដឹងថា មានមនុស្សមួយចំនួនបានគិតថា ព្រះគម្ពីរនេះគឺជារឿងប្រឌិត ។ មានពួកអ្នកជិតខាងរបស់គាត់ជាច្រើន បានជឿថា ការមានព្រះគម្ពីរប៊ីបគឺល្អមគ្រប់គ្រាន់ហើយសម្រាប់ពួកគេហើយពុំបានដឹងថា ព្រះបានប្រទានដល់ប្រជាជាតិនានានូវព្រះគម្ពីរលើសពីមួយដែលមាននូវបន្ទូលរបស់ទ្រង់ ។ គាត់ក៏បានដឹងផងដែរថា មានមនុស្សមួយចំនួនបានបដិសេធសារលិខិតក្នុងគម្ពីរនេះ ដោយសារពួកគេជឿថា ព្រះធ្លាប់មានបន្ទូលមកកាន់ពិភពលោកម្តងរួចទៅហើយ ហើយទ្រង់នឹងពុំមានបន្ទូលម្តងទៀតឡើយ ។

ដោយសារហេតុផលទាំងនេះ និងហេតុផលផ្សេងទៀត នោះមនុស្សភាគច្រើននៅភូមិបាល់ម៉ៃរ៉ា ពុំបានទិញគម្ពីរនោះទេ ។[១៧] ប៉ុន្តែមនុស្សមួយចំនួនដែលបានសិក្សាព្រះគម្ពីរនេះ បានទទួលអារម្មណ៍ពីអនុភាពនៃការបង្រៀនរបស់វា ហើយបានលុតជង្គង់ចុះទូលសូមព្រះ ប្រសិនបើព្រះគម្ពីរនេះពិតមែន ។ លូស៊ី ផ្ទាល់បានដឹងថា ព្រះគម្ពីរមរមនគឺជាបន្ទូលរបស់ព្រះ ហើយចង់ចែកចាយជាមួយនឹងមនុស្សដទៃទៀត ។[១៨]

*នៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ យ៉ូសែប និង អូលីវើរ បានជួបគ្នានៅក្នុងផ្ទះរបស់គ្រួសារវិតមើរ ដើម្បីធ្វើតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយរៀបចំសាសនាចក្ររបស់ទ្រង់ ។*

បន្ទាប់ពីព្រះគម្ពីរមរមនបានបោះពុម្ពរួចហើយភ្លាម យ៉ូសែប និងអូលីវើរ បានរៀបចំដើម្បីបង្កើតព្រះវិហារនៃព្រះយេស៊ូវគ្រីស្ទ ។ នៅប៉ុន្មានខែមុនបង្កើតព្រះវិហារ នោះសាវកពេត្រុស យ៉ាកុប និងយ៉ូហាន ជាសាវកពីបុរាណរបស់ព្រះអម្ចាស់បានមកជួបនឹងពួកគាត់ ហើយបានប្រគល់បព្វជិតភាពមិលគីស្សាដែកដល់ពួកគាត់ ដូចដែលយ៉ូហាន បាទីស្ទបានសន្យា ។ សិទ្ធិអំណាចបន្ថែមនេះបានធ្វើឲ្យយ៉ូសែប និងអូលីវើរ អាចប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់ជនទាំងឡាយណាដែលពួកគាត់បានធ្វើបុណ្យជ្រមុជទឹកឲ្យ ។ សាវកពេត្រុស យ៉ាកុប និងយ៉ូហាន ក៏បានតែងតាំងដល់ពួកគាត់ឲ្យធ្វើជាសាវករបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។[១៩]

នៅអំឡុងពេលនោះ ខណៈដែលកំពុងស្នាក់នៅក្នុងផ្ទះរបស់ វិតមើរ នោះយ៉ូសែប និងអូលីវើរ បានអធិស្ឋានទូលសូមចំណេះដឹងបន្ថែមទៀតអំពីសិទ្ធិអំណាចនេះ ។ ជាការឆ្លើយតបមកវិញ នោះសំឡេងរបស់ព្រះអម្ចាស់បានបញ្ជាដល់ពួកគាត់ឲ្យតែងតាំងគ្នាទៅវិញទៅមកជាពួកអែលឌើរនៃសាសនាចក្រ ប៉ុន្តែមិនត្រូវធ្វើឡើយរហូតដល់ពួកអ្នកមានជំនឿទាំងឡាយធ្វើតាមពួកគាត់ ថាជាថ្នាក់ដឹកនាំនៅក្នុងព្រះវិហាររបស់ព្រះអង្គសង្គ្រោះជាមុនសិន ។ ពួកគាត់ក៏ត្រូវបានប្រាប់ឲ្យតែងតាំងថ្នាក់ដឹកនាំព្រះវិហារដទៃទៀត ហើយប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់ជនទាំងឡាយដែលបានទទួលបុណ្យជ្រមុជទឹកផងដែរ ។[២០]

នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ យ៉ូសែប និងអូលីវើរ បានជួបគ្នានៅក្នុងផ្ទះរបស់លោក វិតមើរ ដើម្បីធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយធ្វើការរៀបចំព្រះវិហាររបស់ទ្រង់ ។ ដើម្បីបំពេញតាមតម្រូវការនៃច្បាប់ នោះពួកគាត់បានជ្រើសរើសមនុស្សប្រាំមួយនាក់ធ្វើជាសមាជិកដំបូងនៃព្រះវិហារថ្មីនេះ ។ មានបុរស និងស្ត្រីប្រមាណជាសែសិបនាក់នៅប្រជ្រៀតគ្នាក្នុងផ្ទះតូចនោះ ដើម្បីធ្វើជាសាក្សីក្នុងឱកាសនេះផងដែរ ។[២១]

ដើម្បីគោរពតាមសេចក្តីណែនាំកាលពីមុនរបស់ព្រះអម្ចាស់ យ៉ូសែប និងអូលីវើរ បានសុំឲ្យអង្គជំនុំធ្វើការគាំទ្រដល់ពួកគាត់ជាថ្នាក់ដឹកនាំនៅក្នុងនគរនៃព្រះ ហើយសូមបង្ហាញបើពួកគេបានជឿថាវាជារឿងត្រឹមត្រូវដែលពួកគាត់បង្កើតព្រះវិហារមួយឡើង ។ សមាជិកគ្រប់រូបនៅក្នុងក្រុមជំនុំបានឯកភាព ហើយយ៉ូសែប បានដាក់ដៃរបស់គាត់នៅលើក្បាលរបស់អូលីវើរ ហើយបានតែងតាំងគាត់ធ្វើជាអែលឌើរនៅក្នុងព្រះវិហារ ។ រួចមកពួកគាត់បានផ្លាស់ប្តូរកន្លែងគ្នាហើយអូលីវើរបានតែងតាំងយ៉ូសែប ។

បន្ទាប់មក ពួកគាត់បានចែកនំបុ័ង និងស្រាទំពាំងបាយជូនៃពិធីសាក្រាម៉ង់ទុកជាការចងចាំដល់ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់មកពួកគាត់បានដាក់ដៃលើជនដែលបានទទួលបុណ្យជ្រមុជទឹក បញ្ជាក់ពួកគេថាជាសមាជិកនៃព្រះវិហារ ហើយផ្តល់ដល់ពួកគេនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។[២២] ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានចាក់ស្រោចមកលើជនទាំងឡាយដែលនៅក្នុងការប្រជុំនោះ ហើយជនខ្លះដែលនៅក្នុងអង្គជំនុំបានចាប់ផ្តើមធ្វើការព្យាករ ។ អ្នកដទៃទៀតបានសរសើរដល់ព្រះអម្ចាស់ ហើយមនុស្សទាំងអស់បានរីករាយជាមួយគ្នា ។

យ៉ូសែប ក៏បានទទួលវិវរណៈដំបូងថ្លែងទៅកាន់សមាជិកទាំងអស់នៃព្រះវិហារថ្មីផងដែរ ។ « មើលចុះ នឹងមានបញ្ជីមួយកត់ទុកនៅក្នុងចំណោមអ្នករាល់គ្នា » ព្រះអម្ចាស់បានបញ្ជាដោយរំឭករាស្ត្ររបស់ទ្រង់ ឲ្យពួកគេសរសេរប្រវត្តិដ៏ពិសិដ្ឋរបស់ពួកគេ ដើម្បីថែរក្សាកំណត់ហេតុនៃសកម្មភាពរបស់ពួកគេ ហើយធ្វើជាសាក្សីដល់តួនាទីរបស់យ៉ូសែប ក្នុងនាមជាព្យាការី អ្នកមើលឆុត និងជាអ្នកទទួលវិវរណៈ ។

ព្រះអម្ចាស់បានប្រកាសថា « អ្នកនោះហើយដែលយើងបានបំភ្លឺឲ្យកម្រើកគតិនៃស៊ីយ៉ូនដោយអំណាចដ៏ធំដើម្បីសេចក្តីល្អ ។ ពាក្យសម្តីរបស់លោកនោះហើយ ដែលអ្នកនឹងបានទទួល ហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់ដោយសេចក្តីអត់ធន់ និងសេចក្តីជំនឿគ្រប់យ៉ាង ។ ដ្បិតដោយសារការធ្វើការណ៍ទាំងនេះ ទើបទ្វារស្ថាននរកនឹងពុំដែលឈ្នះអ្នកឡើយ » ។[២៣]

ក្រោយមក យ៉ូសែប បានឈរនៅក្បែរស្ទឹង ហើយបានធ្វើជាសាក្សីដល់ពិធីបុណ្យជ្រមុជទឹករបស់ម្តាយ និងឪពុករបស់លោកចូលក្នុងព្រះវិហារ ។ បន្ទាប់ពីការចំណាយពេលលើផ្លូវខុសៗគ្នាស្វែងរកសេចក្តីពិតអស់ជាច្រើនឆ្នាំ នៅទីបំផុតពួកគាត់បានរួបរួមគ្នានៅក្នុងសេចក្តីជំនឿ ។ នៅពេលឪពុកគាត់បានក្រោកចេញពីទឹក

មក យ៉ូសែប បានចាប់ដៃគាត់ ហើយបានជួយគាត់ឲ្យឡើងមកលើច្រាំង រួចបានឱបឪពុករបស់គាត់ ។

យ៉ូសែប បានយំឱនមុខគាត់នៅលើទ្រូងឪពុក រួចថា « ព្រះលោកអើយ ខ្ញុំបានរស់នៅមើលឃើញឪពុករបស់ខ្ញុំបានទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ ! »[២៤]

នាល្ងាចនោះ យ៉ូសែប បានចូលទៅក្នុងព្រៃនៅជិតៗនោះ ដោយដួងចិត្តរំភើបញាប់ញ័រ ។ គាត់ចង់នៅម្នាក់ឯង នៅឆ្ងាយពីមិត្តភក្តិ និងគ្រួសារ ។ អស់រយៈពេលដប់ឆ្នាំហើយចាប់តាំងពីការនិមិត្តដំបូងរបស់គាត់ គាត់បានឃើញស្ថានសួគ៌បើកឡើង បានទទួលអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះ ហើយបានទទួលការបង្រៀនពីពួកទេវតា ។ គាត់ក៏មានបាប ហើយបានបាត់បង់អំណោយទានរបស់គាត់ មានតែការប្រែចិត្តប៉ុណ្ណោះ ទើបគាត់ទទួលបានសេចក្ដីមេត្តាករុណារបស់ព្រះ និងបានបកប្រែព្រះគម្ពីរមរមនដោយព្រះចេស្ដា និងព្រះគុណរបស់ទ្រង់ ។

ឥឡូវនេះ ព្រះយេស៊ូវគ្រីស្ទបានស្ដារព្រះវិហាររបស់ទ្រង់ឡើងវិញ ហើយបានប្រគល់ឲ្យយ៉ូសែប នូវបព្វជិតភាពដូចគ្នាដែលពួកសាវកបានកាន់កាលពីសម័យបុរាណកាលដែលពួកលោកបានផ្សព្វផ្សាយដំណឹងល្អដល់ពិភពលោក ។[២៥] សុភមង្គលដែលគាត់ទទួលបានគឺវាលើសលប់ រហូតដល់លោកមិនអាចលាក់ទុកបាន ហើយនៅពេលយ៉ូសែប ណៃត៍ និងអូលីវើរ រកគាត់ឃើញនៅយប់នោះ គឺគាត់កំពុងយំ ។

សេចក្ដីរីករាយរបស់គាត់ធំធេងខ្លាំងណាស់ ។ កិច្ចការបានចាប់ផ្ដើមហើយ ។[២៦] ■

បញ្ជីទាំងស្រុងនៃសៀវភៅនេះមានជាភាសាអង់គ្លេសនៅគេហទំព័រ saints.lds.org ។

ពាក្យ *ប្រធានបទ* នៅក្នុងកំណត់ចំណាំបង្ហាញពីព័ត៌មានបន្ថែមនៅលើអ៊ិនធើណែតនៅគេហទំព័រ saints.lds.org ។

**កំណត់ចំណាំ**


១. Copyright for Book of Mormon ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨២៩, នៅក្នុង *JSP,* D១:៧៦–៨១ ។

២. « Prospect of Peace with Utah » *Albany Evening Journal,* ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៨៥៨ [ទំព័រ ២]; « From the Troy Times » *Albany Evening Journal,* ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៨៥៨ [ទំព័រ ២]; John H. Gilbert, Memorandum ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៨៩២, photocopy, Church History Library ។

៣. Doctrine and Covenants ១៩ (Revelation, ប្រហែលក្នុងរដូវក្ដៅ ឆ្នាំ ១៨២៩នៅ josephsmithpapers.org); សូមមើលផងដែរ Historical Introduction to Revelation, circa Summer ឆ្នាំ ១៨២៩ [DC ១៩]នៅក្នុង *JSP,* D១:៨៥–៨៩ និង Knight, Reminiscences, ទំព័រ ៦–៧។

៤. McBride «Contributions of Martin Harris» ទំព័រ ១–៩; Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៣៤នៅក្នុង *JSP,* H១:៣៥២ ( សេចក្ដីព្រាង ២ ) ។

៥. John H. Gilbert, Statement ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៨៨៧, Church History Library; Indenture, Martin Harris to Egbert B. Grandin, Wayne County, NY, ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៨២៩, Wayne County, NY, Mortgage Records ភាគ ៣ ទំព័រ ៣២៥–២៦ មីក្រូហ្វិលម៍ ៤៧៩.៥៥៦, ការប្រមូលកំណត់ហេតុរបស់អាមេរិក និងកាណាដា, បណ្ណាល័យពង្សប្រវត្តិគ្រួសារ; Historical Introduction to Revelation, circa Summer ឆ្នាំ ១៨២៩ [DC ១៩]នៅក្នុង *JSP,* D១:៨៥–៨៩ ។

៦. Copyright for Book of Mormon ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៧៦–៨១; John H. Gilbert, Memorandum ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៨២៩, photocopy, Church History Library; Porter, « The Book of Mormon » ទំព័រ ៥៣–៥៤ ។

៧. John H. Gilbert, Memorandum ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៨៩២, photocopy, Church History Library; Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៩ [ទំព័រ ៨]; Joseph Smith to Oliver Cowdery ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៩៤–៩៧ ។

៨. John H. Gilbert, Memorandum ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ១៨២៩, ថតចម្លង បណ្ណាល័យនៃប្រវត្តិសាស្ត្រសាសនាចក្រ; Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៩ [ទំព័រ ២]; «Printer's Manuscript of the Book of Mormon» នៅក្នុង *JSP,* R៣ ផ្នែក ១៖ xxvi ។ **ប្រធានបទ ៖** Printing and Publishing the Book of Mormon

៩. Oliver Cowdery to Joseph Smith ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:១០០–១០១; ម៉ូសាយ ៣:១៨–១៩; ៥:៥–៧; នីហ្វៃទី ៤ ១:១៧; សូមមើលផងដែរ Oliver Cowdery to Joseph Smith ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:១០១–៤ ។

១០. Thomas B. Marsh, « History of Thomas Baldwin Marsh » *LDS Millennial Star,* ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ១៨៦៤ ទំព័រ ២៦:៣៥៩–៦០; ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨៦៤ ទំព័រ ២៦:៣៧៥–៧៦។

១១. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៩ [ទំព័រ ៩]។ ឧទាហរណ៍អំពីសេចក្ដីដកស្រង់ចេញពីព្រះគម្ពីរមរមន ដែលបានបោះពុម្ពផ្សាយដោយអប់ន័រ ខូល សូមមើល « ព្រះគម្ពីរមរមន » *Reflector* ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៨២៩ ទំព័រ ១០ « Selected Items » *Reflector* ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៨២៩ ទំព័រ ១៤ « ព្រះគម្ពីរទីមួយនៃគម្ពីរនីហ្វៃ » *Reflector* ថ្ងៃទី ២ ខែ មករា ឆ្នាំ ១៨៣០ ទំព័រ ១ និង « ព្រះគម្ពីរនីហ្វៃ » *Reflector* ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៨៣០ ទំព័រ ១ ។ **ប្រធានបទ ៖** Critics of the Book of Mormon

១២. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៩ [ ៩ ]–[ ១២ ]; Lucy Mack Smith, History ឆ្នាំ ១៨៤៥ ទំព័រ ១៦៦–៦៨។

១៣. Chamberlin, Autobiography ៤–១១។

១៤. Copyright for Book of Mormon ថ្ងទី ១១ ខែមិថុនា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៧៦–៨១; John H. Gilbert, Memorandum ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ១៨២៩, ថតចម្លងបណ្ណាល័យប្រវត្តិសាស្ត្រនៃសាសនាចក្រ « ព្រះ គម្ពីរមរមន » *Wayne Sentinel,* ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ១៨៣០ [៣] ។ គម្ពីរមួយចំនួនក៏បានចងជាស្បែកសត្វផងដែរ ។

១៥. Title Page of Book of Mormon, circa early ខែមិថុនា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៦៣–៦៥ សូមមើលផងដែរ Lucy Mack Smith to Solomon Mack ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ១៨៣១ បណ្ណាល័យប្រវត្តិសាសនាចក្រ ។

១៦. Testimony of Three Witnesses ចុងខែ មិថុនា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៣៧៨–៨២; Testimony of Eight Witnesses ចុងខែ មិថុនា ឆ្នាំ ១៨២៩នៅក្នុង *JSP,* D១:៣៨៥–៨៧ ។

១៧. Tucker, *Origin, Rise, and Progress of Mormonism,* ៦០–៦១ ។

១៨. សូមមើល Lucy Mack Smith to Solomon Mack ថ្ងៃទី៦ ខែមករា ១៨៣១ បណ្ណាល័យប្រវត្តិសាសនាចក្រ ។

១៩. Joseph Smith History, circa Summer ឆ្នាំ ១៨៣២ ទំព័រ ១នៅក្នុង *JSP,* H១:១០; គោលលទ្ធិ និងសេចក្ដីសញ្ញា ២៧:១២–១៣ (វិវរណៈប្រហែលខែសីហា ឆ្នាំ ១៨៣០នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣ ឆ្នាំ ១៨៣៥ កំណែនៅ josephsmithpapers.org ); Oliver Cowdery to Phineas Young ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៨៤៦បណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ «Joseph Smith Documents Dating through June 1831» នៅក្នុង *JSP,* D១:xxxvii–xxxix សូមមើលផងដែរ Cannon and others, « Priesthood Restoration Documents » ទំព័រ ១៦៣–២០៧ ។ **ប្រធានបទ ៖** Restoration of the Melchizedek Priesthood

២០. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ២៧នៅក្នុង *JSP,* H១:៣២៦–២៨ ( សេចក្ដីពង្រាង ២ ) ។

២១. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៣៧នៅក្នុង *JSP,* H១:៣៦៤ ( សេចក្ដីពង្រាង ២ ); Stevenson, Journal ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៨៧៧; ថ្ងៃទី ២ ខែ មករា ឆ្នាំ ១៨៨៧; An Act to Provide for the Incorporation of Religious Societies ( ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៨១៣ ), *Laws of the State of New-York* (ឆ្នាំ ១៨១៣) , ២:២១២–១៩ ។ **ប្រធានបទ ៖** Founding Meeting of the Church of Christ

២២. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៣៧–៣៨នៅក្នុង *JSP,* H១:៣៦៤–៧១ ( សេចក្ដីពង្រាង ២ ) ។

២៣. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៣៧នៅក្នុង *JSP,* H១:៣៦៦; គោលលទ្ធិ និង សេចក្ដីសញ្ញា ២១ (វិវរណៈ ថ្ងៃទី ៦ខែ មេសា ឆ្នាំ ១៨៣០នៅ josephsmithpapers.org); « History of Joseph Smith » *Times and Seasons,* ថ្ងៃទី ១ ខែតុលា ឆ្នាំ ១៨៤២ ទំព័រ ៣:៩២៨–២៩ ។

២៤. Lucy Mack Smith, History ឆ្នាំ ១៨៤៤–៤៥ សៀវភៅ ៩ [ ទំព័រ ១២ ]; Knight, Reminiscences ៨; សូមមើលផងដែរ Bushman, *Rough Stone Rolling* ទំព័រ ១១០ ។

២៥. Joseph Smith History ឆ្នាំ ១៨៣៨–៥៦ ភាគ A-១ ទំព័រ ៣៨នៅក្នុង *JSP,* H១:៣៧២ ( សេចក្ដីពង្រាង ២ ) Joseph Smith «Latter Day Saints» នៅក្នុង Rupp, *He Pasa Ekklesia,* ទំព័រ ៤០៤–៥ នៅក្នុង *JSP,* H១:៥០៦ ។

២៦. Knight, Reminiscences, ទំព័រ ៧ ។



**ដោយអែលឌើរ**
**ឃ្វីនធិន អិល យុក**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណា

*ភាគថ្មីជាច្រើនស្ដីពីប្រវត្តិសាសនាចក្រនឹងជួយយើងឲ្យរក្សាសេចក្ដីសញ្ញារបស់យើង តាមរយៈការពង្រីកការចងចាំរបស់យើងអំពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់ពួកយើង ។*

នៅគ្រាដំបូងក្នុងរយៈពេលជិតមួយរយឆ្នាំ នោះភាគថ្មីជាច្រើនស្ដីពីប្រវត្តិសាសនាចក្រ ត្រូវបានបោះពុម្ពផ្សាយក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ដែលមានចំណងជើងថា *ពួកបរិសុទ្ធ ៖ ដំណើររឿងអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយ* ប្រវត្តិនិទានកថានេះប្រាប់រឿងពិតអំពីមនុស្សសាមញ្ញដែលបានក្លាយជាពួកបរិសុទ្ធ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ( សូមមើល ម៉ូសាយ ៣:១៩ ) ។ ភាគទីមួយ *បទដ្ឋាននៃសេចក្ដីពិត ១៨១៥–១៨៤៦* ឥឡូវនេះត្រូវបានបញ្ចប់ ហើយបកប្រែជា ១៤ ភាសាសម្រាប់ការបោះពុម្ពចែកផ្សាយដល់តំបន់ជាច្រើននៃពិភពលោក ។

សៀវភៅ *ពួកបរិសុទ្ធ* គឺជាដំណើររឿងស្ដីពីរបៀបដែលព្រះបានស្ដារសេចក្ដីពិតអស់កល្បជានិច្ចរបស់ទ្រង់ ដោយសារតែសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះបុត្រាបុត្រីរបស់ទ្រង់ ។ វាបង្ហាញអំពីរបៀបដែលព្រះអម្ចាស់បានស្ដារដំណឹងល្អរបស់ទ្រង់ ដើម្បីប្រទានសេចក្ដីសង្ឃឹម និងភាពសុខសាន្តនៅក្នុងគ្រាដ៏ស្មុគស្មាញ ការសាកល្បង និងការរងទុក្ខ ។ វាក៏បង្ហាញអំពីរបៀបដែលសេចក្ដីសញ្ញាដែលបានស្ដារឡើងវិញ ដឹកនាំទៅរកភាពតម្កើងឡើងតាមរយៈព្រះយេស៊ូវគ្រីស្ទផងដែរ ។

អ្នកអាចរំពឹងគិតថា ដំណើររឿងនេះចាប់ផ្ដើមជាមួយនឹងយ៉ូសែប ស្ម៊ីធ ប៉ុន្តែសៀវភៅ *ពួកបរិសុទ្ធ* ចាប់ផ្ដើមនៅក្នុងឆ្នាំ ១៨១៥ ជាមួយនឹងបន្ទុះភ្នំភ្លើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលបានបណ្ដាលឲ្យមានការស្លាប់ ជំងឺ និងផលប៉ះពាល់ជា


SANTOS
1815–1846
EL
ESTANDARTE
DE LA VERDAD

*តាមរយៈព្យាការីរបស់ទ្រង់ ព្រះបានរំឭកសេចក្ដីសញ្ញាថា កុំឲ្យកម្ចាត់អំពើអាក្រក់ ទុក្ខព្រួយ ការរងទុក្ខ និងបែកចេញពីគ្នានៅពេលមរណៈឡើយ ប៉ុន្តែសន្យាប្រទានការព្យាបាលតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងអះអាងដល់យើងថា ទំនាក់ទំនងអាចបន្តមានរហូតដល់អស់កល្បជានិច្ច ។*



សកល ។ ចំណុចចាប់ផ្ដើមនេះត្រូវបានជ្រើសរើសនៅក្នុងពន្លឺនៃអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងអំពីរបៀបដែលទ្រង់បានស្ដារសេចក្ដីសញ្ញា ដែលចងភ្ជាប់ពួកយើងទៅនឹងព្រះអង្គសង្គ្រោះ ហើយធ្វើឲ្យយើងយកឈ្នះលើបញ្ហាទាំងអស់ក្នុងជីវិត ។

« យើងជាព្រះអម្ចាស់ដោយជ្រាបនូវគ្រោះដែលនឹងមានមកលើ បណ្ដាជនទាំងឡាយនៅលើផែនដីនោះបានហៅ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រជាអ្នកបម្រើរបស់យើង ហើយបាននិយាយមកកាន់លោកពីលើស្ថានសួគ៌ ហើយបានប្រទានព្រះបញ្ញត្តិទាំងឡាយដល់លោក . . .

ដើម្បីឲ្យសេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ចរបស់យើងអាចបានតាំងឡើង » ( គ. និង ស. ១:១៧, ២២ ) ។

ចេញមកពីការបើកឆាកនៃច្បាប់ចេញផ្សាយនេះរហូតដល់ការបោះពុម្ពចែកផ្សាយរបស់វាទូទាំងពិភពលោក នោះសៀវភៅ *ពួកបរិសុទ្ធ* ផ្ដល់សញ្ញាបង្ហាញដល់បុត្រាបុត្រីរបស់ព្រះគ្រប់ទីកន្លែងថា វាជាដំណើររឿងនៃសេចក្ដីសញ្ញារបស់ពួកគេជាមួយព្រះ ដែលត្រាស់ដឹងអំពីសេចក្ដីលំបាករបស់ពួកគេ ។ តាមរយៈព្យាការីរបស់ទ្រង់ ព្រះបានរំឭកសេចក្ដីសញ្ញាថា កុំឲ្យកម្ចាត់អំពើអាក្រក់ ទុក្ខព្រួយ ការរងទុក្ខ និងបែកចេញពីគ្នានៅពេលមរណៈឡើយ ប៉ុន្តែសន្យាប្រទានការព្យាបាលតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះញែកចេញជាបរិសុទ្ធ និងផ្ដល់ដល់ជីវិតរបស់យើងនូវអត្ថន័យដ៏មហស្ចារ្យ និងអះអាងដល់យើងថា ទំនាក់ទំនងដែលយើងរីករាយនៅលើផែនដីនេះអាចបន្តមានរហូតដល់អស់កល្បជានិច្ច « រួបរួមដោយសិរីល្អដ៏នៅអស់កល្បជានិច្ច » ( សូមមើល គ. និង ស. ១៣០:២ ) ។

ជំពូកទាំងប្រាំបីដំបូងនៃ *បទដ្ឋាននៃសេចក្ដីពិត* ត្រូវបានបោះពុម្ពផ្សាយនៅក្នុងច្បាប់ចេញផ្សាយនៃទស្សនាវដ្ដីនេះពេញមួយឆ្នាំ ។ ច្បាប់ចេញផ្សាយខែនេះ រួមមាននូវសេរីនៃជំពូកមកពីសៀវភៅ *ពួកបរិសុទ្ធ* ប៉ុន្តែដំណើររឿងបន្តមាននៅគេហទំព័រ **saints.lds.org** នៅក្នុងកម្មវិធី Gospel Library និងនៅក្នុងការបោះពុម្ព ( បញ្ជាទិញតាមរយៈគេហទំព័រ **store.lds.org** ) ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យបន្តអានវានៅក្នុងបណ្ដាញទាំងនេះ ។

**លំនាំ និងផែនការរបស់ព្រះ**

សៀវភៅ *ពួកបរិសុទ្ធ* បន្តលំនាំរបស់ព្រះដែលពួកព្យាការីប្រើប្រាស់ពេលអតីតកាលដែលជាផ្នែកនៃការងារបម្រើរបស់ពួកលោក ដើម្បីជួយយើងរៀនអំពីរបៀបដែលយើងជានរណា និងឃើញគោលបំណងរបស់ព្រះនៅក្នុងជីវិតរបស់យើង ។ នៅក្នុងព្រះគម្ពីរ ពួកព្យាការីជាច្រើនចាប់ផ្ដើមការបង្រៀនរបស់ពួកលោក

តាមរយៈការដំណាលរឿងនានាអំពីសេចក្ដីមេត្តាករុណារបស់ព្រះចំពោះជីដូនជីតារបស់ពួកគេ ។[១] ម៉ូរ៉ូណៃបានដាស់តឿនអ្នកអានព្រះគម្ពីរមរមនឲ្យ « នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណា » ពេញមួយប្រវត្តិសាស្ត្រ « ហើយសូមរំពឹងគិតនៅក្នុងចិត្តអ្នកចុះ » ( ម៉ូរ៉ូណៃ ១០:៣ ) ។ ការសញ្ជឹងគិតអំពីសេចក្ដីល្អរបស់ព្រះរៀបចំយើងឲ្យទទួលទីបន្ទាល់អំពីព្រះវិញ្ញាណ ដែលបង្រៀនយើង « អំពីរឿងទាំងឡាយ តាមដែលមាននៅពេលនេះ ហើយអំពីរឿងទាំងឡាយ តាមដែលនឹងមាននៅពេលខាងមុខ » ( យ៉ាកុប ៤:១៣ សូមមើលផងដែរ ម៉ូរ៉ូណៃ ១០:៤–៥ ) ។

ការដឹងថា ព្រះមាតាបិតាសួគ៌របស់យើងបានដាក់ផែនការសម្រាប់សុភមង្គល និងភាពតម្កើងឡើងដ៏សំខាន់បំផុតរបស់យើង ផ្ដល់ឲ្យយើងនូវទស្សនវិស័យ ផ្ដល់អត្តសញ្ញាណដល់យើងក្នុងនាមជាបុត្រាបុត្រីជាទីស្រឡាញ់នៃព្រះមាតាបិតាសួគ៌ ហើយបង្កើនទំនុកចិត្តរបស់យើងលើព្រះអម្ចាស់ ទោះបីជានៅគ្រានៃទុក្ខវេទនាក្ដី ។ ការចងចាំអំពីសេចក្ដីល្អនៃព្រះអម្ចាស់ក៏អាចជួយការពារយើងប្រឆាំងភាពឆ្មើងឆ្មៃ និងគ្រោះថ្នាក់នៃភាពចម្រុងចម្រើន ។ មរមនបានសរសេរអំពីគ្រាមួយ នៅពេលពួកសាសន៍នីហ្វៃ « ចាប់ផ្ដើមដុះដាល មានទ្រព្យច្រើនជាអតិបរមា » ។ ប៉ុន្តែពុំដូចជាគ្រាផ្សេងទៀតនៅក្នុងព្រះគម្ពីរមរមនឡើយ នៅពេលប្រជាជនបានអនុញ្ញាតឲ្យភាពឆ្មើងឆ្មៃ និងទ្រព្យសម្បត្តិនាំឲ្យពួកគេធ្លាក់ចុះ នោះពួកគេបានដើរតាមផ្លូវមួយផ្សេងទៀតនាលើកនេះ ៖ « ប៉ុន្តែទោះជាគេមានទ្រព្យដ៏ស្ដុកស្ដម្ភ ឬមានកម្លាំង ឬមានការចម្រើនក្ដី គង់តែពួកគេពុំលើកខ្លួនឡើងក្នុងការឆ្មើងឆ្មៃនៃភ្នែករបស់គេទេ ហើយពួកគេក៏មិនកម្រនឹកឃើញដល់ព្រះអម្ចាស់ជាព្រះរបស់ពួកគេដែរ ប៉ុន្តែពួកគេបានបន្ទាបខ្លួនជាខ្លាំងនៅចំពោះទ្រង់ » ។ ពួកគេបានរក្សាសេចក្ដីសញ្ញារបស់ខ្លួន ហើយបន្តនៅសុចរិត ដោយសារ « ពួកគេបាននឹកឃើញដល់កិច្ចការដ៏អស្ចារ្យទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើដើម្បីពួកគេ » ( សូមមើល អាលម៉ា ៦២:៤៨–៥០ ) ។

សៀវភៅ *ពួកបរិសុទ្ធ* បង្រៀនមេរៀនដូចគ្នានេះ និងអ្វីៗជាច្រើនទៀត ។ សៀវភៅនេះនឹងជួយអ្នកឲ្យឃើញជំនួយរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកដកបទពិសោធន៍ដោយប្រយោលអំពីការសាកល្បងនៃសេចក្ដីជំនឿ ការឈឺចាប់ និងអំណារ វិវរណៈ និងដំណោះស្រាយនៃមនុស្សដែលមិនល្អឥតខ្ចោះដែលស្រឡាញ់ព្រះអម្ចាស់ និងទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ។

នៅពេលអ្នកអាន អ្នកនឹងរកឃើញការយល់ដឹង និងអត្ថន័យថ្មីៗ ទោះបីនៅក្នុងរឿងដែលអ្នកធ្លាប់ឮពីមុនក្ដី ។ គ្មានឆុតឆាកណានៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រដែលគេស្គាល់ប្រសើរជាងការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ ឡើយ ប៉ុន្តែសៀវភៅ *ពួកបរិសុទ្ធ* ជួយយើងឲ្យយល់កាន់តែច្បាស់អំពីរបៀបដែលយ៉ូសែបពុះពារដោះស្រាយនូវអ្វីដែលលោកមាននៅក្នុងចិត្តលោកជាមួយអ្វីដែលលោកបានគិតនៅក្នុងគំនិតលោក ។

បំណងប្រាថ្នាដ៏ស្មោះត្រង់របស់យ៉ូសែបដើម្បីទទួលការអភ័យទោសពីព្រះអង្គសង្គ្រោះពុំបានបំពេញឡើយ ដោយសារលោកបានសង្កេតឃើញថា គ្មានព្រះវិហារណាមួយបង្រៀន « ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដូចមានកត់ត្រានៅក្នុងព្រះគម្ពីរសញ្ញាថ្មីឡើយ » ។[២] នៅក្នុងចិត្តរបស់លោក យ៉ូសែបបានពិចារណាថា តើព្រះវិហារណាមួយត្រឹមត្រូវ ឬព្រះវិហារទាំងនោះសុទ្ធតែខុសទាំងអស់ ។ ក្នុងចិត្តរបស់លោក លោកបានសង្ឃឹមយ៉ាងខ្លាំងថា ពិតជាមានព្រះវិហារណាមួយពិត ដើម្បីគាត់អាចរកឃើញភាពសុខសាន្តដែលគាត់ស្វែងរក ។ ជាមួយនឹងគំនិត និងដួងចិត្តដែលត្រូវគ្នា នោះយ៉ូសែបបានដឹងថា លោកអាចទូលសួរព្រះ ។ លោកបានទៅព្រៃដើម្បីអធិស្ឋាន ។ នៅទីនោះ លោកបានឃើញព្រះវរបិតា និងព្រះរាជបុត្រា ដែលបានអភ័យទោសឲ្យលោក ហើយបានដោះស្រាយទុគ្គោះរបស់លោកក្នុងរបៀបមួយដែលលោកពុំធ្លាប់ស្រមៃដល់ ។[៣]



*សៀវភៅ ពួកបរិសុទ្ធ បង្ហាញថា ការដឹងអំពីទំនាក់ទំនងនៃព្រះអម្ចាស់ ផ្ដល់ទស្សនវិស័យអស់កល្បជានិច្ចដល់យើង ជួយយើងឲ្យឃើញនូវអ្វីៗតាមដែលមាននៅពេលនេះ និងមាននៅពេលខាងមុខ ហើយជួយពួកគេឲ្យអនុវត្តសេចក្ដីជំនឿថា ព្រះអម្ចាស់នឹងទតឃើញយើងតាមរយៈគ្រាលំបាកនានា ។*



យ៉ូសែប ក្រុមគ្រួសាររបស់លោក និងមនុស្សជាច្រើនផ្សេងទៀតដែលទទួលយកសេចក្ដីសញ្ញាដែលស្ដារឡើងវិញរបស់ព្រះអម្ចាស់ ចង់ទទួលសេចក្ដីស្រឡាញ់របស់ព្រះសម្រាប់ពួកគេ រៀនអំពីរបៀបដែលពួកគេអាចខិតកាន់តែជិតទ្រង់ និងព្យាបាលទំនាក់ទំនងជាមួយមនុស្សជាទីស្រឡាញ់ ។ សៀវភៅ *ពួកបរិសុទ្ធ* ប្រាប់អំពីរឿងរបស់ពួកគេ ។

**ការទុកចិត្តលើព្រះអម្ចាស់អំឡុងគ្រាសាកល្បង**

ភាគទី ១ នៃសៀវភៅ *ពួកបរិសុទ្ធ* រួមមានរឿងដ៏រំជួលចិត្តអំពី អាម៉ានដា បាណេស ស្ម៊ីធ និងគ្រួសាររបស់គាត់ ដែលគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយបានធ្វើតាមព្រះទ័យរបស់ទ្រង់ ។[៤] ស្វាមីរបស់អាម៉ានដា និងកូនប្រុសម្នាក់របស់គាត់ត្រូវបានគេសម្លាប់យ៉ាងឃោរឃៅជាមួយនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយ ១៥ នាក់ដទៃទៀត ដែលបានបោះជំរំនៅក្នុងការតាំងទីលំនៅតូចមួយនៅ ស្សូល គ្រិគ ក្នុងរដ្ឋមិសសួរី ។ ព្រះអម្ចាស់គាំទ្រអាម៉ានដាតាមរយៈបទពិសោធន៍ដ៏អាក្រក់នោះ បានឆ្លើយតបការអធិស្ឋានរបស់គាត់ បានប្រទានភាពក្លាហាន និងធ្វើឲ្យគាត់អាចព្យាបាលកូនប្រុសដែលមានរបួសដ៏ធ្ងន់ធ្ងររបស់គាត់ ។[៥]

សៀវភៅ *ពួកបរិសុទ្ធ* បង្ហាញអំពីរបៀបដែលអាម៉ានដាបានរៀនទុកចិត្តលើព្រះអម្ចាស់តាមរយៈសេចក្ដីវេទនាដ៏ខ្លាំងក្លា ។ សៀវភៅនេះក៏ប្រាប់នូវអ្វីដែលយ៉ូសែប ស្ម៊ីធ បានរៀនអំពីសេចក្ដីល្អនៃព្រះទោះបីនៅក្នុងគ្រានៃការរងទុក្ខក្ដី ។ សៀវភៅនេះបង្ហាញថា ការដឹងអំពីទំនាក់ទំនងនៃព្រះអម្ចាស់ ផ្ដល់ទស្សនវិស័យអស់កល្បជានិច្ចដល់យើង ជួយយើងឲ្យឃើញនូវអ្វីៗតាមដែលមាននៅពេលនេះ និងមាននៅពេលខាងមុខ ហើយជួយពួកគេឲ្យអនុវត្តសេចក្ដីជំនឿថា ព្រះអម្ចាស់នឹងទតឃើញយើងតាមរយៈគ្រាលំបាកនានា ។

នៅពេលព្យាការីយ៉ូសែបបានរៀនអំពីអ្វីដែលបានកើតឡើងចំពោះគ្រួសាររបស់អាម៉ានដា និងអ្នកដទៃទៀតនៅ ស្សូល គ្រិគ នោះលោកបានទទួលអារម្មណ៍ថា លោកគួរចូលគុក ឬត្រូវគេសម្លាប់ជាជាងទុកឲ្យពួកបរិសុទ្ធត្រូវបានគេប្រល័យចោល ។ នៅថ្ងៃបន្ទាប់ លោកបានព្យាយាមជជែកតវ៉ានូវដំណោះស្រាយដ៏សន្តិភាពមួយជាមួយទាហានរដ្ឋមិសសួរី ដែលប្រុងប្រៀបវាយប្រហារទីលំនៅសំខាន់របស់ពួកបរិសុទ្ធនៅ ហ្វា វេស ។ ផ្ទុយទៅវិញ យ៉ូសែបត្រូវបានចាប់ខ្លួន ហើយចាត់ទុកដូចជាអ្នកមានទោស ។

ជិតប្រាំខែក្រោយមក យ៉ូសែបបានបន្តនៅក្នុងការឃុំឃាំង បង្ខាំងនៅក្នុងភាពត្រជាក់ រមួលក្រពើក្នុងគុកនៅជាន់ក្រោមក្នុងគុកលីប៊ើធី រដ្ឋមិសសួរី ។ លោកបានឆ្ងល់ថា តើព្រះលាក់ព្រះកាយនៅឯណា ហើយតើលោកអាចទ្រាំនឹងស្ដាប់ការស្រែកយំរបស់ពួកស្ត្រីមេម៉ាយ និងក្មេងកំព្រាបានយូរប៉ុន្មានទៀត ។ លោកបានអធិស្ឋានថា « ឱព្រះអម្ចាស់អើយ តើពួកគេត្រូវរងទុក្ខចំពោះកំហុស និងការសង្កត់សង្កិនដ៏ខុសច្បាប់ទាំងនេះដល់ណាទៅមុនព្រះហឫទ័យរបស់ទ្រង់នឹងបាន

ទន់ទៅរកពួកគេ ហើយមុនព្រះអង្គមានចិត្តក្តួលដោយសេចក្តីមេត្តាករុណាដល់ពួកគេ ? » ( គ. និង ស. ១២១:៣ ) ។

សៀវភៅ *ពួកបរិសុទ្ធ* បង្រៀនពួកយើងថា សេចក្តីវេទនាពុំមែនជាភស្តុតាងនៃការមិនពេញព្រះទ័យរបស់ព្រះ ឬការដកយកពរជ័យរបស់ទ្រង់ឡើយ ។ ការផ្ទុយគឺជាផ្នែកមួយនៃផែនការរបស់ព្រះ ដើម្បីបន្សុទ្ធយើង និងរៀបចំយើងសម្រាប់ជោគវាសនាសេឡេស្ទាលដ៏អស់កល្បមួយ ( សូមមើល នីហ្វៃទី ២ ២:១១ ) ។ យ៉ូសែបបានរៀនថា ការរងទុក្ខដ៏គ្មានដែនកំណត់របស់ព្រះអង្គសង្គ្រោះ ធ្វើឲ្យទ្រង់ជួយពួកយើងនៅពេលពួកយើងរងទុក្ខ ហើយទីបំផុតលើកតម្កើងយើង ( សូមមើល អាលម៉ា ៧:១១–១៣ ) ។ ក្នុងការឆ្លើយតបចំពោះការស្រែកយំអំពាវនាវដ៏ឈឺចាប់របស់យ៉ូសែប នោះព្រះអម្ចាស់បានរៀបរាប់នូវឧបសគ្គទាំងអស់ពីមុនបញ្ចប់ ៖

« បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះនឹងផ្តល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ ។

កូនមនុស្សបានចុះទាបជាងការណ៍ទាំងនោះទៅទៀត ។ តើអ្នកធំជាងទ្រង់ឬអី ? » ( គ. និង ស. ១២២:៧–៨ ) ។

ការដកបទពិសោធន៍នូវ *រឿងទាំងនេះ* ដោយខ្លួនយើងអាចផ្តល់ដល់យើងនូវសេចក្តីអាណិតអាសូរដូចជាព្រះគ្រីស្ទដល់អស់អ្នកដែលរងទុក្ខ ។ យ៉ូសែបបានដឹងអំឡុងពេលនៅក្នុងគុកថា « ចិត្តរបស់ខ្ញុំនឹងកាន់តែទន់ភ្លន់ជាងពីមុនជានិច្ចបន្ទាប់ពីរឿងនោះមក » ។ លោកប្រាថ្នាថា លោកអាចនៅជាមួយពួកបរិសុទ្ធដើម្បីលួងលោមនិងលួងចិត្តរបស់ពួកគេ ។ លោកបានពន្យល់ថា « ខ្ញុំពុំអាចមានអារម្មណ៍ដូចខ្ញុំមាននាគ្រានេះទេ ប្រសិនបើខ្ញុំពុំរងទុក្ខនូវកំហុសដែលខ្ញុំបានអត់ទ្រាំ » ។[៦]

ហេតុផលមួយដែលគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បង្គាប់និងអនុមតិ សៀវភៅ *ពួកបរិសុទ្ធ* នេះគឺថា វាអាចជួយយើងម្នាក់ៗឲ្យដកពិសោធន៍នូវ *រឿងទាំងនេះ* តាមរយៈរឿងរបស់មនុស្សដទៃ ។ យើងអាចរៀនមកពីអាម៉ានដាថា ទោះបីជាពេលដែលព្រះទតឃើញថា សក្តិសមនៅក្នុងព្រះប្រាជ្ញាដ៏គ្មានដែនកំណត់របស់ទ្រង់ដោយពុំរារាំងអំពើអាក្រក់ ឬការរងទុក្ខ នោះទ្រង់ស្រឡាញ់យើង ហើយទ្រង់ខ្វល់ព្រះទ័យពីយើង ។ ទ្រង់ស្តាប់ការអធិស្ឋានរបស់យើង ហើយមានក្តីមេត្តាករុណា និងមានព្រះទ័យល្អ ។

## បានស្តារឡើងវិញនូវពរជ័យព្រះវិហារបរិសុទ្ធ

គ្មានកន្លែងណាដែលសេចក្តីមេត្តា និងសេចក្តីសប្បុរសបង្ហាញដល់យើងច្រើនជាងនៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។ ចំណុចសំខាន់នៃសៀវភៅ *ពួកបរិសុទ្ធ* គឺជាដំណើររឿងនៃពរជ័យព្រះវិហារបរិសុទ្ធដែលបានស្តារឡើងវិញ ។ ភាគទីមួយបញ្ចប់នៅពេលពួកបរិសុទ្ធថ្ងៃចុងក្រោយរាប់ពាន់នាក់ទទួលពិធីបរិសុទ្ធពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធណៅវូក្នុងឆ្នាំ ១៨៤៦ ។ ភាគទីពីរនឹងបញ្ចប់នៅក្នុងការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធសលត៍ លេក ហើយពួកបរិសុទ្ធចាប់ផ្តើមទទួលពិធីបរិសុទ្ធនៅទីនោះក្នុងឆ្នាំ ១៨៩៣ ។ ភាគទីបីនឹងបញ្ចប់ជាមួយនឹងពួកបរិសុទ្ធនៅអឺរ៉ុបចាប់ផ្តើមប្រមូលផ្តុំគ្នាទៅព្រះវិហារបរិសុទ្ធនៅប្រទេសស្វីសក្នុងឆ្នាំ ១៩៥៥ ។ ភាគទីបួននឹងនាំមកនូវដំណើររឿងមកដល់សម័យបច្ចុប្បន្ន នៅពេលព្រះវិហារបរិសុទ្ធមានច្រើននៅលើផែនដី ហើយពួកបរិសុទ្ធនៅជុំវិញសកលលោកទទួលពិធីបរិសុទ្ធនៃភាពតម្កើងឡើង ដូចដែលពួកព្យាការីបានគិតឃើញកាលពីយូរលង់ណាស់មកហើយ ។

នៅក្នុងដំណាក់នៃព្រះអម្ចាស់ យើងចុះសេចក្តីសញ្ញា ហើយទទួលអំណាចដើម្បីឈ្នះលើឥទ្ធិពលនៃការធ្លាក់ រួមទាំងអំពើអាក្រក់ និងការរងទុក្ខនៅក្នុងពិភពលោកនេះ ។ យើងទទួលការការពារ និងអំណាចដ៏ខ្លាំងក្លាដើម្បីចេញមកនៅក្នុងដំណើររស់ឡើងវិញ ផ្សារភ្ជាប់ជាមួយមនុស្សជាទីស្រឡាញ់ជារៀងរហូត ។

សៀវភៅ *ពួកបរិសុទ្ធ* នឹងជួយយើងឲ្យរក្សាសេចក្តីសញ្ញាតាមរយៈការពង្រីកការចងចាំរបស់យើងនៅក្នុងរបៀបនៃពិធីសាក្រាម៉ង់ ។ វានឹងជួយយើងឲ្យចងចាំជានិច្ចនូវអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់យើង ? បើគ្មានកំណត់ត្រាពីទំនាក់ទំនងរបស់ព្រះកាលពីអតីតកាល នោះយើងពុំអាច « នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណាដល់កូនចៅមនុស្ស » នោះទេ ( មរ៉ូណៃ ១០:៣ ) ។ ដោយសារហេតុផលទាំងនេះហើយ យើងជំពាក់គុណព្រះអម្ចាស់ និងពួកបរិសុទ្ធដែលបានកត់ត្រាបទពិសោធន៍របស់ពួកគេអំពីសេចក្តីស្រឡាញ់របស់ទ្រង់ដល់ពួកគេ ។ ព្រះអម្ចាស់បានបង្គាប់ឲ្យយ៉ូសែប ស្ម៊ីធ កត់ត្រាបទពិសោធន៍របស់លោក ( សូមមើល គ. និង ស. ២១:១ ) ។ ទ្រង់បានបង្គាប់ឲ្យអ្នកប្រវត្តិសាស្ត្រសាសនាចក្រធ្វើការក្រោមការដឹកនាំរបស់យ៉ូសែបដើម្បី « ឲ្យកត់បញ្ជី និងប្រវត្តិសាសនាចក្រជានិច្ច » ( គ. និង ស. ៤៧:៣ ) ។ ទ្រង់បានបង្គាប់ថា ប្រវត្តិសាស្ត្ររួមមាន « គ្រប់ទាំងអស់ ដែលនឹងទៅជាការល្អដល់សាសនាចក្រ និងដល់តំណមនុស្សមានវ័យធំឡើង » ( គ. និង ស. ៦៩:៨ ) ។

ជាមួយនឹងវិវរណៈទាំងនេះ និងសេចក្តីសញ្ញាដើម្បីចងចាំព្រះអង្គសង្គ្រោះជានិច្ចនៅក្នុងចិត្ត នោះគណៈប្រធានទីមួយ និងពួកសាវកដប់ពីរនាក់បានចាប់ផ្តើមដាក់ផែនការអំពីសៀវភៅ *ពួកបរិសុទ្ធ* តាំងពី ១០ ឆ្នាំមុន ។ ឥឡូវនេះ យើងសូមលើកទឹកចិត្តអ្នកឲ្យអានវា ដោយទុកចិត្តថា វានឹងជួយអ្នកនៅក្នុងការយល់ដឹងអំពីផែនការរបស់ព្រះឲ្យឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណា ឲ្យស៊ូទ្រាំដោយស្មោះត្រង់នៅក្នុងគ្រាល្អ និងគ្រាអាក្រក់ ឲ្យទទួលបានសេចក្តីអាណិតអាសូរដូចជាព្រះគ្រីស្ទសម្រាប់មនុស្សដទៃ និងរក្សាសេចក្តីសញ្ញាដែលនាំអ្នកឆ្ពោះទៅរកភាពតម្កើងឡើង ។ ■

**កំណត់ចំណាំ**

១. គំរូមមាននីហ្វៃ ( នីហ្វៃទីទី ១ ១៧:២៣–៤៣ ), ស្តេចបេនយ៉ាមីន ( ម៉ូសាយ ១ ), លិមហៃ ( ម៉ូសាយ ៧ ), ទេវតាមួយអង្គរបស់ព្រះអម្ចាស់ចំពោះអាលម៉ា ( ម៉ូសាយ ២៧ ), អាលម៉ា ( អាលម៉ា ៩:១០ ), មរមន ( មរមន ៣:១៧–២២ ), និង ម៉ូសេ ( និក្ខមនំ ១៣:៣ ) ។
២. យ៉ូសែប ស្ម៊ីធ នៅក្នុង « History, circa Summer 1832 » ទំព័រ ២ josephsmithpapers.org ។
៣. សូមមើល « History, 1838–1856, volume A-1 [ 23 December 1805–30 August 1834 ] » ទំព័រ ៣ josephsmithpapers.org ។
៤. សូមមើល « Revelation, 12 January 1838–C » [ ១ ] josephsmithpapers.org ។
៥. សូមមើល Saints ភាគ ១ ជំពូក ៣០ « Fight Like Angels » ។
៦. « Letter to Presendia Huntington Buell, 15 March 1839 » [ ១ ] josephsmithpapers.org ។

# ស៊ុត ហ្វ៊ុយហ្ស៊ីប និងសេចក្ដីជំនឿ

គោលដៅមួយរបស់យើងជាគ្រួសារគឺសន្សំប្រាក់គ្រាប់គ្រាន់ដើម្បីបង់ប្រាក់កក់យកផ្ទះផ្ទាល់ខ្លួនរបស់យើង ។ ប្រសិនបើគ្មានគោលដៅនេះទេ ខ្ញុំប្រហែលជាចំណាយពេលឥតប្រយោជន៍នៅចុងសប្ដាហ៍មើលទូរទស្សន៍ ដោយទន្ទឹងចាំមើលឱកាសហិរញ្ញវត្ថុកើតមានចំពោះខ្ញុំ ។

ក្នុងនាមជាអ្នកបើកបរឲ្យក្រុមហ៊ុនដឹកជញ្ជូនមួយនៅក្នុងប្រទេសឈីលីភាគខាងជើង ខ្ញុំធ្វើការនៅឆ្ងាយពីផ្ទះរយៈពេលបួនថ្ងៃនៅឯអណ្ដូងរ៉ែ ហើយបន្ទាប់មកមានថ្ងៃឈប់សម្រាកបីថ្ងៃ — ថ្ងៃសៅរ៍រហូតដល់ថ្ងៃចន្ទ ។ ដើម្បីបន្ថែមប្រាក់ចំណូល និងប្រាក់សន្សំដើម្បីទិញផ្ទះ យើងបានសម្រេចចិត្តចាប់ផ្ដើមលក់ស៊ុត ។ គម្រោងរបស់យើងគឺលក់ស៊ុតឲ្យមិត្តភក្ដិ អ្នកជិតខាង និងសមាជិកសាសនាចក្ររបស់យើង ដោយយើងទិញស៊ុតប្រហែលជា ១០០០ ស៊ុតរៀងរាល់សប្ដាហ៍មកពីអ្នកលក់ដុំម្នាក់ បន្ទាប់មកទៅដឹកវា ហើយចែកចាយស៊ុតនោះនៅថ្ងៃសៅរ៍ និងថ្ងៃចន្ទ ។

ឡូរ៉ាភរិយារបស់ខ្ញុំ និងខ្ញុំបានសម្រេចចិត្តថា យើងនឹងយកកូនពីរនាក់របស់យើងទៅជាមួយយើងពេលចែកចាយ ហើយមានពេលរីករាយជាមួយគ្នា ។ ប៉ុន្តែនៅពេលយើងនៅតាមផ្លូវទៅទិញស៊ុតជាលើកដំបូងរបស់យើង ឡានយើងបានខូច ។ ដោយលេងជាមួយប្រដាប់ខួងខ្មៅដៃដែកដ៏តូចមួយ នោះកូនម្នាក់របស់យើងបានបោះប្រដាប់ខួងនោះ ហើយវាបានធ្លាក់ចំត្រង់កន្លែងដាក់ដែកកេះដក់បារីទទេ ។ ផ្កាភ្លើងបានខ្ទាតឡើងមក ហើយឡានរបស់យើងបានដាច់ភ្លើងទាំងអស់ ធ្វើឲ្យឡានឈប់ងក់ភ្លាមនៅចំកណ្ដាលទ្រូងផ្លូវធំមួយ ។ ឡានយើងបានដាច់ហ្វ៊ុយហ្ស៊ីប ។



នៅពេលប្រដាប់ខួងខ្មៅដៃដែកតូចមួយបានធ្លាក់ចូលចំក្នុងកន្លែងដាក់ដែកកេះដក់បារីទទេ នោះឡានរបស់យើងស្រាប់តែខូចភ្លាម ។ ឡានយើងបានដាច់ហ្វ៊ុយហ្ស៊ីប ។

នៅពេលយើងអង្គុយនៅទីនោះដោយធ្វើឲ្យកកស្ទះចរាចរណ៍ ហើយមិនដឹងជាធ្វើដូចម្ដេច នោះយើងមានភាពស្មុគស្មាញជាខ្លាំងដែលធ្វើឲ្យយើងមានអារម្មណ៍ចង់យំ ។ ប៉ុន្តែនៅគ្រានោះ ខ្ញុំបានចាំថា ព្រះអម្ចាស់បានសន្យាថា លើកយើងឡើង និងជួយយើង ប្រសិនបើយើងដាក់ទីទុកចិត្តរបស់យើងលើទ្រង់ ។ ភាពស្ងប់សុខបានកើតមានមកលើខ្ញុំ ។ ខ្ញុំបានដឹងថា ខ្ញុំពុំអាចគ្រាន់តែអង្គុយនៅទីនោះ ហើយរអ៊ូរទាំឡើយ ។ យើងមានបញ្ហា ហើយដោយមានជំនួយពីព្រះ នោះយើងអាចដោះស្រាយវាបាន ។

ឡូរ៉ា និងខ្ញុំបានបែរមើលមុខគ្នា ហើយនិយាយថា « យើងត្រូវតែបង្ហាញសេចក្ដីជំនឿ » ។ យើងបានអធិស្ឋាន ហើយជូតទឹកភ្នែករបស់ពួកយើង ។ បន្ទាប់មក ខ្ញុំចេញទៅក្រៅដើម្បីរុញឡាន ហើយឡូរ៉ាកាច់ចង្កូត ។ មនុស្សមួយចំនួនចេញមកពីឡានរបស់ពួកគេ ហើយជួយរុញឡានខ្ញុំ ។

យើងបានរុញឡានប្រហែលជា ២០០ ម៉ែត្រ ពីមុនយើងអាចរកឃើញកន្លែងសុវត្ថិភាពមួយចេញពីផ្លូវធំនោះដើម្បីចត ។ នៅពេលឡានបានរំកិលទៅកន្លែងឈប់មួយ ខ្ញុំឃើញថា យើងបានចតឡាននៅផ្នែកខាងស្ដាំនៅពីមុខហាងឡានស្ទើរអូ ។

ខ្ញុំបានរកទីតាំងហ្វ៊ុយហ្ស៊ីបដែលខូចនោះ ហើយដើរទៅក្នុងហាងរួចសួរថា « តើអ្នកមានលក់អានេះទេ ? »

អ្នកលក់បានតបថា « មាន » ។

ខ្ញុំបានទិញហ្វ៊ុយហ្ស៊ីបមួយ ហើយដាក់វានៅកន្លែងវាវិញ ឡានបានឆេះឡើងវិញ ហើយយើងបានចេញដំណើរទៅមុខទៀត ។ អ្នកលក់ស៊ុតនោះនៅជិតកន្លែងដែលយើងទើបតែបើកឡានចេញទៅនោះ ។ យើងបានទិញស៊ុត ហើយដឹកយកទៅឲ្យគេ ។

ពេលយើងមានឧបសគ្គ យើងត្រូវតែចងចាំទូលសូមជំនួយពីព្រះវរបិតាសួគ៌របស់យើង ។ ខ្ញុំដឹងថា ទ្រង់នឹងឆ្លើយតបយើង នៅពេលយើងបន្តឆ្ពោះទៅមុខ ហើយបង្ហាញសេចក្ដីជំនឿរបស់យើងលើទ្រង់ ។ ■

អាលវ៉ារ៉ូ អាលសៀណូ ទីក្រុងអានតូហ្វាហ្គាស្ដា ប្រទេស ឈីលី

រចនារូបភាពដោយ ខារ៉ូលីន វីបបើត

# ពរជ័យមួយនៅក្នុងសំណេរដោយរបស់ម្ដាយខ្ញុំ

ល្ងាចមួយ ខ្ញុំកំពុងពិចារណាអំពីសារលិខិតដែលត្រូវនិយាយនៅក្នុងសន្និសីទវួដនាពេលខាងមុខ ។ ខ្ញុំបានសិក្សាព្រះគម្ពីរពេញមួយសប្ដាហ៍ ហើយទោះបីជាខ្ញុំបានទទួលការណែនាំ និងការយល់ដឹងដ៏អស្ចារ្យក្ដី ខ្ញុំនៅតែពុំមានការណែនាំច្បាស់លាស់អំពីអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យខ្ញុំថ្លែងទៅកាន់សមាជិកវួដក្នុងនាមជាប្រធានស្តេក ។

ក្នុងការអធិស្ឋានដ៏ស្មោះត្រង់របស់ខ្ញុំ ខ្ញុំបានទូលសូមការណែនាំមកពីព្រះវិញ្ញាណដើម្បីដឹកនាំគំនិតរបស់ខ្ញុំ ។ បន្ទាប់មក ខ្ញុំបានបើកព្រះគម្ពីរ ហើយចាប់ផ្ដើមអានវាម្ដងទៀត ។ រំពេចនោះ ចិត្តរបស់ខ្ញុំបានបែរទៅរកគោលដៅវួដរបស់យើងដែលប៊ីស្សព និងខ្ញុំទើបតែបានពិភាក្សាគ្នា ។ គោលដៅមួយនោះគឺការប្រើសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* នៅក្នុងការចែកចាយដំណឹងល្អជាមួយមិត្តភក្ដិ និងអ្នកជិតខាង ។

ខ្ញុំបានទទួលអារម្មណ៍សង្កត់ធ្ងន់ឲ្យបញ្ចូលសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ខ្ញុំនាល្ងាចនោះ ។ ខ្ញុំបានទាញយកសៀវភៅនោះមួយក្បាលចេញមក ហើយបើកវាទៅដោយមិនដឹងទំព័រទេ ។ នៅក្នុងទំព័រមួយ ខ្ញុំបានឃើញខគម្ពីរយោងពីរដែលសរសេរដោយដៃ — នីហ្វៃទី ១ ៨:៨–១១ និង នីហ្វៃទី ១ ១១:២១–២២ ។ នៅពេលខ្ញុំមើលជិត ខ្ញុំបានដឹងថា ខគម្ពីរយោងទាំងនោះគឺជាអក្សររបស់ម្ដាយខ្ញុំ ។ ម្ដាយដ៏ជាទីស្រឡាញ់របស់ខ្ញុំបានចែកឋានទៅអស់ជាច្រើនឆ្នាំមកហើយ គឺពីរខែបន្ទាប់ពីខួបកំណើតទី ៨០ ឆ្នាំរបស់គាត់ ។ គាត់គឺជាគំរូមួយនៃភាពក្លាហាន និងភាពមិនអាត្មានិយម ដែលមើលឃើញសេចក្ដីល្អនៅក្នុងមនុស្សជានិច្ច ។ ហើយគាត់ស្រឡាញ់ព្រះគម្ពីរ ។

ខ្ញុំបានបើកព្រះគម្ពីររកខគម្ពីរទាំងនោះ ដើម្បីដឹងថា តើមានអ្វីដែលបំផុសគំនិតឲ្យគាត់សរសេរវាទុក ។ នៅពេលខ្ញុំអានខគម្ពីរទាំងនោះ ស្រាប់តែគំនិតរបស់ខ្ញុំបានបើកភ្លាមទៅកាន់សារលិខិតដែលខ្ញុំគួរតែនិយាយ ។ វាគឺជាសារលិខិតសាមញ្ញដែលសមាជិកសាសនាចក្រ ដែលបានភ្លក់ផ្លែឈើដ៏ឆ្ងាញ់នៃដំណឹងល្អជួនកាលអាចភ្លេចថា មនុស្សដទៃជាច្រើនទៀតកំពុងស្វែងរកផ្លែឈើដូចគ្នានោះ ។ យើងត្រូវតែឈោងទៅរកពួកគេ ហើយប្រាប់ពួកគេអំពីកន្លែងដើម្បីស្វែងរកវា ។

ខ្ញុំបានគិតអំពីម្ដាយជាទីស្រឡាញ់របស់ខ្ញុំនៅពេលខ្ញុំមើលសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* ដល់ចប់ ។ គ្មានឈ្មោះ គ្មានកំណត់ចំណាំ ឬអ្វីទៀតដែលបង្ហាញថា សៀវភៅនេះគឺជាសៀវភៅរបស់គាត់ឡើយ ។ ខ្ញុំបានអង្គុយដោយប្លែកក្នុងចិត្ត នៅពេលខ្ញុំសញ្ជឹងគិតអំពីច្រវ៉ាក់ខាងវិញ្ញាណដ៏បំផុសគំនិត ដែលដឹកនាំឲ្យមកដល់គ្រានេះ ។ ព្រះវិញ្ញាណបញ្ជាក់ដល់ខ្ញុំថា ខ្ញុំត្រូវបានដឹកនាំនៅក្នុងគំនិតខ្ញុំ គឺដូចជាអ្វីដែលខ្ញុំបានអធិស្ឋានទូលសូម ។ ម្ដាយខ្ញុំបានដឹងតិចតួច ប៉ុន្តែជាច្រើនឆ្នាំកន្លងទៅ គាត់បានសរសេរខគម្ពីរយោងទាំងនោះ ដែលព្រះអម្ចាស់នឹងប្រើវាដើម្បីឆ្លើយតបចំពោះការអធិស្ឋានដ៏រាបសារបស់កូនប្រុសគាត់ ។ ■

ដាកឡាស ហេដហ្គើរ រដ្ឋណារ៉ាដា ស.រ.អា.

អំឡុងពេលរៀបចំសម្រាប់សន្និសីទវួដ ខ្ញុំបានបើកសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* ទៅកាន់ទំព័រមួយដែលមានខគម្ពីរយោងដែលម្ដាយរបស់ខ្ញុំបានសរសេរ ។




រូបគំនូរដោយ ឌីលើន ម៉ាស្ស

# អព្ភូតហេតុនៅក្នុងដំណាក់របស់ព្រះអម្ចាស់នៅគៀវ

គ្រួសារខ្ញុំ និងខ្ញុំមានចិត្តរំភើបរីករាយដើម្បីធ្វើដំណើរតាមឡានពីប្រទេសរូម៉ានីទៅគៀវ ប្រទេសអ៊ុយក្រែន សម្រាប់ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនៅខែ សីហា ឆ្នាំ ២០១០ ។ ដោយដឹងថា នេះគឺជាព្រះវិហារបរិសុទ្ធសម្រាប់ពួកបរិសុទ្ធនៅក្នុងបេសកកម្ម រូម៉ានី/មូលដូវ៉ា នោះយើងបានធ្វើដំណើររយៈពេល ១៤ ម៉ោងដើម្បីទៅកាន់ទីនោះ ។ ពេលយើងទៅដល់ យើងបានជួបក្រុមផ្សេងទៀតដែលបានធ្វើដំណើរមកពីប្រទេសរូម៉ានីផងដែរ ។ យើងទាំងអស់រីករាយដើម្បីនៅគៀវសម្រាប់ប្រព្រឹត្តិការណ៍ដ៏ពិសិដ្ឋនេះ ។

នៅថ្ងៃនៃការឧទ្ទិសឆ្លង ក្រុមរបស់យើងមកពីប្រទេសរូម៉ានី ត្រូវបានចាត់ឲ្យមើលការឧទ្ទិសឆ្លងនោះតាមរយៈការចាក់ផ្សាយនៅក្នុងបន្ទប់មួយនៅជាន់ផ្ទាល់ដីនៃព្រះវិហារបរិសុទ្ធ ។ មនុស្សមួយចំនួនបានបង្ហាញការខកចិត្តរបស់ពួកគេ ។ ពួកគេបានសង្ឃឹមថា បានចូលរួមនៅក្នុងការឧទ្ទិសឆ្លងជាមួយព្យាការីនៅក្នុងបន្ទាប់សេឡេស្ទាល ។ អ្នកខ្លះបាននិយាយថា ពួកគេអាចនៅផ្ទះ ហើយមើលការចាក់ផ្សាយនេះពីសាលាប្រជុំមួយនៅក្នុងប្រទេសរូម៉ានីវិញ ។

ខ្ញុំបានចាប់ផ្ដើមអធិស្ឋានក្នុងចិត្តខ្ញុំថា « ឱ ព្រះវរបិតាសួគ៌អើយ តើយើងអាចជួយសមាជិកទាំងនេះដែលមកពីប្រទេសរូម៉ានីឲ្យទទួលបានបទពិសោធន៍ដែលពុំអាចបំភ្លេចបាននៅក្នុងដំណាក់របស់ព្រះអង្គដូចម្ដេចទៅ ? »

ខ្ញុំនៅតែពុំបានទទួលចម្លើយនៅឡើយ នៅពេលសម័យប្រជុំឧទ្ទិសឆ្លងបានចាប់ផ្ដើម ។ រំពេចនោះយើងបានដឹងថា ព្យាការី ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) នឹងចុះមកខាងក្រោមហើយបញ្ចុះបឋមសីលាទៅកន្លែងរបស់វា ។ ប្រហែលនេះអាចជាចម្លើយរបស់ពួកយើង ! ខ្ញុំបានអធិស្ឋានទូលសូមរបៀបមួយឲ្យព្យាការីមក ហើយស្វាគមន៍ដល់ពួកបរិសុទ្ធរូម៉ានី ។

ខ្ញុំបានអធិស្ឋានថា « ខ្ញុំពុំបានទូលសូមការណ៍នេះសម្រាប់ខ្លួនខ្ញុំឡើយ ប៉ុន្តែសម្រាប់បងប្អូនប្រុសស្រីរបស់ខ្ញុំវិញ » ។

បន្ទាប់ពីពិធីបញ្ចុះបឋមសីលារួច ប្រធានម៉នសុនបានដើរក្បែរបន្ទប់របស់យើងដើម្បីត្រឡប់ទៅបន្ទប់



រចនារូបភាពដោយ អេលែន ហ្គានស៍

សេឡេស្ទាលវិញ ។ រំពេចនោះ ខ្ញុំមានអារម្មណ៍ក្នុងចិត្ត ថា ខ្ញុំគួរតែឈរ ហើយអញ្ជើញគាត់ឲ្យចូលមកក្នុងបន្ទប់របស់យើង ។

ខ្ញុំបានឈរ ហើយនិយាយថា « ឱ ព្យាការីរបស់យើងអើយ ! សូមចូលមក ហើយមើលពួកយើង ។ ពួកយើងមកពីប្រទេសរូម៉ានី » ។

លោកហាក់ដូចជាមិនឮខ្ញុំនិយាយទេ ។ មួយសន្ទុះក្រោយមក លោកបានត្រឡប់មកវិញ ។ លោកបានមានប្រសាសន៍ថា « ប្រទេសរូម៉ានី ! » រួចលោកបានចូលក្នុងបន្ទប់ ។

លោកបានស្វាគមន៍ពួកយើង ហើយថ្លែងថា លោកស្រឡាញ់ពួកយើងយ៉ាងខ្លាំង ។ ដួងចិត្តរបស់ខ្ញុំបានពោរពេញ នៅពេលខ្ញុំបានមើលទឹកមុខដ៏មានអំណររបស់សមាជិកជាទីស្រឡាញ់របស់ខ្ញុំ ។ ខ្ញុំបានអធិស្ឋានថា « ឱ ព្រះវរបិតាអើយ សូមអរគុណទ្រង់សម្រាប់អព្ភូតហេតុនេះនៅក្នុងដំណាក់របស់ទ្រង់ » ។

ខ្ញុំបានអធិស្ឋានក្នុងចិត្តខ្ញុំថា « ឱ ព្រះវរបិតាសួគ៌អើយ តើយើងអាចជួយសមាជិកទាំងនេះដែលមកពីប្រទេសរូម៉ានីឲ្យទទួលបានបទពិសោធន៍ដែលពុំអាចបំភ្លេចបាននៅក្នុងដំណាក់របស់ព្រះអង្គដូចម្ដេចទៅ ? »



នៅពេលព្យាការីចាកចេញពីបន្ទប់ទៅ គ្មាននរណាម្នាក់កើតទុក្ខទៀតឡើយ ។ ខ្ញុំមានអារម្មណ៍ថា យើងនៅក្នុងបន្ទប់មួយដ៏មានពរបំផុតនៅក្នុងព្រះវិហារបរិសុទ្ធ ។ វាជាបទពិសោធន៍មួយដែលខ្ញុំនឹងមិនអាចបំភ្លេចវាឡើយ ។ ■

ដ្ជូ វ៉ាសីល ទីក្រុង ប៊ូឆារេស ប្រទេសរូម៉ានី

# ស្នាមញញឹមនៃការទទួលយក

នាល្ងាចមួយវួដរបស់យើងបានប្រារព្ធសកម្មភាពមួយដែលយើងចំណាយពេលជាច្រើនម៉ោងដើម្បីរៀបចំ ។ បន្ទាប់ពីសកម្មភាពរួច យុវជនម្នាក់ដែលជាសាសនាគន់ការីបាននិយាយលាខ្ញុំ ប៉ុន្តែពីរបីនាទីក្រោយមក គាត់បានត្រឡប់មកសួរថា « ប៊ីស្សព តើពេលណាខ្ញុំត្រូវត្រឡប់មកវិញ ? » ខ្ញុំបានប្រាប់គាត់ថា នៅថ្ងៃអាទិត្យ ហើយយុវជននោះបាននិយាយភ្លាមថា « អត់ទេ តើមានសកម្មភាពមួយផ្សេងទៀតឬទេ ? » គាត់មានពេលដ៏រីករាយជាមួយយុវជនក្នុងវួដរបស់យើង ដែលធ្វើឲ្យគាត់ចង់ត្រឡប់មកវិញទៀត ។

ខ្ញុំក៏បាននិយាយជាមួយគូស្វាមីភរិយាមួយគូជាភ្ញៀវដែលបានមកចូលរួមសកម្មភាពនោះ ហើយបានសួរពួកគេថា តើពួកគេគិតដូចម្ដេចដែរ ។ ស្វាមីបាននិយាយថា « តាំងពីខ្ញុំមកដល់ទីនេះ យើងមានភាពសុខសាន្ត និងស្ងប់ស្ងាត់ » ដែលមានភរិយាគាត់បានងក់ក្បាលបញ្ជាក់ ។ ខ្ញុំមានការភ្ញាក់ផ្អើលចំពោះការណ៍នេះ ដោយសារពេលពួកគេមកដល់ដំបូង មានមនុស្សជាច្រើនបាននិយាយគ្នា និងមានសំឡេងអ៊ូអរណាស់ ។ ប៉ុន្តែគាត់បានបន្ត ហើយសម្លឹងមើលខ្ញុំ ហើយសួរថា « តើនោះគឺជាព្រះវិញ្ញាណបរិសុទ្ធមែនទេ ? » ដោយក្ដីភ្ញាក់ផ្អើល ខ្ញុំគ្រាន់តែអាចនិយាយថា មែនហើយ ។

មានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីត្រៀមសម្រាប់កម្មវិធីនេះ ដូច្នេះនៅយប់នោះនៅពេលអ្វីៗបានបញ្ចប់ទៅ រឿងមួយគត់ដែលខ្ញុំចង់ធ្វើនោះគឺទៅផ្ទះ ហើយសម្រាក ។ ដោយសារតែខ្ញុំអស់កម្លាំងពេក នោះខ្ញុំពុំអាចគិតអំពីការសន្ទនារបស់ខ្ញុំជាមួយសាសនាគន់ការីទាំងនោះទេ ។ ពេលខ្ញុំទៅដល់ផ្ទះ ខ្ញុំបានអធិស្ឋាន ហើយចូលសម្រាក ប៉ុន្តែខ្ញុំពុំអាចដេកលក់ឡើយ ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំបានឃើញព្រះភក្ត្រព្រះអម្ចាស់ញញឹម ។ វាជាស្នាមញញឹមនៃការទទួលយក ។ នៅគ្រានោះ ខ្ញុំបានចាប់ផ្ដើមចាំនូវរឿងដ៏អស្ចារ្យដែលបានកើតឡើងនៅឯសកម្មភាពនោះ ។

ខ្ញុំបានយល់ថា ភាពឧស្សាហ៍ព្យាយាម និងសេចក្ដីស្រឡាញ់របស់សមាជិកវួដអាចធ្វើឲ្យដួងចិត្តរបស់សាសនាគន់ការីទាំងបីនាក់នោះរំជួលចិត្ត ។ ខ្ញុំបានយល់ថា ស្នាមញញឹមនៃការទទួលយកគឺសម្រាប់អ្វីដែលយើងបានធ្វើ ។ ខ្ញុំអត់ទ្រាំនឹងយំពុំបានឡើយ ហើយខ្ញុំមានអារម្មណ៍អរគុណសម្រាប់អំណោយដែលព្រះអម្ចាស់បានប្រទានដល់យើង ។ ទ្រង់បានប្រទានដល់យើងនូវស្នាមញញឹមនៃការទទួលយក ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះបន្ទូលរបស់ព្រះអម្ចាស់ពិត ថា នៅពេលយើងនាំព្រលឹងតែមួយគត់មកកាន់ទ្រង់ នោះយើងនឹងមានសេចក្ដីអំណរដ៏មហិមានៅក្នុងនគរនៃព្រះវរបិតា ( សូមមើល គ. និង ស. ១៨:១៥ ) ។ ■

ហ្វ្រែងគ្លីន រូម៉េអូ ទីក្រុងម៉ាណាប៊ី ប្រទេសអេក្វាឌ័រ

**ចែកចាយរឿងរបស់អ្នក**

សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយបោះពុម្ពដំណើររឿងពិតនានាស្ដីពីប្រធានបទដំណឹងល្អ ប៉ុន្តែយើងកំពុងស្វែងរកបទពិសោធន៍របស់អ្នកជាពិសេសនៅក្នុងការងារបម្រើដល់អ្នកដទៃ និងការបង្ហាញភាពក្លាហាននៅក្នុងការរស់នៅតាមដំណឹងល្អ។ សូមដាក់ស្នើអត្ថបទរបស់អ្នកតាមអ៊ិនធើរណែតនៅគេហទំព័រ **liahona.lds.org** សូមចុច Submit an Article or Feedback

# ការជំរុញចិត្ត របស់យើង ដើម្បី រស់នៅ តាមដំណឹងល្អ

ដោយ មីនឌី សេលូ
ទស្សនាវដ្ដីសាសនាចក្រ

**នឹងមាន « ពាក្យពិបាកស្ដាប់ » ជានិច្ច ។ ប៉ុន្តែនឹងមានជម្រើសជានិច្ចដើម្បីជ្រើសរើសសេចក្ដីជំនឿលើមន្ទិលសង្ស័យ ឬភាពមិនប្រាកដប្រជានានា ។**

ផ្លូវនៃភាពជាសិស្សពោរពេញដោយពរជ័យ — ទាំង « មើលឃើញ និងមើលពុំឃើញ » ។[១] ប៉ុន្តែមានគ្រាដែលផ្លូវនោះពុំងាយស្រួលឡើយ ទោះបីជាមានពរជ័យក្ដី ។ ការក្លាយជាសិស្សរបស់ព្រះគ្រីស្ទតម្រូវឲ្យមានការខិតខំ និងការលះបង់ ហើយជួនកាលវាមានការលំបាកដើម្បីរកឃើញការជំរុញចិត្តដើម្បីរស់នៅតាមបទបញ្ញត្តិ និងធ្វើការលះបង់ទាំងនោះ ។

ក្នុងនាមជាយុវមជ្ឈិមវ័យ អ្នកប្រហែលជាមមាញឹកក្នុងការព្យាយាមរៀបចំការទទួលខុសត្រូវថ្មីៗ ធ្វើការសម្រេចចិត្តដែលផ្លាស់ប្ដូរជីវិត និងស្វែងយល់អំពីផ្លូវផ្ទាល់របស់អ្នកនៃភាពជាសិស្សនឹងមានសភាពបែបណាសម្រាប់ពេញមួយជីវិតរបស់អ្នក ។ លើសពីនោះទៀត មានអ្វីៗជាច្រើននៅក្នុងគោលនយោបាយ ប្រវត្តិសាសនាចក្រ ឬនៅក្នុងគោលលទ្ធិដំណឹងល្អ ដែលអ្នកពុំសូវយល់ និងមានការល្បួងដែលអ្នកកំពុងពុះពារយកឈ្នះ ព្រមទាំងពរជ័យដែលអ្នកកំពុងទន្ទឹងរង់ចាំ និងសំណួរអំពីផែនការរបស់ព្រះសម្រាប់អ្នក ។

ពេលខ្លះមានពួកយើងមួយចំនួនអាចឆ្ងល់ថា តើការរស់នៅតាមដំណឹងល្អសក្ដិសមនឹងពរជ័យដែលយើងត្រូវបានសន្យានឹងឲ្យដែរឬទេ ។ យើងប្រហែលជាប្រកែកថា យើងពុំសក្ដិសមនោះគឺជាការងារដ៏ច្រើនពេកហើយ ឬថាសំណួរនោះហាក់ដូចជាពិបាកឆ្លើយណាស់ ។ ប៉ុន្តែអ្វីដែលពិតជាផ្អែកទៅលើនោះគឺការជំរុញចិត្ត ។ ហេតុអ្វីអ្នកធ្វើនូវអ្វីដែលអ្នកធ្វើ ហើយរស់នៅតាមរបៀបដែលអ្នករស់នៅ ? ហេតុអ្វីអ្នកបន្តរក្សាបទបញ្ញត្តិ ទោះបីគ្មាននរណាម្នាក់នៅជុំវិញអ្នកកត់សម្គាល់ពីរឿងនោះក្ដី ?

ទោះបីអ្នកជានរណា ហើយអ្នកស្ថិតនៅក្នុងកម្រិតណានៃជីវិតអ្នកក្ដី ជម្រើសស្វែងរកការជំរុញចិត្តរបស់អ្នកតាមរយៈការបណ្ដុះសេចក្ដីជំនឿរបស់អ្នកលើព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់គឺស្រេចទៅលើអ្នក ។

**តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ ?**

ការស្វែងរក និងរក្សាការជំរុញចិត្តដើម្បីរស់នៅតាមដំណឹងល្អពុំមែនជាឧបសគ្គខ្លាំងសម្រាប់ជំនាន់របស់យើងនេះទេ ។ សូម្បី



តែកាលព្រះអង្គសង្គ្រោះគង់នៅលើផែនដី មនុស្សនៅតែពិបាកយល់ និងគោរពតាមគោលការណ៍នានាដែលទ្រង់បានបង្រៀន ។ មានពួកសិស្សទ្រង់មួយចំនួនបានស្ដាប់នៅពេលទ្រង់បានពន្យល់គោលគំនិតមួយដែលហាក់ដូចជាធ្វើឲ្យពួកគេអាក់អន់ចិត្ត — អំពីតួនាទីរបស់ទ្រង់ថាជា « នំបុ័ងនៃជីវិត » ( សូមមើល យ៉ូហាន ៦:៣៥–៥៨ ) ។ ពួកគេបានតបទាំងសង្ស័យថា « ពាក្យនេះពិបាកស្ដាប់ណាស់ តើអ្នកណាយល់បាន ? » ( យ៉ូហាន ៦:៦០ ) ។

ដោយទតឃើញពួកគេមានការពិបាកជឿ ឬពុំទទួលយកគោលលទ្ធិនេះ នោះព្រះគ្រីស្ទបានសួរថា « តើសេចក្ដីនេះនាំបង្អាក់ដល់ចិត្តអ្នករាល់គ្នាឬអី ? » ( យ៉ូហាន ៦:៦១ ) ។ ជំនួសឲ្យការដាក់សេចក្ដីជំនឿរបស់ពួកគេនៅមុខការមន្ទិលសង្ស័យរបស់ខ្លួន នោះពួកសិស្សជាច្រើនរបស់ទ្រង់ « ដកខ្លួនថយចេញ មិនតាមទ្រង់ទៀតទេ » ( យ៉ូហាន ៦:៦៦ ) ។

ប៉ុន្តែនៅពេល ព្រះគ្រីស្ទបានសួរពួកសិស្សទាំងអស់របស់ទ្រង់ថា តើពួកគេនឹង « ថយទៅដែរឬ ? » ពេត្រុសជាម្នាក់ដែលបានឆ្លើយនូវអ្វីដែលពិតជាត្រូវឆ្លើយថា ៖ « តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ គឺទ្រង់ហើយ ដែលមានព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច » ( យ៉ូហាន ៦:៦៧–៦៨ ) ។

## ប្រភពនៃការជំរុញចិត្តរបស់យើង

ពេត្រុសបានស្គាល់ពីប្រភពនៃការជំរុញចិត្តរបស់គាត់ ។ វាផ្អែកទៅលើហេតុផលសំខាន់អំពីមូលហេតុដែលយើងធ្វើនូវអ្វីដែលយើងកំពុងធ្វើនៅក្នុងដំណឹងល្អ ៖ ទីបន្ទាល់ និងសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ។ ពេត្រុសបានប្រកាសថា « យើងខ្ញុំក៏បានជឿ *ហើយដឹងថា* ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ពិត » ( យ៉ូហាន ៦:៦៩ ការគូស



បញ្ជាក់បានបន្ថែម ) ។ តាមរយៈការទទួលបានការជឿស៊ប់លើព្រះយេស៊ូវគ្រីស្ទ ភាពជាព្រះរបស់ទ្រង់ និងកិច្ចការរបស់ទ្រង់ខ្លាំងបែបនោះ នោះយើងក៏អាចស្វែងរកការជំរុញចិត្តដើម្បីបន្តរស់នៅតាមដំណឹល្អ — ទោះបីវាហាក់បីដូចជាពិបាក ទោះបីជាគ្មាននរណាម្នាក់ទៀតនឹងកត់សម្គាល់ ហើយសូម្បីតែពេលយើងពុំប្រាកដអំពីអ្វីដែលយើងចង់ធ្វើក្តី ។

នឹងមាន « ពាក្យពិបាកស្តាប់ » ជានិច្ច ។ ប៉ុន្តែនឹងមានជម្រើសជានិច្ចដើម្បីជ្រើសរើសសេចក្តីជំនឿលើមន្ទិលសង្ស័យ ឬភាពមិនប្រាកដប្រជានានា ។ ដូចអែលឌើរ អិល វិតនី ក្លេតុន ក្នុងគណៈប្រធាននៃពួកចិតសិបនាក់បានថ្លែងថា « ការសម្រេចចិត្តជឿ គឺជាជម្រើសដ៏សំខាន់បំផុតដែលយើងមិនធ្លាប់ធ្វើ » ។[១២]

ដូច្នេះតើយើងត្រូវធ្វើដូចម្តេច ប្រសិនបើយើងឃើញខ្លួនយើងនៅក្នុងផ្នែកណាមួយនៃ « ពាក្យពិបាកស្តាប់ » ទាំងនោះ ?

១. ធ្វើតាមគំរូរបស់ពេត្រុស និងពួកសិស្សផ្សេងទៀតដែលបន្តស្មោះត្រង់ទោះបីវាងាយស្រួលដើម្បី « ដកខ្លួនថយ » ក្តី ។ ស្តាប់ការទូន្មានមកពីពួកព្យាការី ពួកសាវក និងថ្នាក់ដឹកនាំដទៃទៀត ៖

« ក្នុងវេលានៃការភ័យខ្លាច ឬការសង្ស័យ ឬពេលដែលមានបញ្ហា សូមតោងចាប់ទីតាំងដែលអ្នកបានឈ្នះរួចហើយឲ្យជាប់ ។ . . . *យើងអាចតោងឲ្យជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយនោះ ហើយឈរឲ្យរឹងមាំរហូតដល់ទទួលបានចំណេះដឹងបន្ថែម* » ។[១៣]

« សូមបោះជំហានយ៉ាងសាមញ្ញទៅកាន់ក្តីជំនឿ — ហើយបន្ទាប់មកបោះមួយជំហានទៀត ។ . . . ផ្តោតលើសេចក្តីពិតដែល [ អ្នកពិតជា ] ជឿ ហើយឲ្យការពិតទាំងនោះចម្អែតគំនិត និងដួងចិត្ត [ របស់អ្នក ] ។ . . .

. . . សូមចាប់ផ្តើមជាមួយនឹងមូលដ្ឋានគ្រឹះនៃសេចក្តីពិតរបស់ដំណឹងល្អ » ។[១៤]

២. សូមបន្តអានព្រះគម្ពីរ ហើយធ្វើតាមការបង្រៀននៅក្នុងនោះ ៖

« សូមសិក្សា ហើយពិចារណាព្រះគម្ពីរមរមនជារៀងរាល់ថ្ងៃប្រកបដោយការអធិស្ឋាន » ។[១៥]

« បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ » ( យ៉ូហាន ៧:១៧ ) ។

« ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ » ( យ៉ាកុប ១:២២ ) ។

៣. សូមបន្តរក្សាបទបញ្ញត្តិ ។

« ចម្លើយចំពោះសំណួរដ៏ស្មោះត្រង់របស់យើង កើតមាននៅពេលយើងព្យាយាមស្វែងរក និងនៅពេលយើងរស់នៅតាមបទបញ្ញត្តិទាំងឡាយ ។ . . . សេចក្តីជំនឿរបស់យើងអាចជួយយើងឲ្យជឿលើអ្វីដែលយើងមិនយល់ក្នុងពេលនេះ » ។[១៦]

« នៅពេលអ្នកបន្តគោរពប្រតិបត្តិ . . . នោះអ្នកនឹងទទួលបានចំណេះដឹង និងការយល់ដឹងដែលអ្នកស្វែងរក » ។[១៧]

នៅទីបំផុត ការជំរុញចិត្តរបស់យើងផ្អែកសំខាន់ទៅលើអ្វីដែលពេត្រុសបាននិយាយ ។ តើយើងជឿថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទដែរឬទេ ថាទ្រង់ដឹកនាំសាសនាចក្ររបស់ទ្រង់ ហើយថាទ្រង់មានព្រះបន្ទូលនៃជីវិតអស់កល្បជានិច្ចដែរឬទេ ? តើសេចក្តីជំនឿរបស់យើងលើទ្រង់មានធំជាង « ពាក្យពិបាកស្តាប់ » ដែលយើងពុំអាចយល់នៅគ្រានោះដែរឬទេ ?

**រង្វាន់នៃការរស់នៅតាមដំណឹងល្អ**

ពេលយើងសម្រេចចិត្តដើម្បីស្រឡាញ់ និងធ្វើតាមព្រះ និងព្រះយេស៊ូវគ្រីស្ទ ព្រមទាំងរក្សាបទបញ្ញត្តិ ទោះបីនៅពេលយើងពុំយល់ពីបទបញ្ញត្តិនោះទាំងស្រុងក្តី នោះនឹងទទួលរង្វាន់មិនអាចវាស់វែងបានឡើយ ។ មនុស្សខាងសាច់ឈាមសួរថា « តើវាមានប្រយោជន៍អ្វីសម្រាប់ខ្ញុំ ? » ការបង្រៀននៃដំណឹងល្អឆ្លើយតបថា ៖ « សេចក្តីសុខសាន្តនៅនាលោកិយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ចនៅបរលោក », កន្លែងមួយដែលបានរៀបចំសម្រាប់អ្នកនៅក្នុងវិមាននៃព្រះ, អ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌មាន, « សុភមង្គលដ៏មិនចេះចប់មិនចេះហើយ » ( សូមមើល គ. និង ស. ៥៩:២៣; អេធើរ ១២:៣៤; គ. និង ស. ៨៤:៣៨; ម៉ូសាយ ២:៤១ ) ហើយដូចអែលឌើរ ឌៀថើរ អេស្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា ៖

« [ នៅក្នុងសាសនាចក្រ ] នេះ អ្នកនឹងរកឃើញនូវអ្វីដែលមានតម្លៃហួសពីការប៉ាន់ស្មាន ។ . . . នៅទីនេះអ្នកនឹងរកឃើញបន្ទូលនៃជីវិតអស់កល្ប ការសន្យានៃការប្រោសលោះ និងមាគ៌ាឆ្ពោះទៅភាពសុខសាន្ត និងសុភមង្គល » ។[៩] នេះគ្រាន់តែមួយចំនួនប៉ុណ្ណោះ ។

នៅពេលយើងបូជាខ្លួនយើងដើម្បីធ្វើតាមព្រះគ្រីស្ទ ហើយគោរពតាមបទបញ្ញត្តិទ្រង់ នោះយើងត្រូវបានសន្យាថា ទទួលបាននូវអ្វីៗទាំងអស់នេះ និងរបស់ជាច្រើនថែមទៀត ។ នោះពុំមែនមានន័យថា ផ្លូវនោះនឹងងាយស្រួល ឬអាចយល់បាននោះទេ ប៉ុន្តែពរជ័យដែលយើងត្រូវបានសន្យាមកពីការបន្តរឹងមាំ នឹងបន្តបើកសម្តែងពេញមួយជីវិតរបស់យើង និងបន្ទាប់ពីជីវិតនេះផងដែរ ។

ប៉ុន្តែ ទោះបីពរជ័យទាំងនេះអស្ចារ្យយ៉ាណាក្តីវាពុំគួរជាការជំរុញចិត្តសំខាន់របស់យើងដើម្បីរស់នៅតាមដំណឹងល្អឡើយ ។ ទោះបីអ្នកមានសំណួរអ្វី ទោះបីគោលលទ្ធិណាមួយដែលអ្នកពុំយល់ក្តី សេចក្តីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់គឺជាកូនសោនៃការជំរុញចិត្តរបស់អ្នកដើម្បីរស់នៅតាមដំណឹងល្អ គឺដូចជាករណីរបស់ពេត្រុស និងមនុស្សដទៃទៀតផងដែរ ។

អែលឌើរ អុជដូហ្វ បានមានប្រសាសន៍ថា « ការជំរុញចិត្ត និងគំនិតទាំងស្រុងរបស់យើងជះឥទ្ធិពលលើសកម្មភាពរបស់យើង » ។ « ទីបន្ទាល់នៃភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ គឺជាការជំរុញចិត្តដ៏មានអនុភាពបំផុតនៅក្នុងជីវិតរបស់យើង ។ ព្រះយេស៊ូវបានគូសបញ្ជាក់ឡើងវិញអំពីអំណាចនៃគំនិតល្អ និងការជំរុញចិត្តត្រឹមត្រូវដូច្នេះ ៖ ‹ ចូរមើលមកឯយើង ដោយនូវគ្រប់ទាំងគំនិត ចូរកុំសង្ស័យ កុំខ្លាចឡើយ › ( គ. និង ស. ៦:៣៦ ) ។

« ទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញនឹងជួយយើងនៅក្នុងជីវិតរបស់យើង ដើម្បីរៀនអំពីផែនការជាក់លាក់របស់ព្រះសម្រាប់យើង ហើយបន្ទាប់មកអនុវត្តស្របទៅតាមនោះ ។ វាផ្តល់ដល់យើងនូវការបញ្ជាក់អះអាងអំពីភាពពិតប្រាកដ សេចក្តីពិត និងសេចក្តីល្អនៃព្រះ អំពីការបង្រៀន និងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងអំពីការបម្រើមកពីព្រះនៃពួកព្យាការីថ្ងៃចុងក្រោយនេះ » ។[៩]

សម្រាប់ខ្ញុំ ខ្ញុំនឹងបន្តការព្យាយាមទៅមុខ ទោះបីនៅពេលវាលំបាកក្តី ។ ខ្ញុំនឹងបន្តអធិស្ឋាន ហើយសិក្សាព្រះគម្ពីរ ។ ខ្ញុំនឹងខិតខំពង្រឹងទីបន្ទាល់របស់ខ្ញុំអំពីព្រះអង្គសង្គ្រោះរៀងរាល់ថ្ងៃ ។ ហើយខ្ញុំនឹងបន្តព្យាយាមរស់នៅដូចដែលទ្រង់សព្វព្រះទ័យឲ្យខ្ញុំរស់នៅ ហើយពឹងផ្អែកលើព្រះបន្ទូលរបស់ទ្រង់ និងពួកព្យាការី និងពួកសាវកនៅរស់របស់ទ្រង់ដើម្បីបង្រៀនខ្ញុំអំពីរបៀបនានា ដោយពឹងផ្អែកលើការជំរុញចិត្តដែលពុំមែនគ្រាន់តែជាលទ្ធផលមកពីសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ចំពោះទ្រង់ប៉ុណ្ណោះនោះទេ ប៉ុន្តែមកពីការលះបង់ដ៏អស់កល្បជានិច្ច និងសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់ខ្ញុំផងដែរ ។ ■

កំណត់ចំណាំ
១. ឌៀថើរ អែហ្វ អុជដូហ្វ « The Way of the Disciple » Liahona ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៧៦ ។
២. អិល វិតនី ក្លេតុន « Choose to Believe » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៣៨ ។
៣. ជែហ្វ្រី អ័រ ហូឡិន « Lord, I Believe » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៣–៩៤ ការគូសបញ្ជាក់នៅក្នុងច្បាប់ដើម ។
៤. រ៉ូសម៉ារី អិម វិកស្យុម « Returning to Faith » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៩៤ ។
៥. ថូម៉ាស អេស ម៉នសុន « The Power of the Book of Mormon » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ៨៧ ។
៦. រ៉ូសម៉ារី អិម វិកស្យុម « Returning to Faith » ទំព័រ ៩៥ ។
៧. រ៉ សុល អិម ណិលសុន « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៥–៩៦ ។
៨. ឌៀថើរ អេស្វ អុជដូហ្វ « Come, Join with Us » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ២៤ ។
៩. ឌៀថើរ អែហ្វ អុជដូហ្វ « The Power of a Personal Testimony » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៣៧ ។



**ជម្រើសពីរ**

« ផ្លូវរបស់ព្រះអម្ចាស់មិនលំបាកទេ ។ ជីវិតគឺពិបាក ប៉ុន្តែដំណឹងល្អមិនដូច្នោះទេ ។. . . ជីវិតធ្វើឲ្យយើងទាំងអស់គ្នាមានការលំបាក ប៉ុន្តែជីវិតក៏មានភាពសាមញ្ញផងដែរ ។ យើងមានជម្រើសតែពីរប៉ុណ្ណោះ ។ យើងអាចដើរតាមព្រះអម្ចាស់ ហើយទទួលបាននូវព្រះចេស្តារបស់ទ្រង់ ហើយមានសេចក្តីសុខសាន្ត ពន្លឺ កម្លាំង ចំណេះដឹង ភាពជឿជាក់ សេចក្តីស្រឡាញ់ និងអំណរក៏បាន ឬក៏យើងអាចទៅផ្លូវមួយចំនួនទៀត ផ្លូវផ្សេងណាមួយ ផ្លូវផ្សេងណាក៏បានដែរ ហើយដើរលើផ្លូវនោះតែម្នាក់ឯង – ដោយគ្មានជំនួយរបស់ទ្រង់ គ្មានការគាំទ្ររបស់ទ្រង់ គ្មានព្រះចេស្តារបស់ទ្រង់ គ្មានការដឹកនាំរបស់ទ្រង់ នៅក្នុងសេចក្តីងងឹត ភាពចលាចល ការសង្ស័យ ទុក្ខសោក និងភាពអស់សង្ឃឹម ។ ហើយខ្ញុំសួរថា តើផ្លូវមួយណាដែលស្រួលជាង ? »

**អែលឌើរ លូវែន អ៊ី ខូប្រ៊ីតហ្គ ក្នុងពួកចិតសិបនាក់ « The Way » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣៦ ។**

# ជំហានទីមួយឆ្ពោះទៅកាន់ការប្រែចិត្ត

**ខ្ញុំទទួលអារម្មណ៍ថាភាពងងឹតគ្របដណ្ដប់លើជីវិតខ្ញុំ ។ បន្ទាប់មក ខ្ញុំបានដឹងថា ខ្ញុំត្រូវនិយាយជាមួយប៊ីស្សពរបស់ខ្ញុំ ។**

**ដោយ អូរីឡាស ភីធើសិន**

ខ្ញុំចាំពីការកំណត់ថ្ងៃបុណ្យជ្រមុជទឹករបស់ខ្ញុំជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានសួរខ្ញុំថា តើខ្ញុំត្រៀមខ្លួនរួចរាល់ដើម្បីចុះសេចក្ដីសញ្ញាជាមួយព្រះវរបិតាសួគ៌ដែរឬទេ ។ ដោយពុំបានគិតអំពីវា និងដោយមានចិត្តពោរពេញដោយអំណរ នោះខ្ញុំបាននិយាយថា « ត្រៀមរួចរាល់ហើយ ! » ខ្ញុំចង់ទទួលអំណោយពិសេសពីព្រះវរបិតាដែលពោរពេញដោយក្ដីស្រឡាញ់របស់ខ្ញុំប្រទានដល់ខ្ញុំ ហើយខ្ញុំបានដឹងថា ខ្ញុំនឹងពុំរីករាយឡើយ ប្រសិនបើគ្មានព្រះអង្គសង្គ្រោះក្នុងជីវិតខ្ញុំនោះ ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ពុំប្រាកដប្រជាអំពីអនាគតថានឹងកើតឡើងយ៉ាងណាចំពោះខ្ញុំឡើយ ។

ទីបំផុត ថ្ងៃដ៏ធំនោះបានកើតឡើង ។ ខ្ញុំពុំអាចបំភ្លេចវាបានឡើយ ហើយខ្ញុំពិតជារីករាយណាស់ ។

## ថ្ងៃដ៏អាប់អួរ

បន្ទាប់ពីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់របស់ខ្ញុំមក ហាក់ដូចជាមានភាពអាប់អួរកើតឡើងចំពោះខ្ញុំ ។ ខ្ញុំកំពុងដោះស្រាយបញ្ហាជាមួយគ្រួសារខ្ញុំ ហើយខ្ញុំកំពុងពុះពារគោរពតាមក្រឹត្យវិន័យទាំងអស់របស់ព្រះ ។ ខ្ញុំពុំដឹងថាត្រូវធ្វើអ្វីឡើយ ហើយខ្ញុំចង់ចុះចាញ់នូវអ្វីៗគ្រប់យ៉ាង ។ វាហាក់ដូចជាគ្មាននរណាម្នាក់យល់ចិត្តខ្ញុំឡើយ ។

ខ្ញុំចូលចិត្តអានព្រះគម្ពីរមរមនជានិច្ច ប៉ុន្តែអំឡុងគ្រានោះ ខ្ញុំបានទុកវាមួយអន្លើរ ។ ថ្ងៃមួយ ពេលខ្ញុំនៅផ្ទះតែឯង ខ្ញុំមានអារម្មណ៍ដ៏ផ្អែមល្ហែមមកពីការបំផុសគំនិតពីព្រះវិញ្ញាណដល់ខ្ញុំឲ្យអានព្រះគម្ពីរមរមន ។ ខ្ញុំបានអធិស្ឋានជាមុន ដោយចង់ស្វែងរកចម្លើយដែលអាចនាំនូវភាពសុខសាន្តចំពោះការរងទុក្ខរបស់ខ្ញុំ ។ ខ្ញុំបានបើកទៅអាលម៉ាជំពូក ៥ តែម្ដង ។ ខទី ២៧ ចែងថា ៖ « តើអ្នករាល់គ្នាបានដើរ ដោយកាន់ខ្លួនអ្នកថា ជាគ្មានទោសនៅចំពោះព្រះឬ ? តើអ្នករាល់គ្នាអាចនិយាយនៅក្នុងចិត្តអ្នក បើសិនជាអ្នករាល់គ្នាត្រូវបានហៅឲ្យទៅស្លាប់នៅក្នុងពេលនេះថា តើអ្នករាល់គ្នាបានបន្ទាបខ្លួនគ្រប់គ្រាន់ហើយឬនៅ ? តើសម្លៀកបំពាក់របស់អ្នកត្រូវបានជម្រះ ហើយត្រូវបានធ្វើឲ្យស តាមរយៈព្រះលោហិតនៃព្រះគ្រីស្ទ ដែលទ្រង់នឹងយាងមកសង្គ្រោះរាស្ត្ររបស់ទ្រង់ពីអំពើបាបទាំងឡាយរបស់គេហើយឬ ? »

ទីបំផុត ខ្ញុំរំជួលដួងចិត្តនឹងពាក្យទាំងនោះ ។ ខ្ញុំដឹងថា ខ្ញុំត្រូវប្រែចិត្ត ដូច្នេះខ្ញុំបានណាត់ជួបជាមួយប៊ីស្សពរបស់ខ្ញុំ ។ ខ្ញុំមានការភ័យខ្លាចណាស់ ប៉ុន្តែខ្ញុំបានបង្ខំខ្លួនឯងដើម្បីទៅជួបជាមួយគាត់ ។

## ការយល់ដឹងអំពីការសន្យារបស់ព្រះ

ពេលខ្ញុំទៅដល់ការិយាល័យរបស់ប៊ីស្សព ខ្ញុំមានអារម្មណ៍ថា មានកំហុសដែលខ្ញុំចង់ចេញទៅវិញដោយពុំបាច់ជួបគាត់ ។ ប៉ុន្តែខ្ញុំបានអធិស្ឋានទូលសូមភាពក្លាហានដើម្បីនិយាយនូវអ្វីដែលខ្ញុំត្រូវនិយាយ ។ ប៊ីស្សពបានស្វាគមន៍ខ្ញុំឲ្យចូលការិយាល័យរបស់គាត់ បន្ទាប់មក គាត់បាន

រចនារូបភាពដោយ ប៉ូស្ទេ ផេនទីង

អធិស្ឋានដើម្បីទទួលបានជំនួយពីព្រះ ។ គាត់បាននិយាយមកកាន់ខ្ញុំ ដូចខ្ញុំជាកូនរបស់គាត់ ហើយបង្ហាញសេចក្ដីស្រឡាញ់របស់គាត់ចំពោះខ្ញុំតាមរយៈពាក្យសម្ដីរបស់គាត់ ។ គាត់បានផ្ដល់ការទូន្មានដល់ខ្ញុំ ហើយសុំឲ្យខ្ញុំធ្វើនូវរឿងចាំបាច់នានាដើម្បីទទួលបានការអភ័យទោសពីព្រះ ហើយបន្ទាប់មកត្រឡប់មកជួបគាត់ទៀត ។

ខ្ញុំរីករាយយ៉ាងខ្លាំងសម្រាប់ឱកាសនេះ ។ ខ្ញុំបានធ្វើតាមការទូន្មានរបស់គាត់ ហើយទីបំផុតខ្ញុំបានយល់អំពីការសន្យារបស់ព្រះអំពីការអភ័យទោសដល់អាលម៉ា ៖ « បើសិនជាគេទទួលសារភាពនូវអំពើបាបទាំងឡាយរបស់ខ្លួនចំពោះអ្នក និងចំពោះយើង ហើយប្រែចិត្តដោយស្មោះអស់ពីចិត្ត អ្នកនោះហើយដែលអ្នកត្រូវអត់ទោសឲ្យ ហើយយើងក៏នឹងអត់ទោសឲ្យគេដែរ » ( ម៉ូសាយ ២៦:២៩ ) ។ បន្ទាប់ពីការប្រែចិត្តដ៏ស្មោះត្រង់ នោះខ្ញុំបានដឹងថា ព្រះបានអភ័យទោសឲ្យខ្ញុំ ។ ទីបំផុតខ្ញុំអាចទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ក្នុងចិត្តរបស់ខ្ញុំ ហើយភាពអាប់អួរនោះត្រូវបានលើកស្ទួយ ។ ខ្ញុំរីករាយ ហើយមានមោទនភាពចំពោះខ្លួនឯង ។

**ប៊ីស្សពនៅទីនោះដើម្បីជួយជានិច្ច**

ប៊ីស្សពគឺជាអ្នកតំណាងឲ្យព្រះអម្ចាស់សម្រាប់សមាជិកវួដ ។ សូមដឹងថា គាត់នៅទីនោះដើម្បីជួយអ្នកស្វែងរកសុភមង្គលដ៏ពិតដែលព្រះបានត្រៀមទុកសម្រាប់អ្នក ។ សូមទុកចិត្តគាត់ ។ ប្រសិនបើអ្នកមានបញ្ហា ឬត្រូវប្រែចិត្ត សូមទៅជួបគាត់ ។ គាត់នឹងជួយអ្នក ។

ខ្ញុំដឹងថា ជួនកាលវាពុំមែនជារឿងងាយស្រួលដើម្បីទៅជួបគាត់ឡើយ ។ ប៉ុន្តែ ប្រធាន ឡូរ៉េនសូ ស្នូ ( ១៨១៤–១៩០១ ) បានពន្យល់អំពីផែនការអស់កល្បជានិច្ចរបស់ព្រះវរបិតាសួគ៌របស់យើង ៖ « ខ្ញុំហ៊ាននិយាយថានៅក្នុងពិភពវិញ្ញាណ [ ជីវិតមុនឆាកជីវិតនេះ ] នៅពេលយើងត្រូវបានស្នើសុំឲ្យ. . .ឆ្លងកាត់បទពិសោធន៍ដែលយើងកំពុងទទួលឥឡូវនេះ វាពុំរីករាយ និងទទួលយកបានទាំងអស់នោះទេ ។ . . . ប៉ុន្តែគ្មានការសង្ស័យឡើយដែលយើងបានឃើញ និងយល់យ៉ាងច្បាស់នៅទីនោះថា នេះជាបទពិសោធន៍ចាំបាច់មួយ ដើម្បីសម្រេចបាននូវភាពតម្កើងឡើង និងសិរីល្អរបស់យើង » ។ លោកបានបន្តថ្លែងទៀតថា « យើងមានឆន្ទៈអនុលោមតាមព្រះទ័យរបស់ព្រះ ហើយនោះជាហេតុដែលយើងនៅទីនេះ » ( *Teachings of Presidents of the Church: Lorenzo Snow* [ ឆ្នាំ ២០១២ ] ទំព័រ ១១០ ) ។



ការប្រែចិត្តគឺជាផ្នែកនៃការអនុលោមតាមព្រះទ័យរបស់ព្រះ ។ ដូច្នេះជាជាងការភ័យខ្លាចនឹងប៊ីស្សព សូមធ្វើជាមិត្តភក្ដិនឹងគាត់វិញ ។ ព្រះបានជ្រើសរើសគាត់ ហើយគាត់អាចជួយអ្នកឲ្យប្រែចិត្ត និងព្យាបាលព្រលឹងអ្នកតាមរយៈការមករកព្រះយេស៊ូវគ្រីស្ទ ។ ព្រះអម្ចាស់សព្វព្រះទ័យជួយយើង ប៉ុន្តែយើងត្រូវតែធ្វើជំហានទីមួយឆ្ពោះទៅកាន់ការប្រែចិត្តសិន ។ តាមរបៀបនេះយើងអាចឃើញឃើញការសន្យានៅក្នុង អេសាយ ១:១៨ ត្រូវបានបំពេញ ៖ « ទោះបើអំពើបាបរបស់អ្នករាល់គ្នាខ្មៅកខ្វក់យ៉ាងណាក្ដីក៏វាប្រែសដូចសំឡីវិញដែរ » ។ ដោយហេតុនោះហើយ ប៊ីស្សពនៅទីនោះដើម្បីជួយ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះមានព្រះជន្មរស់ ហើយថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ! ពួកទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ។ ■

***អ្នកនិពន្ធរស់នៅទីក្រុងអូអេសប្រទេសថៃ ។***

# ការរៀនសូត្រ តាមរបៀបរបស់ព្រះអម្ចាស់



ដោយអែលឌើរ
ដាវីឌ អេ បែដណា
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

ការពន្លឿននៃកិច្ចការរបស់ព្រះអម្ចាស់តម្រូវឲ្យយើងបន្តរៀនសូត្រ ផ្លាស់ប្តូរ និងឆ្ពោះទៅមុខដោយសេចក្តីជំនឿលើព្រះអង្គសង្គ្រោះ ។

## គំរូអំពីគ្រប់ទាំងអស់

នៅក្នុងវិវរណៈមួយដែលបានប្រទានឲ្យព្យាការីយ៉ូសែប ស្ម៊ីធ នៅខែ មិថុនា ឆ្នាំ ១៨៣១ នោះព្រះអម្ចាស់បានប្រកាសដូច្នេះ ៖ « យើងនឹងប្រទានគំរូដល់អ្នកអំពីគ្រប់ទាំងអស់ ដើម្បីកុំឲ្យអ្នករាល់គ្នាអាចត្រូវគេបញ្ឆោតបាន ដ្បិតសាតាំងកំពុងនៅពាសពេញលើផែនដី ហើយវាចេញទៅ ដោយបញ្ឆោតសាសន៍នានា » ( គ. និង ស. ៥២:១៤ ) ។

គួរឲ្យចាប់អារម្មណ៍ណាស់ ព្រះអម្ចាស់បានប្រទានដល់យើងនូវគំរូ « មួយ » មិនមែនគំរូ « មួយ » សម្រាប់ គ្រប់ទាំងអស់នោះទេ ។ ខ្ញុំពុំជឿថា ព្រះអម្ចាស់កំពុងប្រាប់នូវពាក្យ « គំរូអំពីគ្រប់ទាំងអស់ » ថាទ្រង់មានតែគំរូមួយដើម្បីប្រើប្រាស់នៅក្នុងគ្រប់ស្ថានភាពនោះទេ ។ ផ្ទុយទៅវិញ របៀបរបស់ព្រះអម្ចាស់រួមមានគំរូជាច្រើនដែលអាចត្រូវបានប្រើប្រាស់ដើម្បីសម្រេចបាននូវវត្ថុបំណងខាងវិញ្ញាណផ្សេងៗគ្នា ។

គោលបំណងចម្បងបំផុតរបស់យើងក្នុងបទពិសោធន៍នៃការរៀនសូត្រ និងការបង្រៀន គួរតែត្រូវបានកំណត់ និងប្រើគំរូនេះ ឬគំរូនានាដែលបំពេញតម្រូវការរបស់យើងបានល្អបំផុត ហើយសម្រេចបាននូវលទ្ធផលរៀនសូត្រដែលប៉ងប្រាថ្នា ។

## ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀន

ព្រះវិញ្ញាណបរិសុទ្ធគឺជាសមាជិកទីបីនៃក្រុមព្រះ និងជាអ្នកផ្តល់វិវរណៈ គ្រូបង្រៀន អង្គជាជំនួយ អង្គដែលញែកចេញបរិសុទ្ធ ហើយទ្រង់នាំឲ្យយើងចងចាំនូវអ្វីៗទាំងអស់ ( សូមមើល យ៉ូហាន ១៤:១៦–១៧, ២៦; នីហ្វៃទី ៣ ២៧:២០ ) ។ អែលឌើរ ជេម អ៊ី ថាលម៉េហ្គ ( ឆ្នាំ ១៨៦២–១៩៣៣ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា « តំណែងរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការងារបម្រើរបស់ទ្រង់ក្នុងចំណោមមនុស្សត្រូវបានពិពណ៌នានៅក្នុងព្រះគម្ពីរ ។ ទ្រង់គឺជាគ្រូបង្រៀនដែលព្រះវរបិតាបានបញ្ជូនមក ហើយចំពោះអស់អ្នកដែលមានសិទ្ធិដើម្បីទទួល

ការយោងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យធ្វើជាគ្រូបង្រៀន គឺជាគោលបំណងចម្បងមួយនៅក្នុងលំនាំទាំងអស់របស់ព្រះអម្ចាស់សម្រាប់ការរៀនសូត្រ ។



# ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានទាំងចិត្ត និងគំនិតដែលស្ម័គ្រតាម ។



ការបង្រៀនរបស់ទ្រង់ នោះទ្រង់នឹងបើកសម្ដែងនូវគ្រប់អ្វីៗទាំងអស់ដែលចាំបាច់សម្រាប់ការលើកតម្កើងព្រលឹង » ។[១] ការយាងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យធ្វើជា គ្រូបង្រៀននោះ គឺជាគោលបំណងចម្បងមួយនៅក្នុងលំនាំទាំងអស់របស់ព្រះអម្ចាស់សម្រាប់ការរៀនសូត្រ និងការបង្រៀន ។

អ្នករៀនសូត្រដែលអនុវត្តសិទ្ធិជ្រើសរើសខាងសីលធម៌ ហើយអនុវត្តស្របតាមគោលការណ៍ត្រឹមត្រូវ បើកដួងចិត្តពួកគេចំពោះព្រះវិញ្ញាណបរិសុទ្ធ — ហើយអញ្ជើញការបង្រៀនរបស់ទ្រង់ អំណាចនៃការថ្លែងទីបន្ទាល់ និងសាក្សីបញ្ជាក់របស់ទ្រង់ ។ . . . ការរៀនសូត្រជាមួយ និងដោយសេចក្ដីជំនឿតម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និងខាងរូបកាយ ហើយពុំមែនគ្រាន់តែជាការទទួលដោយភាពអកម្មនោះទេ ។ នៅក្នុងសេចក្ដីស្មោះត្រង់ និងភាពខ្ជាប់ខ្ជួននៃសកម្មភាពដែលបានបំផុសគំនិតយើងឲ្យមានសេចក្ដីជំនឿ នោះយើងបង្ហាញចំពោះព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ នូវការស្ម័គ្រចិត្តរបស់យើងដើម្បីរៀន និងទទួលយកការបង្ហាត់បង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។

សូមពិចារណាអំពីរបៀបដែលពួកអ្នកផ្សព្វផ្សាយសាសនាជួយសាសនាគន់ការីរៀនដោយសេចក្ដីជំនឿ ។ ការធ្វើ និងការរក្សាការតាំងចិត្តខាងវិញ្ញាណ ដូចជាការសិក្សា និងការអធិស្ឋានអំពីព្រះគម្ពីរមរមន ការរក្សាបទបញ្ញត្តិ និងការចូលរួមការប្រជុំសាសនាចក្រតម្រូវឲ្យសាសនាគន់ការីអនុវត្តសេចក្ដីជំនឿ ហើយធ្វើសកម្មភាព ។ គោលការណ៍នេះក៏អនុវត្តចំពោះសមាជិកទាំងអស់ រួមទាំងឪពុកម្ដាយ គ្រូបង្រៀន និងថ្នាក់ដឹកនាំផងដែរ ។

ការបង្រៀន ការដាស់តឿន និងការពន្យល់ — គឺសំខាន់ — តែពុំអាចផ្លាស់ប្ដូរសាសនាគន់ការីកុមារ សិស្ស ឬសមាជិកនូវសាក្សីនៃសេចក្ដីពិតដ៏ពេញលេញនៃដំណឹងល្អដែលបានស្ដារឡើងវិញឡើយ ។ លើកលែងតែនៅពេលសេចក្ដីជំនឿរបស់ពួកគេចាប់ផ្ដើមសកម្មភាព ហើយបើកផ្លូវទៅដល់ដួងចិត្ត ដែលអាចឲ្យព្រះវិញ្ញាណបរិសុទ្ធនាំមកនូវសាក្សីបញ្ជាក់នោះ ។ ពួកអ្នកផ្សព្វផ្សាយសាសនា ឪពុកម្ដាយ គ្រូបង្រៀន និងថ្នាក់ដឹកនាំត្រូវតែរៀនជាប្រាកដ ដើម្បីបង្រៀនដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ ប៉ុន្តែភាពសំខាន់ស្មើគ្នានោះគឺការទទួលខុសត្រូវដែលពួកគេមានដើម្បីជួយអ្នកដទៃឲ្យរៀនដោយខ្លួនពួកគេតាមរយៈសេចក្ដីជំនឿ ។

ការរៀនសូត្រដែលខ្ញុំកំពុងពិពណ៌នានេះ វាមានកម្រិតហួសពីការយល់ដឹង ហើយរក្សាទុក និងចងចាំអំពីព័ត៌មាន ។ ប្រភេទការរៀនសូត្រដែលខ្ញុំកំពុងនិយាយនេះធ្វើឲ្យយើងភ្ញាក់ឡើងចំពោះព្រះ ( សូមមើល អាលម៉ា ៥:៧ ) សម្រាតភាពខាងសាច់ឈាមចេញ ( សូមមើល ម៉ូសាយ ៣:១៩ ) ផ្លាស់ប្ដូរដួងចិត្តរបស់យើង ( សូមមើល ម៉ូសាយ ៥:២ ) ហើយបានប្រែចិត្តជឿដល់ព្រះអម្ចាស់ និងពុំបោះបង់ចោលសាសនាឡើយ ( សូមមើល អាលម៉ា ២៣:៦ ) ។ ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានចិត្ត និងគំនិតដែលស្ម័គ្រតាម ( សូមមើល គ. និង ស. ៦៤:៣៤ ) ហើយជាលទ្ធផលនៃព្រះវិញ្ញាណបរិសុទ្ធ ដែលនាំព្រះចេស្ដានៃព្រះបន្ទូលព្រះមកកាន់ដួងចិត្តផង និងចូលដល់ក្នុងដួងចិត្តផង ។ ការរៀនសូត្រដោយសេចក្ដីជំនឿ ពុំអាចត្រូវបានផ្ទេរពីគ្រូបង្រៀនទៅសិស្សម្នាក់ ពីអ្នកផ្សព្វផ្សាយសាសនាម្នាក់ទៅសាសនាគន់ការីម្នាក់ តាមរយៈការបង្រៀន ការបង្ហាញ ឬតាមសកម្មភាពក្នុងថ្នាក់រៀនទេ តែសិស្សម្នាក់ត្រូវតែអនុវត្តសេចក្ដីជំនឿ និងធ្វើសកម្មភាព ដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនគាត់ ។

## គំរូសម្រាប់ការរៀនសូត្រ និងការបង្រៀន

**១. *រៀបចំខ្លួនរៀន*** ប្រសិនបើអ្នកចូលរួមថ្នាក់សាលាថ្ងៃអាទិត្យ ហើយស្ដាប់គ្រូបង្រៀនរបស់អ្នកបង្ហាញប្រធានបទមួយ នោះគឺជាការល្អណាស់ ។ ប៉ុន្តែប្រសិនបើអ្នកបានធ្វើការ ហើយរៀបចំ ប្រសិនបើអ្នកកំពុងគិតអំពីអ្វីដែលគ្រូបង្រៀនរបស់អ្នកបានអញ្ជើញអ្នកឲ្យអាន ពិចារណា និងអធិស្ឋានពីមុនមករៀន នោះអាចមានការចាក់ស្រោចព្រះវិញ្ញាណដ៏មានអនុភាព ហើយព្រះវិញ្ញាណបរិសុទ្ធក្លាយជាគ្រូបង្រៀនរបស់អ្នក ។ ការរៀបចំអញ្ជើញឲ្យមានវិវរណៈ ។

**២. *រួមចំណែកដើម្បីឲ្យស្អាងឡើង*** ខ្ញុំចង់ឲ្យអ្នកយកចិត្តទុកដាក់នឹងខគម្ពីរនេះ ។ « តាំងគ្រូបង្រៀន

ម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា ហើយចូរកុំឲ្យទាំងអស់គ្នានិយាយព្រមគ្នាឡើយ ប៉ុន្តែចូរនិយាយម្នាក់ម្ដង ហើយចូរឲ្យទាំងអស់គ្នាស្ដាប់ពាក្យសម្ដីរបស់អ្នកនោះ ប្រយោជន៍កាលណាទាំងអស់គ្នានិយាយ នោះទើបឲ្យទាំងអស់បានស្អាងឡើងទាំងអស់គ្នា ហើយប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានសិទ្ធិស្មើគ្នា » ( គ. និង ស. ៨៨:១២២ ) ។

នេះគឺជាគំរូដ៏មានអនុភាពមួយរបស់ព្រះអម្ចាស់សម្រាប់ការរៀនសូត្រ និងការបង្រៀន ។ ខ្ញុំសូមផ្ដល់យោបល់នូវវិធីមួយនៃការមើលខគម្ពីរនេះ « តាំងគ្រូបង្រៀនម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា » ។ តើនរណាជាគ្រូបង្រៀន ? ព្រះវិញ្ញាណបរិសុទ្ធ ។ តើវាអាចទេ ប្រសិនបើអ្នកចង់ឲ្យព្រះវិញ្ញាណបរិសុទ្ធក្លាយជាគ្រូបង្រៀនរបស់អ្នក នោះ « ចូរកុំឲ្យទាំងអស់គ្នា [ និយាយ ] ព្រមគ្នាឡើយ ប៉ុន្តែចូរនិយាយម្នាក់ម្ដង ហើយចូរឲ្យទាំងអស់គ្នាស្ដាប់ពាក្យសម្ដីរបស់អ្នកនោះ ប្រយោជន៍កាលណាទាំងអស់គ្នានិយាយ នោះទើបឲ្យទាំងអស់បានស្អាងឡើងទាំងអស់គ្នា ? » បុគ្គលម្នាក់ដែលអាចបង្កើតការស្អាងឡើងនោះមានតែព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។

ការចូលរួមដើម្បីស្អាងឡើងអញ្ជើញឲ្យមានវិវរណៈ ។ បច្ចុប្បន្ននេះនៅក្នុងសាសនាចក្រ ពួកយើងកំពុងតែរៀន និងអនុវត្តការកាន់តែឆាប់ដឹងភាពហ្មត់ចត់ខាងវិញ្ញាណ និងគំរូនៃតម្រូវការក្នុងការរៀនសូត្រ និងការបង្រៀន ។ តើយើងនឹងធ្វើជានិច្ចនូវអ្វីដែលតែងតែធ្វើ ហើយទទួលលទ្ធផលដដែលៗដែលយើងធ្លាប់ទទួលដែរឬទេ ឬតើយើងនឹងប្រែចិត្ត ហើយរៀន និងផ្លាស់ប្ដូរ ហើយបង្រៀនតាមរបៀបរបស់ព្រះអម្ចាស់កាន់តែច្រើនឡើងដែរឬទេ ?

***៣. អញ្ជើញឲ្យអនុវត្ត*** គ្រាន់តែសំណួរសាមញ្ញមួយអាចជួយឲ្យសម្រេចបានគោលដៅនេះ ។ តើអ្នកនឹងធ្វើយ៉ាងណាជាមួយនឹងអ្វីដែលអ្នកបានរៀននេះ ? ការអនុវត្តតាមវិវរណៈអញ្ជើញវិវរណៈកាន់តែច្រើនឡើង ។

ខ្ញុំអធិស្ឋានសូមឲ្យពួកយើងរក្សាល្បឿនជាមួយការពន្លឿនរបស់ព្រះអម្ចាស់ ថាយើងនឹងពុំគ្រាន់តែធ្វើនូវអ្វីដែលសាមញ្ញៗដូចដែលយើងធ្លាប់បានធ្វើវាឡើយ ។

ខ្ញុំសូមប្រកាសជាសាក្សីអំពីភាពពិតប្រាកដនៃព្រះជន្មរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ខ្ញុំសូមធ្វើជាសាក្សីថា ទ្រង់មានព្រះជន្មរស់ ។ ទ្រង់បានមានព្រះជន្មរស់ឡើងវិញ ។ ទ្រង់គង់នៅជាប្រមុខនៃសាសនាចក្រនេះ ហើយទ្រង់ដឹកនាំកិច្ចការសាសនាចក្រនេះ ។ ទ្រង់កំពុងអង្វរករយើងម្នាក់ៗឲ្យរក្សាល្បឿនជាមួយនឹងការពន្លឿនកិច្ចការរបស់ទ្រង់ ហើយធ្វើតាមគំរូដែលទ្រង់បានគូសដានមកសម្រាប់ការរីកចម្រើន និងការរៀនសូត្ររបស់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាសម្រាប់ប្រធានបេសកកម្មថ្មីនៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៤ ។*

**កំណត់ចំណាំ**

១. ជេម អ៊ី ថាលមេច *Articles of Faith* 12th បានបោះពុម្ព ( ឆ្នាំ ១៩២៤ ) ទំព័រ ១៦២ ។



# ការរៀបចំអញ្ជើញឲ្យមានវិវរណៈ ។

# របៀប ៥ យ៉ាងដើម្បីរៀនអំពីសន្និសីទទូទៅ

**សន្និសីទទូទៅគឺជាឱកាសមួយដ៏អស្ចារ្យដើម្បី** ចូលរួមជាមួយសមាជិកសាសនាចក្រទូទាំងពិភពលោក ដើម្បីស្ដាប់ថ្នាក់ដឹកនាំ និងទទួលការណែនាំមកពីព្រះអម្ចាស់ ។ ការទស្សនា ការស្ដាប់ និងការសិក្សាសារលិខិតសន្និសីទទូទៅនឹងយាងព្រះវិញ្ញាណមកកាន់ជីវិតអ្នក ហើយជួយអ្នកឲ្យស្ថាបនាសេចក្ដីជំនឿអ្នក ។ វាជាឱកាសមួយឲ្យអ្នកទទួលបាន និងអនុវត្តតាមវិវរណៈផ្ទាល់ខ្លួន ។

នេះគឺជារបៀបទាំងប្រាំដែលអ្នកអាចរៀនពីសន្និសីទទូទៅ ។

## ១ កត់ត្រាសំណួររបស់អ្នកពីមុនសន្និសីទទូទៅចាប់ផ្ដើម

សូមចំណាយពេលកត់ត្រាសំណួររបស់អ្នកពីមុនសន្និសីទទូទៅចាប់ផ្ដើម បន្ទាប់មកយកចិត្តទុកដាក់ចំពោះចម្លើយដែលកើតមានចំពោះអ្នកអំឡុងពេលសន្និសីទ ។ ការអធិស្ឋាន និងសំណួររបស់អ្នកអាចត្រូវបានឆ្លើយតប នៅពេលអ្នកចូលរួម ហើយស្ដាប់តាមព្រះវិញ្ញាណ ។



ដកស្រង់មកពី *ព្រះគ្រីស្ទ និងកម្លោះអ្នកមាន* ដោយ ហិនរីឆ ហូហ្វមិន

## ២ ព្យាយាមរៀនអំពីព្រះគ្រីស្ទ

ពួកព្យាការីថ្លែងទីបន្ទាល់ និងបង្រៀនអំពីព្រះអង្គសង្គ្រោះ ( សូមមើល កិច្ចការ ១០:៤៣ ) ។ នៅពេលអ្នកស្ដាប់សារលិខិតសន្និសីទ អ្នកអាចគិតអំពីអ្វីដែលអ្នកនិយាយកំពុងបង្រៀនអ្នកអំពីព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចធ្វើបញ្ជីមួយនៅក្នុងសៀវភៅកំណត់ចំណាំរបស់អ្នក ។



អ្នក មានសមត្ថភាព ដើម្បីទទួលវិវរណៈ ហើយធ្វើតាមវាដោយពុំភ័យខ្លាច ។

ប្រធាន ហិនរី ប៊ី អាវរិង « ព្រះអង្គម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ » សន្និសីទទូទៅខែតុលា ឆ្នាំ ២០១៧

## ៥ ត្រូវជំរុញចិត្ត និង បំផុសគំនិតឲ្យអនុវត្ត

សូមកត់សារលិខិត និងការដកស្រង់ដែលបំផុសគំនិតអ្នក ឬអញ្ជើញអ្នកឲ្យអនុវត្ត ។ ការណ៍នេះអាចជួយអ្នកឲ្យអនុវត្តអ្វីដែលអ្នករៀន—ហើយជួយអ្នកឲ្យចាំអ្វីដែលជាគំនិតរបស់អ្នក នៅពេលអ្នកត្រូវការការរំឭកលើកក្រោយ ! ■



## ៣ រកមើលបាវចនា

បន្ទាប់ពីទស្សនាសន្និសីទទូទៅមួយចំនួនមក អ្នកអាចកត់សម្គាល់ថា អ្នកបានស្ដាប់ឮប្រធានបទ ឬបាវចនាដែលលើកឡើងច្រើនជាងម្ដង ។ គំរូដែលអ្នកកត់សម្គាល់អាចជារបៀបមួយដែលព្រះវិញ្ញាណជួយអ្នកទទួលស្គាល់អ្វីដែលអ្នកត្រូវរៀន ។





ការរៀនសូត្រជាមួយ និងដោយសេចក្ដីជំនឿតម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និង ខាងរូបកាយ ហើយពុំមែនគ្រាន់តែជាការទទួលភាពអកម្មនោះទេ ។

អែលឌើរ ដេវីឌ អេ បែដណា « ការរៀនសូត្រតាមរបៀបរបស់ព្រះអម្ចាស់ » ទំព័រ ៥០ នៃច្បាប់ចេញផ្សាយនេះ ។

## ៤ កត់ត្រាទុកអំពីព្រះគម្ពីរមរមន

អ្នកអាចរៀនច្រើនតាមរយៈការផ្ដោតចិត្តទុកដាក់ដល់ខគម្ពីរដែលថ្នាក់ដឹកនាំលើកឡើងជាពិសេសព្រះគម្ពីរមរមន ដែលជា « មូលដ្ឋាននៃសាសនារបស់យើង » ( សូមមើលបុព្វកថាព្រះគម្ពីរមរមន ) ។ មើលថា តើអ្នកអាចតាមដានគ្រប់ពេលដែលពួកគាត់ថ្លែងអំពីវានៅក្នុងសន្និសីទទូទៅដែរឬទេ ។ អ្នកនឹងភ្ញាក់ផ្អើលចំពោះអ្វីដែលអ្នករកឃើញ !

រូបភាពយកពី GETTY IMAGES រូបថតមនុស្សនៅលើកំពូលភ្នំយកពី JOSHUA EARLE/UNSPLASH

# បានបង្រៀនដោយ
# ព្រះវិញ្ញាណបរិសុទ្ធ

***យុវវ័យទាំងនេះបានរៀបចំខ្លួន*** ដើម្បីទទួលការបង្រៀនដោយព្រះវិញ្ញាណពីមុនសន្និសីទទូទៅ ។ នេះគឺជាអ្វីដែលពួកគេបានរៀនពីសន្និសីទមុនៗ និងអ្វីដែលពួកគេកំពុងធ្វើប្លែកខុសពីមុនដោយសារការណ៍នោះ ។







### ការណែនាំដ៏បំផុសគំនិត

សន្និសីទទូទៅបានបំផុសគំនិតដល់ខ្ញុំ ។ អំឡុងពេលស្ដាប់ការណែនាំមកពីថ្នាក់ដឹកនាំរបស់យើងឲ្យបម្រើអ្នកដទៃ ទុកចិត្តលើព្រះគ្រីស្ទ និងតោងឲ្យជាប់ដំបងដែក នោះខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់មកខ្ញុំថា ដំណឹងល្អនេះពិត ហើយថាយើងអាចទទួលជីវិតអស់កល្បជានិច្ច តាមរយៈការរក្សាបទបញ្ញត្តិ និងការធ្វើតាមព្រះបន្ទូលព្រះ ។ ខ្ញុំបានដាក់គោលដៅធ្វើការបម្រើកាន់តែច្រើននៅក្នុងសហគមន៍របស់ខ្ញុំ ហើយពង្រឹងទីបន្ទាល់របស់ខ្ញុំតាមរយៈការអធិស្ឋាន និងការសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ។ ខ្ញុំដឹងថា ខ្ញុំជាបុត្រីរបស់ព្រះវរបិតាសួគ៌ ។ ទ្រង់មានព្រះជន្មរស់ ហើយស្រឡាញ់ខ្ញុំជារៀងរហូត និងជានិច្ច ។

***ម៉ាដេលីន ប៊ី អាយុ ១៦ ឆ្នាំ ដេឡាវ៉ែ ស.រ.អា.***

***អំពីខ្ញុំ ៖*** កូនច្បងនៃបងប្អូនបីនាក់ ធ្វើដំណើរជុំវិញប្រទេស ចូលចិត្តអាន និងច្រៀង ចូលចិត្តភាសាអេស្ប៉ាញ ហើយសង្ឃឹមថាបង្រៀនភាសាអង់គ្លេសជាភាសាទីពីរ

### ចម្លើយចំពោះសំណួរ

ពីមុនសន្និសីទទូទៅខ្ញុំមានសំណួរពីរ ៖ ( ១ ) តើខ្ញុំអាចរក្សាឥរិយាបថល្អ ហើយជួយមិត្តភក្តិរបស់ខ្ញុំ នៅពេលពួកគេធ្វើការសម្រេចចិត្តមិនល្អដោយរបៀបណា ? និង ( ២ ) តើខ្ញុំអាចថ្លែងទីបន្ទាល់អំពីសាសនាចក្រដោយគ្មានការសើចចំអកពីពួកគេដោយរបៀបណា ? អំឡុងសន្និសីទ ព្រះវិញ្ញាណបានថ្លែងទីបន្ទាល់ដល់ខ្ញុំថា ខ្ញុំពុំនៅឯកោទេ ។ ឥឡូវនេះ ខ្ញុំដឹងថា តាមរយៈការសិក្សាព្រះគម្ពីរដោយអស់ពីដួងចិត្តខ្ញុំ នោះខ្ញុំនឹងទទួលចម្លើយចំពោះសំណួររបស់ខ្ញុំអំពីមិត្តភក្តិខ្ញុំ ។ ខ្ញុំដឹងថា ព្រះវរបិតាព្រះសណ្ដាប់ការអធិស្ឋានរបស់ខ្ញុំ ហើយខ្ញុំនឹងព្យាយាមធ្វើខ្លួនឲ្យប្រសើរឡើងជារៀងរាល់ថ្ងៃ ។

***អ៊ីសាក អ័រ អាយុ ១៣ ឆ្នាំ ទីក្រុងពីឈីនឆា ប្រទេសអេក្វាទ័រ***

***អំពីខ្ញុំ ៖*** ជាកូនទោល ចូលចិត្តលេងព្យាណូ លេងស្កេត លេងបាល់ឱប ហាត់យូដូ ហែលទឹក ច្រៀង និងធ្វើស្គរគ្រាប់ ចង់ក្លាយជាវេជ្ជបណ្ឌិត ពណ៌ដែលចូលចិត្តគឺពណ៌បៃតង



រូបភាពផ្តិតបានមកពី GETTY IMAGES





## បានអញ្ជើញឲ្យរីកចម្រើន

សន្និសីទទូទៅបានពង្រឹងខ្ញុំនូវបំណងប្រាថ្នាដើម្បីដើរតាមមាគ៌ានៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ វាជួយខ្ញុំឲ្យដឹង និងយល់ថា នេះគឺជាសាសនាចក្រពិតដែលនាំពន្លឺ និងសុភមង្គលដល់យើង ។ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណអញ្ជើញខ្ញុំឲ្យរីកចម្រើនរៀងរាល់ថ្ងៃ ហើយអានព្រះគម្ពីរមរមនដើម្បីទទួលបានទីបន្ទាល់រឹងមាំអំពីដំណឹងល្អ ។ ខ្ញុំជឿថា ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យខ្ញុំស្ដាប់សារលិខិតដ៏បំផុសគំនិតទាំងនេះ ។

***វីជិនតេ អេ អាយុ ១៦ ឆ្នាំ ទីក្រុង មេត្រូប៉ូលីតាន វីជិន ប្រទេសឈីលី***



***អំពីខ្ញុំ ៖*** កូនច្បងនៃបងប្អូនបួននាក់ ចូលចិត្តលេងវីដេអូហ្គេម ស្ដាប់តន្ត្រី និងលេងបាល់ឱប ចូលរោងមហោស្រព ចង់បម្រើបេសកកម្ម



## រៀបចំខ្លួនរៀន

ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំងនៅសន្និសីទទូទៅ ។ ដោយសារខ្ញុំបានចាប់ផ្ដើមរៀបចំសំណួរ និងការរៀបចំខ្លួនខ្ញុំខាងវិញ្ញាណសម្រាប់សន្និសីទ នោះវាធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំនៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំអាចរៀនកាន់តែច្រើនតាមរយៈសុន្ទរកថានីមួយៗ ។ ខ្ញុំមានអំណរគុណចំពោះព្យាការី និងពួកសាវក ហើយខ្ញុំដឹងថា ព្រះវរបិតាសួគ៌បញ្ជូនពួកលោកឲ្យមកដឹកនាំ និងណែនាំផ្លូវនៅក្នុងជីវិតរបស់ពួកយើង !

***បិន អេច អាយុ ១៧ ឆ្នាំ រដ្ឋខេនធើឃី ស.រ.អា.***

***អំពីខ្ញុំ ៖*** ចូលចិត្តកីឡា លេងបាល់បោះ និងធេននីសនៅសាលារៀន ចូលចិត្តជិះស្គី ជិះក្ដារលើទឹកកក ធ្វើដំណើរ និងឡើងភ្នំ



## ស្វែងរកពន្លឺ

នៅឆ្នាំពីមុនឆ្នាំទៅគឺជាឆ្នាំដ៏លំបាកសម្រាប់ខ្ញុំ ។ ឪពុករបស់ខ្ញុំកំពុងឈឺជំងឺមហារីក ហើយមានពួកភាវរករបានវាយប្រហារទីក្រុងរបស់ខ្ញុំ ។ ខ្ញុំមានការលំបាកនឹងការថប់បារម្ភ ដោយឆ្ងល់ថា តើខ្ញុំអាចទទួលអារម្មណ៍សុខសាន្ត នៅពេលខ្ញុំភ័យខ្លាចសម្រាប់សុវត្ថិភាពខាងវិញ្ញាណ និងខាងសាច់ឈាមរបស់ខ្ញុំដោយរបៀបណា ។ ខ្ញុំបានរៀនមកពីសន្និសីទទូទៅថា យើងអាចរកឃើញភាពសុខសាន្ត នៅពេលយើងរស់នៅដោយមានគុណធម៌ បំពេញដួងចិត្តរបស់យើងដោយសេចក្ដីជំនឿ ហើយរក្សាទស្សនវិស័យអស់កល្បជានិច្ច ។ ខ្ញុំត្រូវបានបំផុសគំនិតឲ្យងាកទៅរកព្រះគ្រីស្ទនៅក្នុងគ្រាលំបាក ជំនួសឲ្យការពឹងផ្អែកលើការយល់ដឹងរបស់ខ្ញុំផ្ទាល់ ។ ខ្ញុំដឹងថា ខ្ញុំអាចយកឈ្នះលើឥទ្ធិពលនៃភាពខ្មៅងងឹត តាមរយៈការព្យាយាមស្វែងរកភាពភ្លឺនៃពន្លឺព្រះគ្រីស្ទ ។

***អូលីវៀ អេច អាយុ ១៧ ឆ្នាំ ប្រទេសប៊ែលសិក***

***អំពីខ្ញុំ ៖*** អ្នកហែលទឹក ចូលចិត្តការបម្រើ រួមមានការស្ម័គ្រចិត្តធ្វើម្ហូបនៅផ្ទះបាយ អ្នកមើលថៃផ្ទះ និងកម្មវិធីអប់រំពិសេសនៅសាលា



« ខ្ញុំ

# សូមសន្យា

នឹងសមាជិកសាសនាចក្រ

វ័យក្មេងថា បើអ្នក

# ស្ដាប់

[ សន្និសីទទូទៅ ]

នោះអ្នកនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណ

ក្នុងចិត្តអ្នក ។ ព្រះអម្ចាស់នឹងប្រាប់អ្នកពីអ្វីដែល

ទ្រង់ចង់ឲ្យអ្នកធ្វើក្នុងជីវិតអ្នក » ។

អែលឌើរ រ៉ូបឺត ឌី ហែល ( ១៩៣២–២០១៧ )
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « សន្និសីទទូទៅ៖
ការពង្រឹងសេចក្ដីជំនឿ និងទីបន្ទាល់ »
សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៣ ។

# សេចក្ដីពិតស្ដីពី
# សន្និសីទទូទៅ

ព្យាណូខ្យល់នៃមជ្ឈមណ្ឌលសន្និសីទ
មានបំពង់សំឡេងចំនួន
**៧៦៦៧**
—ប៉ុន្តែមានបំពង់សំឡេងតែ ១៧០
ប៉ុណ្ណោះដែលទស្សនិជនអាចមើលឃើញ

ប្រធាន វែសុល អិម
ណិលសុន បានថ្លែង
**៨៤**
សុន្ទរកថានៃសន្និសីទទូទៅនៅក្នុង
រយៈពេល ៣៤ ឆ្នាំក្នុងនាមជាអ្នក
មានសិទ្ធិអំណាចទូទៅ

មនុស្សនៅក្នុង
**២២១**
ប្រទេស និងតំបន់ទស្សនា
សន្និសីទទូទៅ

សុន្ទរកថាត្រូវបានបកប្រែជា
**៩៤**
ភាសា




វេទិកាឈើនៃ
មជ្ឈមណ្ឌលសន្និសីទបានមក
ពីដើមវ៉លណាត់ចាស់របស់
**ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី**
( ១៩១០–២០០៨ )

មនុស្សជាង
**១០០០០០**
ចូលរួមសម័យប្រជុំទាំងប្រាំនៅមជ្ឈមណ្ឌលសន្និសីទក្នុងទីក្រុង
សលត៍ លេក រដ្ឋយូថាហ៍ ស.រ.អា.

**យន្តហោះប៊ូអ៊ីង ៧៤៧**—ដែលមានប្រវែង ៧០.៥
ម៉ែត្រ—អាចដាក់ចូលក្នុងសាលប្រជុំមជ្ឈមណ្ឌលសន្និសីទ

មានសុន្ទរកថាប្រហែល
**៣៥**
ត្រូវបានថ្លែងរៀងរាល់សន្និសីទ

## ការប្រកាសដែលអាចកត់សម្គាល់បានអំឡុងពេលសន្និសីទទូទៅ ៖

**ខែ កញ្ញា ឆ្នាំ ១៩៩៥ ៖**
« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក »

**ខែ មេសា ឆ្នាំ ១៩៩៨ ៖**
ការសាងសង់ព្រះវិហារបរិសុទ្ធដែលតូចជាងមុន

**ខែ មេសា ឆ្នាំ ២០០១ ៖**
មូលនិធិអប់រំដែលមានជាបន្តបន្ទាប់បានចាប់ផ្ដើម

**ខែ តុលា ឆ្នាំ ២០១២ ៖**
អាយុនៃពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានបន្ថយចុះ

**ខែ មេសា ឆ្នាំ ២០១៨ ៖**
ការងារបម្រើជំនួស ការបង្រៀនតាមផ្ទះ និងការបង្រៀនសួរសុខទុក្ខ

រូបភាពមកពី GETTY IMAGES



# « តើខ្ញុំអាចយាងព្រះវិញ្ញាណបរិសុទ្ធមកក្នុងគេហដ្ឋានខ្ញុំ ពេលយើងកំពុងមានជម្លោះ ឬការទាស់ទែងគ្នាតាមរបៀបណា ? »

**ចូរធ្វើជាអ្នកផ្សះផ្សាគេ**

*« ពេលយើងពុំអាចផ្លាស់ប្ដូរឥរិយាបថរបស់អ្នកដទៃ នោះយើងនឹងត្រូវគ្រប់គ្រងខ្លួនយើងឲ្យបានត្រឹមត្រូវ ។ . . .*

*តួនាទីរបស់យើងនៅក្នុងជម្លោះ និងការកកាំរកុះរវាងសមាជិកគ្រួសារគឺត្រូវស្ដាបនា ស្ដាប់ និងពិគ្រោះគ្នា » ។*

អែលឌើរ ម៉ាវីន ជេ អាស្ហុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ( ឆ្នាំ ១៩១៥–១៩៩៤ ) « No Time for Contention,» សន្និសីទទូទៅខែមេសា ឆ្នាំ ១៩៧៨ ។



## ប្រាប់រឿងរបស់អ្នក

ពេលខ្ញុំមានជម្លោះ ខ្ញុំបានឃើញថា ការនិយាយពាក្យសូមទោស និងសារភាពថាអ្នកខុស ទោះបីអ្នកគិត ឬដឹងថាអ្នកត្រូវក្ដី វាជួយនាំភាពសុខសាន្តត្រឡប់មកកាន់បន្ទប់នោះវិញ ។ បន្ទាប់មកដើរចេញ នៅស្ងៀម ប្ដូរប្រធានបទ ឬស្វែងរកចំណុចអ្វីមួយដើម្បីយល់ស្របនឹងគ្នា ។ វាពុំចំណាយពេលច្រើនឡើយដើម្បីឲ្យព្រះវិញ្ញាណយាងត្រឡប់មកវិញនោះ ។

***ឌីលែន អិម អាយុ ១៥ ឆ្នាំ រដ្ឋកាលីហ្វូញ៉ា ស.រ.អា.***

## សូមស្រឡាញ់

ខ្ញុំបានឃើញថា ការបង្ហាញសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធចំពោះគ្រួសារអ្នកយាងអញ្ជើញព្រះវិញ្ញាណឲ្យគង់នៅក្នុងគេហដ្ឋានរបស់យើង ។ ព្យាការីបានថ្លែងអំពីសេចក្ដីស្រឡាញ់ថា ជាកាតាលីករដែលបណ្ដាលឲ្យផ្លាស់ប្ដូរ និងជាថ្នាំដែលនាំមកនូវការព្យាបាលដល់ព្រលឹង ។ វិញ្ញាណនៃក្ដីស្រឡាញ់នាំមកនូវសុវត្ថិភាព និងភាពសុខសាន្តក្នុងគេហដ្ឋាន ។

***យ៉ូសែប ស៊ី អាយុ ១៨ ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា.***

## សូមនិយាយទៅកាន់គ្រួសាររបស់អ្នក

ប្រសិនបើគ្រួសារអ្នកពុំមែនជាសមាជិកសាសនាចក្រ សូមប្រាប់ពួកគេអំពីអារម្មណ៍អាក្រក់ដែលអ្នកមានពេលពួកគេឈ្លោះគ្នា ហើយសូមឲ្យពួកគេកែលម្អ ។ ប្រសិនបើវាពុំដំណើរការទេនោះ សូមអធិស្ឋាន ហើយព្យាយាមម្ដងទៀត ។ ប្រសិនបើពួកគេជាសមាជិក សូមរំឭកពួកគេថា ពួកគេគឺជាកូនរបស់ព្រះ ហើយថាពួកគេគួរតែចៀសវាងការឈ្លោះទាស់ទែងគ្នា ។

***ខារ៉ូលីណា អេស អាយុ ១៩ ឆ្នាំ ទីក្រុង ហ្គូយអាស ប្រទេសប្រេស៊ីល***



អធិស្ឋានទូលសូមព្រះវិញ្ញាណ នៅពេលណាដែលគ្រួសារកំពុងឈ្លោះគ្នា វាពិបាកនឹងទទួលអារម្មណ៍ពីវត្តមាននៃព្រះវិញ្ញាណ ប៉ុន្តែនោះពុំមែនមានន័យថា អ្នកពុំអាចទទួលអារម្មណ៍ពីទ្រង់នោះទេ ប្រសិនបើអ្នកសក្ដិសមនោះ ។ សូមអធិស្ឋានក្នុងចិត្តអ្នកទូលសូមការបង្កើននូវព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ហើយយកចិត្តទុកដាក់បន្ថែមទៀតចំពោះការបំផុសគំនិតដែលទ្រង់បានប្រទានមក ។ ព្រះវរបិតាសួគ៌អាចជួយអ្នកឲ្យទទួលអារម្មណ៍សុខសាន្ត ហើយដឹងអំពីរបៀបដ៏ល្អបំផុតដើម្បីជួយនាំភាពសុខសាន្តនោះចូលក្នុងគេហដ្ឋានអ្នក ។

*ខាធី ដី អាយុ ១៧ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.*

## ព្យាយាមដោះស្រាយ

សូមនិយាយជាមួយគ្រួសារអ្នកដើម្បីដោះស្រាយបញ្ហាតាមរបៀបមួយដែលមនុស្សគ្រប់គ្នាបានប្រយោជន៍ ឬចែកចាយខគម្ពីរ ឬច្រៀងទំនុកតម្កើង ។ អ្នកក៏អាចទូលសូមជំនួយពីព្រះវរបិតាសួគ៌ឲ្យជួយដោះស្រាយបញ្ហា ។ តាមរបៀបនេះ មនុស្សគ្រប់រូបនឹងស្ងប់ចិត្ត ហើយអាចដោះស្រាយបញ្ហាដោយពុំត្រូវការការស្រែក ឬអំពើហិង្សាឡើយ ។ ប្រាកដណាស់ ព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញដល់អ្នកនូវភាពសុខសាន្ត ហើយផ្ដល់ដល់មនុស្សគ្រប់រូបនូវបំណងប្រាថ្នាមិនឲ្យឈ្លោះគ្នាទៀតឡើយ ។

*ល្វីស អេហ្វ អាយុ ១៤ ឆ្នាំ ប្លេយ៉ា ឌេល កាមិន ប្រទេសម៉ិកស៊ិក ។*

*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យមិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

ខាងឆ្វេង ៖ រូបថតពី GETTY IMAGES




## តើទីបន្ទាល់វាលើសពីការទទួលអារម្មណ៍ឬ ?

ទីបន្ទាល់គឺជាអ្វីដែលព្រះអង្គសង្គ្រោះបានថ្លែង កាលទ្រង់បានប្រាប់ពេត្រុសថា « មិនមែនជាសាច់ឈាមទេដែលបានសម្ដែងឲ្យអ្នកស្គាល់ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ ( ម៉ាថាយ ១៦:១៧ ) ។ វាគឺជាចំណេះដឹងពីព្រះដែលបានបើកសម្ដែងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលជាសំឡេងដែលយើងទទួលអារម្មណ៍ជាជាងស្ដាប់ឮ ប៉ុន្តែព្រះវិញ្ញាណយាងមកទាំង « នៅក្នុងគំនិតរបស់អ្នក *និង* នៅក្នុងចិត្តរបស់អ្នក » ( គ. និង ស ៨:២ ការគូសបញ្ជាក់បានបន្ថែម ) — គំនិតរបស់យើង ព្រមទាំងអារម្មណ៍របស់យើងផងដែរ ។

ព្យាការី យ៉ូសែប ស៊្មីធ បានពិពណ៌នាអំពីវិញ្ញាណនៃវិវរណៈថា ជាអារម្មណ៍នៃ « បញ្ញាដ៏សុទ្ធសាធដែលហូរចូលមកកាន់អ្នក [ ដោយផ្ដល់ ] ដល់អ្នកនូវគំនិតភ្លាមៗ » ( *ការបង្រៀននៃប្រធានសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ១៣២ ) ។

ពេលយើងបែរគំនិត និងដួងចិត្តរបស់យើង — គំនិត អារម្មណ៍ និងបំណងប្រាថ្នារបស់យើង — ទៅរកព្រះ នោះទ្រង់អាចមានបន្ទូលមកកាន់គំនិត និងដួងចិត្តរបស់យើងជាមួយនឹងសំឡេងតូចរហៀងនៃព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលទ្រង់ទាក់ទងនឹងវិញ្ញាណរបស់យើង នោះអារម្មណ៍ និងគំនិតជាក់លាក់ហាក់ដូចជាហូរមកកាន់ពួកយើង ។ នេះគឺជាទីបន្ទាល់ដែលទ្រង់ប្រទានឲ្យពួកយើង ។

***តើអ្នកគិតដូចម្ដេច ?***

« តើខ្ញុំអាចស្វែងរកមិត្តភក្ដិដែលមានបទដ្ឋានល្អដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទៅកាន់គេហទំព័រ liahona.lds.org ( សូមចុច « Submit an Article » ) ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

# មាគ៌ាដែលរៀបចំខ្លួនអ្នកសម្រាប់អនាគតរបស់អ្នក

**ដោយ លៀច បាតុន**
ទស្សនាវដ្ដីសាសនាចក្រ

ខ្ញុំពុំគិតថា វាជាក្ដីសុបិនរបស់ក្មេងស្រីអាយុ ១៤ ឆ្នាំ ដើម្បីឃើញខ្លួននាងនៅក្នុងជង្រុកស្រូវមួយដែលប្រឡាក់ដី លើកពេលព្រេះ សម្អាតក្រោលសេះដ៏ស្អុយឡើយ ។ ប៉ុន្តែនោះគឺជាកិច្ចការរបស់ខ្ញុំរៀងរាល់ថ្ងៃបន្ទាប់ពីចេញពីសាលារៀន រហូតដល់ខ្ញុំធំល្មមដើម្បីបានការងារមួយផ្សេង ។

ប្រាកដណាស់ វាពុំមែនជាស្ថានភាពល្អឥតខ្ចោះរបស់ខ្ញុំដើម្បីធ្វើការអំឡុងពេលរៀនវិទ្យាល័យឡើយ ប៉ុន្តែកាលនោះខ្ញុំបានយល់ថា ប្រសិនបើខ្ញុំចង់បានការងារមួយដែលខ្ញុំពិតជាចូលចិត្ត — ជាការងារមួយដែលមិនទាក់ទងនឹងការសម្អាតសត្វទាំងនេះ — នោះខ្ញុំត្រូវការមហាវិទ្យាល័យ ហើយខ្ញុំត្រូវទៅរៀនមហាវិទ្យាល័យ ខ្ញុំត្រូវការប្រាក់ ។ ខ្ញុំបានដឹងថា ( ដោយក្ដីសង្ឃឹម ) សម្រាប់ខ្ញុំការអប់រំគឺជាជំហានត្រឹមត្រូវឆ្ពោះ ទៅការបំពេញមុខរបរមួយ ។

រឿងដែលល្អនោះគឺថា ផ្លូវដែលខ្ញុំបានជ្រើសរើសគឺជាផ្លូវមួយនៃផ្លូវជាច្រើនដែលអាចជួយខ្ញុំឲ្យរៀនធ្វើការ និងផ្ដល់តម្រូវការខ្ញុំផ្ទាល់ ។ នេះមានន័យថា ត្រូវមានភាពខ្លួនទីពឹងខ្លួនទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ។ នៅពេលអ្នកពិចារណាអំពីជម្រើសរបស់អ្នក សូមព្យាយាមជ្រើសផ្លូវដែលអ្នកទទួលអារម្មណ៍ថានឹងរៀបចំអ្នកបានល្អបំផុត ។

រឿងទាំងនេះបានមកពីមនុស្សដែលមានអាយុស្របាលអ្នកកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ ។ តាមរយៈការធ្វើតាមគំរូនៃយុវមជ្ឈិមវ័យទាំងនេះ អ្នកអាចរកឃើញផ្លូវផ្ទាល់ខ្លួនអ្នកឆ្ពោះទៅរកភាពខ្លួនទីពឹងខ្លួនយ៉ាងជោគជ័យ ។



## ពិចារណាអំពីតម្រូវការជុំវិញអ្នក

*ដោយ ឧត្តម ពិសិដ្ឋ ប្រទេសកម្ពុជា*

ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្ញុំ ខ្ញុំប្រាប់ខ្លួនខ្ញុំជានិច្ចថា ការខិតខំធ្វើការគឺមានសារៈសំខាន់ណាស់ ប៉ុន្តែរបៀបមួយដើម្បីឲ្យពូកែនោះគឺការធ្វើការដោយឈ្លាសវៃ ។ បន្ទាប់ពីបេសកកម្មរបស់ខ្ញុំនៅប្រទេសអង់គ្លេសមក ខ្ញុំបានត្រឡប់ទៅប្រទេសកម្ពុជាវិញ ហើយស្វែងរកការងារ ។ ខ្ញុំមើលចំណុចនានាដូចជារយៈពេលនៃការបំពាក់បំប៉នដើម្បីទទួលបានការងារនីមួយៗ និងតម្លៃនៃការបំពាក់បំប៉ន ។

ខ្ញុំបានរកឃើញកម្មវិធីបំពាក់បំប៉នមួយដើម្បីធ្វើជាអ្នកបញ្ជាទិញសម្ភាររោងចក្រកាត់ដេរសម្លៀកបំពាក់ វាមានរយៈពេលខ្លី ប៉ុន្តែមានការលំបាក ហើយពុំសូវមានមនុស្សច្រើនធ្វើការងារនេះទេ ។ ខ្ញុំបានឃើញថា វាជាឱកាសល្អ ហើយខ្ញុំបានសម្រេចចិត្តរៀនវា ។ ឥឡូវនេះខ្ញុំបានរៀនចប់កម្មវិធីនេះ ហើយខ្ញុំកំពុងធ្វើការជាអ្នកបញ្ជាទិញសម្ភាររោងចក្រកាត់ដេរសម្លៀកបំពាក់មួយ ។

ការស្វែងរកមុខរបរត្រឹមត្រូវអាចជាការពិបាកណាស់ ប៉ុន្តែខ្ញុំមានព្រះអង្គសង្គ្រោះជួយខ្ញុំ ហើយលើកស្ទួយខ្ញុំឡើង ។

*ទោះបីអ្នកទៅរៀនមហាវិទ្យាល័យ ស្វែងរកការងារ ឬរៀនធ្វើជំនួញក្ដី អ្នកកំពុងអភិវឌ្ឍបុគ្គលិកលក្ខណៈដ៏ចាំបាច់ ដើម្បីស្ថាបនានគរព្រះ ។*

## ប្រើការអប់រំដើម្បីបើកឱកាសនានា

*ដោយ អ៉ីអូលែនដា ផៀសៀវ៉ា ទីក្រុង កាពេ វើដ ប្រទេសអាហ្វ្រិក*

ម្ដាយខ្ញុំលើកទឹកចិត្តខ្ញុំជានិច្ចជាមួយនឹងឃ្លាថា « ការអប់រំគឺជាគន្លឹះឆ្ពោះទៅរកភាពជោគជ័យ » ។ ខ្ញុំចង់បានអនាគតមួយដ៏ប្រសើរសម្រាប់ខ្លួនខ្ញុំ ហើយជាពិសេសសម្រាប់គ្រួសារខ្ញុំ ហើយដើម្បីធ្វើរឿងនេះ ខ្ញុំត្រូវតែបន្តការអប់រំរបស់ខ្ញុំ ។ ដោយគ្មានប្រាក់ដើម្បីទៅរៀនមហាវិទ្យាល័យនៅគ្រានោះ ខ្ញុំបានដាក់ពាក្យស្នើសុំអាហាររូបករណ៍ចូលរៀនសាលាបំពាក់បំប៉នវិជ្ជាជីវៈ ដើម្បីសិក្សាប្រព័ន្ធ និងការថែទាំកុំព្យូទ័រ ។

ពេញមួយកម្មវិធីសិក្សារបស់ខ្ញុំ ខ្ញុំបានជួបនឹងឧបសគ្គជាច្រើន ប៉ុន្តែវាពុំអាចបញ្ឈប់ខ្ញុំពីការបន្តឆ្ពោះទៅមុខដោយកែវភ្នែកសម្លឹងទៅរកថ្ងៃដ៏ប្រសើរនោះទេ ។ ការអធិស្ឋានបានជួយខ្ញុំយ៉ាងច្រើន ខ្ញុំស្វែងរកការទូន្មានមកពីព្រះអម្ចាស់ជានិច្ច ។ ខ្ញុំតាំងចិត្តចំពោះការសិក្សាខ្ញុំជានិច្ច ហើយសព្វថ្ងៃនេះ ខ្ញុំបន្តតាំងចិត្តធ្វើការងាររបស់ខ្ញុំ ខំប្រឹងអស់ពីសមត្ថភាពខ្ញុំក្នុងនាមជាជាងជួសជុលកុំព្យូទ័រ និងជំនួយការផ្នែកទីផ្សារ ។





រូបភាពខ្នែខាងក្រោយ ដោយ ចូស ថលប៊ឺត ផ្ទាំងបញ្ចូលដោយ GETTY IMAGES

# ធ្វើការបច្ចុប្បន្ននេះដើម្បីឆ្ពោះទៅកាន់អនាគតដែលអ្នកចង់បាន

*ដោយ អាន សូហ្វី និង ឡូរ៉ែន ខារីន ប្រទេសស្កុតឡង់ ចក្រភពអង់គ្លេស*





អាន-សូហ្វី ៖ ខ្ញុំចង់សិក្សានៅមហាវិទ្យាល័យជានិច្ច ប៉ុន្តែផែនការរបស់ខ្ញុំអំពីអ្វីដែលត្រូវសិក្សាបានផ្លាស់ប្ដូរយ៉ាងច្រើន អំឡុងពេលនៃយុវវ័យរបស់ខ្ញុំ ។ បន្ទាប់ពីរៀនចប់វិទ្យាល័យ ខ្ញុំបានស្ម័គ្រចិត្តនៅក្នុងមន្ទីរពេទ្យរយៈពេលប្រាំមួយខែ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានចូលចិត្តគំនិតមួយនៃការក្លាយជាគិលានុបដ្ឋាយិកា ប៉ុន្តែខ្ញុំគិតថា ខ្ញុំពុំអាចធ្វើវាបានទេ ។

នៅក្នុងថ្នាក់ភាពខ្លួនទីពឹងខ្លួនរបស់វួដខ្ញុំ យើងត្រូវបានសូមឲ្យរើសយកការងារមួយដែលយើងចូលចិត្ត ទោះបីជាយើងមិនអាចមានគុណសម្បត្តិនឹងការងារនោះក្ដី ។ ខ្ញុំបានអធិស្ឋានអំពីអ្វីដែលត្រូវធ្វើ ហើយការធ្វើជាគិលានុបដ្ឋយិកាបានបន្តផុសឡើងក្នុងគំនិតខ្ញុំ ។ ខ្ញុំបានសម្រេចចិត្តធ្វើតាមការបំផុសគំនិតពីព្រះអម្ចាស់ ។ ការចាប់យកជំនាញនៅលើផ្លូវនេះពុំងាយស្រួលឡើយ ។ ដើម្បីចាប់ផ្ដើម ខ្ញុំបានស្រាវជ្រាវកម្មវិធីគិលានុបដ្ឋយិកា និងអ្វីដែលតម្រូវឲ្យខ្ញុំរៀន ។ ខ្ញុំបាននិយាយជាមួយមនុស្សដែលបានឆ្លងកាត់ដំណើរការស្រដៀងនោះ ។ នៅគ្រាដំបូង ខ្ញុំបានដាក់ពាក្យរៀនកម្មវិធីគិលានុបដ្ឋយិកា ខ្ញុំត្រូវបានដាក់ឲ្យនៅក្នុងបញ្ជីរង់ចាំ ។ ប៉ុន្តែខ្ញុំពុំបោះបង់ចោលឡើយ ខ្ញុំបានដាក់ពាក់សុំម្ដងទៀត ហើយទីបំផុតខ្ញុំអាចចូលរៀនបាន ។ ជួនកាលអ្នកត្រូវតែអត់ធ្មត់ ហើយទុកចិត្តលើព្រះអម្ចាស់នៅពេលទ្រង់មានផែនការផ្ទាល់សម្រាប់អ្នក ។

ឡូរ៉ែន ៖ កាលខ្ញុំនៅក្មេង ខ្ញុំបានដាក់គោលដៅដើម្បីធ្វើជាមនុស្សដែលមានសមត្ថភាពបំផុតតាមដែលខ្ញុំអាចធ្វើបាន ទោះបីខ្ញុំរៀនមុខវិជ្ជាអ្វី ឬធ្វើការងារអ្វីក៏ដោយ ។ ខ្ញុំតែងតែព្យាយាមរៀនសូត្រ និងកែលម្អខ្លួន ដើម្បីផ្ដល់ដល់ខ្លួនខ្ញុំនូវឱកាសសម្រាប់ភាពជោគជ័យ ។

បច្ចុប្បន្ននេះ ខ្ញុំធ្វើការជាអ្នកគ្រប់គ្រងម្នាក់នៅរោងចក្រកាត់ដេរ ប៉ុន្តែខ្ញុំចង់ចូលធ្វើជាកងកម្លាំងប៉ូលីស ។ នៅប្រទេសស្កុតឡង់ អ្នកត្រូវរស់នៅក្នុងប្រទេសរយៈពេលបីឆ្នាំជាប់គ្នា ពីមុនដាក់ពាក្យសូមធ្វើជាប៉ូលីស ។ ដោយសារការបម្រើបេសកកម្ម ខ្ញុំបានរស់នៅក្រៅប្រទេសអស់រយៈពេលពីរឆ្នាំ នោះខ្ញុំត្រូវរង់ចាំពីរបីខែទៀតពីមុនខ្ញុំអាចចូលក្រុមនោះបាន ។

ទោះបីវាជាឧបសគ្គដ៏ធំដែលពាំងផ្លូវខ្ញុំក្ដី ខ្ញុំពុំបោះបង់វាឡើយ ។ ខ្ញុំមានការងារល្អដើម្បីផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំ ហើយខ្ញុំបានខិតខំធ្វើការដើម្បីប្រាកដថា ខ្ញុំមានឈ្មោះល្អដើម្បីគេអាចណែនាំសម្រាប់ការងារនាពេលអនាគត ។

ដូចជាពួកយុវមជ្ឈិមវ័យទាំងនេះដែរ អ្នកនឹងរកឃើញនូវផ្លូវជាច្រើនដែលអាចរៀបចំអ្នកឲ្យមើលថែខ្លួនអ្នក និងគ្រួសារនាពេលអនាគតរបស់អ្នក ។ ដោយមានគោលដៅក្នុងចិត្តនោះអ្នកអាចដាក់ផែនការសម្រាប់ភាពជោគជ័យ ។ អែលឌើរ ឌៀថើរ អែស្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ចូរយើងធ្វើឲ្យអស់ពីសមត្ថភាពដែលយើងអាចធ្វើបាន ហើយបណ្ដុះកេរ្តិ៍ឈ្មោះសម្រាប់ភាពឥតខ្ចោះនៅក្នុងគ្រប់កិច្ចការដែលយើងធ្វើ ។ ចូរយើងដាក់គំនិត និងរូបកាយរបស់យើងទៅរកឱកាសដ៏រុងរឿងនៃការងារដែលមានថ្មីៗរៀងរាល់ថ្ងៃនេះ » ( « Two Principles for Any Economy » សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០០៩ ) ។ នៅពេលអ្នកផ្ដោតយកចិត្តទុកដាក់ក្នុងពេលនេះទៅលើការរៀនសូត្រ និងការងារ នោះអ្នកនឹងបង្កើតទម្លាប់នានាដែលនឹងជួយអ្នកឲ្យទទួលអារម្មណ៍ថាមានទំនុកចិត្តកាន់តែខ្លាំងអំពីអនាគត ។ ■

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ សូមគិតពីការសួរប៊ីស្សពរបស់អ្នកឲ្យណែនាំអ្នកស្គាល់អ្នកឯកទេសភាពខ្លួនទីពឹងខ្លួននៅក្នុងស្តេករបស់អ្នក ។ ពួកគេអាចជួយអ្នកឲ្យរកមើលឱកាសនានាសម្រាប់ការអប់រំ និងការងារនាពេលអនាគតរបស់អ្នក ។*

# ការស្វែងរកមាគ៌ារបស់អ្នក

## ១.

**ស្គាល់ខ្លួនឯង**

តើអ្នកពូកែខាងអ្វី ? តើអ្នកចូលចិត្តធ្វើអ្វី ? ការឆ្លើយសំណួរទាំងនេះអាចជួយអ្នករកឃើញមុខរបរដែលនឹងអាចមាន ដែលត្រូវនឹងជំនាញ ចំណាប់អារម្មណ៍ និងទេពកោសល្យដែលអ្នកមានរួចជាស្រេចនោះ ។

**តម្រុយ ៖** សូមគិតពីការសួរឪពុកម្ដាយ គ្រូបង្រៀន និងមិត្តភក្តិរបស់អ្នកអំពីទេពកោសល្យដែលពួកគេឃើញថាអ្នកមាន ។ អ្នកអាចនឹងភ្ញាក់ផ្អើលចំពោះអ្វីដែលពួកគេនិយាយ !

## ២.

**ស្គាល់ពីពិភពលោកជុំវិញអ្នក**

តើការងារអ្វីខ្លះដែលកំពុងត្រូវការនៅកន្លែងដែលអ្នករស់នៅ ? តើក្រុមហ៊ុនមួយណាដែលកំពុងរើសមនុស្សធ្វើការ ? វាជារឿងឈ្លាសវៃដើម្បីរើសយកផ្លូវនៃមុខរបរមួយនៅក្នុងកន្លែងមួយដែលរីកចម្រើន ហើយដែលនឹងទំនងជាមានឱកាសនាពេលអនាគត ។

**តម្រុយ ៖** ជារឿយៗ មហាវិទ្យាល័យ សាកលវិទ្យាល័យ ឬសាលាជំនួញស្គាល់ជំនាញនានាដែលកំពុងត្រូវការ និងវិស័យណាដែលកំពុងរីកចម្រើន ។

## ៣.

**ដឹងអ្វីដែលអ្នកត្រូវធ្វើបន្ទាប់ទៀត**

តើមានតម្រូវការរៀបចំអ្វីខ្លះសម្រាប់ការងារដែលអ្នកចង់ធ្វើ ? តើអ្នកនឹងទទួលការបំពាក់បំប៉ន និងការអប់រំដែលអ្នកត្រូវការនៅកន្លែងណា ? តើអ្នកនឹងបង់ថ្លៃការអប់រំនោះយ៉ាងដូចម្ដេច ? ដើម្បីសម្រេចបាននូវគោលដៅមុខរបរយូរអង្វែងមួយ អ្នកចាំបាច់ត្រូវដឹងអំពីរបៀបដើម្បីទៅដល់ទីនោះ ។

**តម្រុយ ៖** សូមគិតពីការនិយាយជាមួយនរណាម្នាក់ដែលកំពុងធ្វើនូវអ្វីដែលអ្នកចង់ធ្វើ ។ សួរសំណួរពួកគេ ។ ភាគច្រើនមនុស្សរីករាយនឹងផ្ដល់ការទូន្មាន និងយោបល់នានា ។

# ការចែកចាយ សេចក្ដីស្រឡាញ់នៃព្រះ



**ដោយ អាលី ប៊ី អាយុ ១២ ឆ្នាំ រដ្ឋខេនធើឃី ស.រ.អា.**

មួយរយៈកន្លងទៅ គ្រួសារខ្ញុំ និងខ្ញុំបានប្ដូរទៅរស់នៅរដ្ឋខេនធើឃី ។ ខ្ញុំពិតជាអន់ចិត្តណាស់ដោយសារខ្ញុំត្រូវចេញពីមិត្តភក្ដិ និងសាច់ញាតិរបស់ខ្ញុំ ។ រដ្ឋខេនធើឃីគឺជារដ្ឋមួយផ្សេងពីកន្លែងដែលខ្ញុំធ្លាប់រស់នៅ ។ គ្រាដំបូងដែលយើងបានទៅព្រះវិហារ ខ្ញុំបានឃើញថា ពុំសូវមានមនុស្សច្រើននៅទីនោះឡើយ ។ ពេលខ្ញុំដឹងថា យើងមានសមាជិកតិចនៅសាខាដូច្នោះ ខ្ញុំបានសម្រេចចិត្តថា ជំនួសឲ្យការគិតមិនល្អអំពីសាខានេះ នោះខ្ញុំនឹងធ្វើអ្វីមួយ ។

នៅថ្ងៃបន្ទាប់ ម្ដាយខ្ញុំ និងខ្ញុំបានទៅហាងទំនិញមួយ ។ ពីមុនយើងចេញពីផ្ទះ ខ្ញុំបានចាប់យកប័ណ្ណចែកចាយមួយដុំ ។ ពេលយើងទៅដល់ហាងទំនិញ ខ្ញុំបានយកស្ករគ្រាប់មួយដុំ ហើយបានចេញទៅបង់ប្រាក់ ។ បេឡាករបានស្កេនស្ករគ្រាប់នោះ បន្ទាប់មកហុចវាឲ្យខ្ញុំ ។ ខ្ញុំបានហុចវាត្រឡប់ទៅវិញ ។ គាត់បានមើលមកខ្ញុំដោយងឿងឆ្ងល់ ហើយនិយាយថា « ប្អូនទើបតែបានបង់ប្រាក់រួចសម្រាប់ស្ករគ្រាប់នេះ » ។

ខ្ញុំបាននិយាយថា « ខ្ញុំដឹង ប៉ុន្តែខ្ញុំជូនបងទុកជាអំណោយ » ។ បន្ទាប់មកខ្ញុំបានដាក់ប័ណ្ណចែកចាយមួយជាមួយនឹងស្ករគ្រាប់នោះ ។ គាត់បានញញឹម ហើយអរគុណខ្ញុំ ។ គាត់បានមើលផ្នែកខាងក្រោយនៃប័ណ្ណចែកចាយនោះ នៅលើប័ណ្ណនោះខ្ញុំបានសរសេរថា « មនុស្សគ្រប់គ្នាគឺជាបុត្ររបស់ព្រះ » ។ ខ្ញុំបានដើរចេញទៅដោយមានសុភមង្គល ដោយដឹងថា ទោះបីជាគាត់ពុំចូលរួមសាសនាចក្រក្ដី ខ្ញុំនៅតែបានធ្វើអ្វីមួយដែលល្អ ។

បន្តិចក្រោយមកនៅថ្ងៃដដែលនោះ ខ្ញុំបានចាំថា ខ្ញុំបានទុកប័ណ្ណចែកចាយដែលនៅសល់នៅកន្លែងម៉ាស៊ីនគិតប្រាក់នោះ ។ ក្រោយមក ពេលយើងបានទៅហាងនោះទៀត ខ្ញុំបានទៅសួរ ប្រសិនបើប័ណ្ណទាំងនោះនៅតែនៅទីនោះ ។ ក្រោយមក ខ្ញុំបានឃើញអ្វីមួយ ហើយខ្ញុំបានឈប់នៅស្ងៀម ។ ម៉ាស៊ីនគិតប្រាក់ប្រហែលជាប្រាំមានប័ណ្ណចែកចាយនោះដែលសរសេរថា « មនុស្សគ្រប់គ្នាគឺជាបុត្ររបស់ព្រះ » ។ បេឡាករនោះបានចែកចាយកាតទាំងនោះ ! ខ្ញុំមានអារម្មណ៍សប្បាយរីករាយចំពោះអ្វីដែលខ្ញុំបានធ្វើ ។ ■





# ការអធិស្ឋាននៅឯជ្រលងភ្នំ



**ដោយ ខាសិន ខេ អាយុ ១១ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.**

កាលពីឆ្នាំមុន ខ្ញុំបានឡើងភ្នំជាមួយឪពុក និងបងប្រុសខ្ញុំ ។ យើងបានឡើងទៅដល់ជ្រលងភ្នំដ៏ជ្រៅ ។ មិនយូរប៉ុន្មានក្រោយមក យើងបានចាប់ផ្ដើមមើលផ្លូវកៀនៗ ។ យើងបានឃើញរូងធំ និងកន្លែងដែលមើលឃើញទេសភាពស្អាតៗ ។ យើងបានឡើងកាន់តែខ្ពស់ទៅៗ ហើយខ្ពស់ផុតពីថ្មវែងៗ និងកូនភ្នំដែលចោត ។

មួយរយៈក្រោយមក យើងបានវង្វេងផ្លូវទាំងស្រុង ។ យើងពុំដឹងថា តើផ្លូវណាអាចត្រឡប់ចុះទៅកាន់បាតនៃជ្រលងភ្នំវិញទេ ។ យើងបាននៅជាប់ក្នុងព្រៃគុម្ពពោតដ៏ក្រាស់ ដោយមើលពុំឃើញទាំងកំពូល និងបាតនៃជ្រលងភ្នំ ។ ខ្ញុំបានចាប់ផ្ដើមមានភាពស្មុគស្មាញជាខ្លាំង ។ ខ្ញុំពុំដឹងថាត្រូវទៅណា ហើយឪពុកខ្ញុំក៏ដូចគ្នាផងដែរ !

មេឃចាប់ផ្ដើមងងឹត ហើយត្រជាក់ ហើយយើងមិនដឹងពីរបៀបចេញពីជ្រលងភ្នំនោះឡើយ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ដឹងផ្លូវណាដែលត្រូវទៅ ។

ខ្ញុំបាននិយាយថា « ប្រសិនបើយើងចង់ចេញពីទីនេះ នោះយើងត្រូវតែអធិស្ឋាន ! » ដូច្នេះយើងទាំងបីនាក់បានលុតជង្គង់ចុះអធិស្ឋាន ដោយទូលសូមឲ្យព្រះវរបិតាសួគ៌ដឹកនាំយើងចេញពីជ្រលងភ្នំនោះ ។

នៅពេលយើងចាប់ផ្ដើមដើរ មានអារម្មណ៍មួយបានប្រាប់ខ្ញុំថា ពេលខ្ញុំឃើញដើមឈើត្រង់ខ្ពស់ៗ នោះខ្ញុំគួរតែបត់ឆ្វេង ។ បន្ទាប់ពីខ្ញុំបត់ឆ្វេង ខ្ញុំបានឃើញឡានរបស់យើង ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌បានជួយយើងឲ្យចេញពីជ្រលងភ្នំនោះ ។ ព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់យើង ហើយយើងបានរកឃើញផ្លូវចេញមកដោយសុវត្ថិភាព — គឺចំពេលដែលព្រះអាទិត្យបានលិច ។

ខ្ញុំមានអំណរគុណសម្រាប់អំណាចនៃការអធិស្ឋាន និងសម្រាប់ការឆ្លើយតបរបស់ព្រះវរបិតាសួគ៌ ។ ■

# ការបញ្ចាំងពន្លឺនៅក្នុងសាធារណៈរដ្ឋឆែក

*ចងក្រងដោយ សារ៉ុន ហ្គោដរិច ទស្សនាវដ្ដីសាសនាចក្រ*

យើងគឺជាកុមារនៅថ្នាក់បឋមសិក្សានៅក្នុងសាធារណៈរដ្ឋឆែក ។ នេះគឺជារបៀបដែលយើងបញ្ចាំងពន្លឺនៅក្នុងប្រទេសរបស់យើង ។

មានគ្រាមួយ ខ្ញុំបានបាត់ស្រោមដៃដែលខ្ញុំចូលចិត្ត ។ ខ្ញុំកើតទុក្ខជាខ្លាំង ។ ម្ដាយខ្ញុំ និងខ្ញុំបានអធិស្ឋាន ប៉ុន្តែយើងរកវាពុំឃើញទេ ។ ខ្ញុំបានព្យាយាមឲ្យមានសេចក្ដីជំនឿ ។ មួយសប្ដាហ៍ក្រោយមក ប្អូនប្រុសរបស់ខ្ញុំបានរកឃើញស្រោមដៃខ្ញុំនៅតាមផ្លូវ ! ព្រះបានឆ្លើយតបការអធិស្ឋានរបស់យើង ។ ខ្ញុំស្រឡាញ់ទ្រង់ ហើយខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ !

**អែនដ្រៀ ដបុលយូ អាយុ ៩ ឆ្នាំ**





ខ្ញុំមានមិត្តភក្តិនៅសាលារៀនដែលពុំមែនជាសមាជិកសាសនាចក្រទេ ប៉ុន្តែពួកគេនៅតែគោរពបទដ្ឋានរបស់ខ្ញុំ ។ ពេលខ្ញុំនិយាយថា យើងគួរតែអធិស្ឋាន ពួកគេបានយល់ព្រម ! ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ។

**អ៊ីវ៉ាំណា អេ អាយុ ១១ ឆ្នាំ**








មិត្តភក្តិខ្ញុំ និងខ្ញុំកំពុងចុះទៅជាន់ក្រោម ។ ពេលយើងទៅដល់ជណ្ដើរយោង ខ្ញុំមានអារម្មណ៍អត់ល្អ ហើយសូមកុំឲ្យមិត្តខ្ញុំប្រើជណ្ដើរយោងនោះឡើយ ។ តែពួកគេបានសម្រេចចិត្តជិះជណ្ដើរយោងនោះ ។ ខ្ញុំបានចុះតាមជណ្ដើរធម្មតាវិញ ។ ពេលខ្ញុំចុះទៅដល់ជាន់ក្រោម មិត្តភក្តិរបស់ខ្ញុំមិននៅទីនោះទេ ។ ជណ្ដើរយោងនោះបានជាប់គាំង ! វាគាំងមួយរយៈពេលធំពីមុនពួកគេអាចចេញវិញបាន ។ ខ្ញុំរីករាយដែលគ្មានបញ្ហាអ្វីធ្ងន់ធ្ងរបានកើតឡើង ។ ខ្ញុំក៏ទទួលអារម្មណ៍ល្អដែលខ្ញុំបានធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ ។



**អាម៉ាលី អិន អាយុ ១០ ឆ្នាំ**



នៅឯមាត់សមុទ្រ មេឃបានចាប់ផ្ដើមងងឹត ។ ខ្យល់បានបោកបក់ ហើយធ្វើឲ្យមានរលកធំៗ ។ មានរន្ទះបាញ់ ផ្លេកបន្ទោរ និង ដុំទឹកកកធំៗ ។ មនុស្សម្នាបានរត់ទៅរកទីជ្រក ។ យើងគ្មាន គ្រោះថ្នាក់ដោយសារព្យុះនោះទេ ។ នៅតាមផ្លូវទៅផ្ទះវិញ យើងបាន ឃើញឥន្ទធនូបី ។ យើងដឹងថា ព្រះបានជួយ និងការពារយើង ។

**ចាកូប ប៊ី អាយុ ១០ ឆ្នាំ**





នៅសាលារៀន ខ្ញុំមានមិត្តម្នាក់ដែលគ្មាននរណាផ្សេងទៀត ចង់រាប់អានគាត់ជាមិត្តឡើយ ។ ក្មេងផ្សេងទៀតបានចាប់ផ្ដើម និយាយពាក្យអាក្រក់ៗដាក់នាងដែលធ្វើឲ្យនាងមានអារម្មណ៍ អាក្រក់ ។ ខ្ញុំបានប្រាប់ គ្រូបង្រៀនរបស់ខ្ញុំ ហើយ បានអញ្ជើញមិត្តរបស់ខ្ញុំឲ្យ លេងជាមួយខ្ញុំ ។ វាធ្វើឲ្យ មិត្តខ្ញុំរីករាយជាខ្លាំង !

**លូមីឡា វី អាយុ ៨ ឆ្នាំ**



ខ្ញុំបានខឹងនឹងម្ដាយខ្ញុំ ដោយសារខ្ញុំពុំចង់ងូត ទឹក ហើយចូលគេង ។ នៅថ្ងៃបន្ទាប់ខ្ញុំកើតទុក្ខ ដោយសារជម្រើសមិនល្អរបស់ខ្ញុំ ។ ម៉ាក់បាន និយាយថា យើងអាចអធិស្ឋាន ហើយទូលសូម ការអភ័យទោសពីព្រះវរបិតាសួគ៌ ។ យើងបាន លុតជង្គង់ ហើយអធិស្ឋាន ។ ខ្ញុំមានអារម្មណ៍ ប្រសើរឡើងវិញ ។ ខ្ញុំបានរៀនថា យើងអាចប្រែចិត្ត ហើយដោយសារព្រះយេស៊ូវគ្រីស្ទ នោះយើង អាចទទួលបានការអត់ទោស ។

**សាំយូអែល អេច អាយុ ៥ ឆ្នាំ**







ខ្ញុំបានថ្លែងទីបន្ទាល់របស់ខ្ញុំនៅក្នុង ព្រះវិហារ ។ វាត្រូវការភាពក្លាហាន ! ចាប់តាំងពីនោះមក ខ្ញុំមានអារម្មណ៍ពី ព្រះវិញ្ញាណបរិសុទ្ធ ។

**អ៊ីលីស្កា ខេ អាយុ ១១ ឆ្នាំ**

ពេលសត្វកណ្ដុរដែលជាសត្វចិញ្ចឹមរបស់ខ្ញុំឈឺ ខ្ញុំបានអធិស្ឋានសម្រាប់វា ។ ខ្ញុំមានអំណរគុណ ចំពោះព្រះវរបិតាសួគ៌សម្រាប់ការជួយពួកយើង ។

**អាណេតា ភី អាយុ ១០ ឆ្នាំ**



## សូមផ្ញើរូបផ្កាយ មកយើង !



យើងជិតឈប់ប្រមូលរូប ផ្កាយហើយ ! ប្រសិនបើអ្នក ពុំទាន់បានផ្ញើវាមកទេ សូមប្រញាប់ឡើង ហើយ អ៊ីម៉ែលយើងនូវរូបថតនៃផ្កាយរបស់ប្អូន ជាមួយនឹងរឿង រូបថតរបស់ប្អូន ព្រមជាមួយនឹងការអនុញ្ញាតពីឪពុក ម្ដាយតាមអ៊ីម៉ែល liahona@ldschurch.org ។

## ពួកសាវកថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ





« ខ្ញុំសូមថ្លែងទីបន្ទាល់អំពីទ្រង់ថា ជាព្រះអង្គប្រោសលោះនៃពិភពលោក និងជាលោកចៅហ្វាយនៃយើងទាំងអស់គ្នា ។ ទ្រង់គឺជាបុត្រសំណព្វតែមួយគត់នៃព្រះដ៏មានព្រះជន្មរស់ ។

**ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

« *Miracles of the Restoration* » Ensign, *ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៣៤ ។*

រចនាដោយ ស៊ីមីនី ប្លូកយើរ

# ទំព័ររបស់យើង



ពេលខ្ញុំទៅព្រះវិហារ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះ និងសេចក្ដីស្រឡាញ់ដែលខ្ញុំមានចំពោះទ្រង់ និងព្រះអង្គសង្គ្រោះរបស់ខ្ញុំគឺព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំស្រឡាញ់ព្រះប្រោសលោះរបស់ខ្ញុំ ។

**អាយ៉ាណា ប៊ី អាយុ ៧ ឆ្នាំ ប្រទេសបារាំង**






ខ្ញុំចូលចិត្តនៅព្រះវិហារបរិសុទ្ធជាមួយគ្រួសារខ្ញុំ ។ វាគឺជាកន្លែងដ៏អស្ចារ្យដែលខ្ញុំអាចទៅពេលខ្ញុំអាយុ ១២ ឆ្នាំ ។ វាជាដំណាក់របស់ព្រះអម្ចាស់ ។

**អាលដូ ស៊ី អាយុ ១០ ឆ្នាំ ប្រទេសម៉ិកស៊ិក**




« ប្រធានម៉នសុន និងទីប្រឹក្សារបស់លោក »

**អូម៉ា អេ អាយុ ៩ ឆ្នាំ ប្រទេសប៉េរូ**



ខ្ញុំចូលចិត្តចែកចាយដំណឹងល្អនៅសាលារៀនជាមួយមិត្តភក្តិ ជាពិសេសជាមួយក្មេងប្រុសដែលពិបាកក្នុងការនិយាយ សរសេរ និងអានអក្សរ ។ របៀបមួយដើម្បីចែកចាយដំណឹងល្អដូចជាព្រះយេស៊ូវគ្រីស្ទបានបង្រៀននោះគឺជួយ និងបម្រើអ្នកដទៃ ។ នៅពេលណាដែលគ្រូបង្រៀនផ្ដល់ការចាត់តាំងដល់យើងនៅក្នុងសៀវភៅកិច្ចការផ្ទះ ខ្ញុំមានឆន្ទៈដើម្បីជួយក្មេងប្រុសនេះជានិច្ច ។ ខ្ញុំចូលចិត្តបម្រើអ្នកដទៃ ដោយសារវាជួយខ្ញុំឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ខ្ញុំ ។

**អាលីសុន អិម អាយុ ១០ ឆ្នាំ ប្រទេស អែល សាល់វ៉ាឌ័រ**

# សេចក្ដីសង្ឃឹម នៅក្នុងប្រទេសហូឡង់

**ដោយ មេហ្គាន អាមនិក**
ផ្អែកទៅលើដំណើររឿងពិត

*ហ្គ្រេសគឺជាក្មេងស្រីអាយុ ១៥ ឆ្នាំរស់នៅប្រទេសហូឡង់អំឡុងសង្គ្រាមលោកលើកទី II ។ សង្គ្រាមបានអូសបណ្ដាយពេលយ៉ាងយូរ ។ ប្រជាជននៅប្រទេសហូឡង់មានភាពអត់ឃ្លាន ហើយពួកគេសង្ឃឹមថា សង្គ្រាមនឹងចប់ក្នុងពេលឆាប់ៗ ។*



ឆ្នាំចុងក្រោយគេនៃសង្គ្រាមលោកលើកទី II គឺជាឆ្នាំដ៏អាក្រក់បំផុតសម្រាប់ប្រទេសហូឡង់ ។ ពួកណាស៊ីសបានគ្រប់គ្រងលើអ្វីៗគ្រប់យ៉ាង ។ ហ្គ្រេសពុំអាចទៅរៀនបានឡើយ ។ គ្មានធ្យូងដើម្បីដុតកម្ដៅនៅក្នុងផ្ទះពួកគេឡើយ ។ ហ្គ្រេស និងគ្រួសាររបស់នាងត្រូវតែបរិភោគផ្កាធូលីបដើម្បីកុំឲ្យដាច់ពោះស្លាប់ ។ វាមានរសជាតិ *មិនឆ្ងាញ់ទេ* ! កាន់តែអាក្រក់បំផុតនោះ ប៉ារបស់នាងនៅតែជាអ្នកទោសសង្គ្រាម ។

ប៉ុន្តែពួកគេនៅតែមានក្ដីសង្ឃឹម ។ មនុស្សម្នានិយាយថា ពួកណាស៊ីសបានចាញ់សង្គ្រាម ។ ហើយនៅក្នុងខែ ឧសភា ឆ្នាំ ១៩៤៥ ពួកណាស៊ីសបានចុះចាញ់ ។ ទីបំផុតប្រទេសហូឡង់មានសេរីភាពសារជាថ្មី ! មនុស្សម្នាបានអបអរសាទរនៅតាមដងផ្លូវ ។ ឥឡូវនេះហ្គ្រេសអាចត្រឡប់ទៅរៀនវិញបានហើយ ។ គ្មានទាហានដែលធ្វើឲ្យនាងខ្លាចទៀតឡើយ ។

កាន់តែល្អបំផុតនោះ នាថ្ងៃមួយពេលហ្គ្រេស និងប្អូនប្រុសនាងកំពុងដើរទៅផ្ទះពេលចេញពីរៀន ពួកគេបានឃើញថា ទង់ជាតិប្រទេសហូឡង់បានបង្ហោះឡើងនៅខាងមុខផ្ទះរបស់ពួកគេ ។ ពួកគេដឹងថា ការណ៍នោះមានអត្ថន័យអ្វីមួយ ។

ហើប៊ើរបានស្រែកថា « ប៉ាត្រឡប់មកផ្ទះវិញហើយ ! »

ហ្គ្រេស និងប្អូនប្រុសរបស់នាងបានរត់ចូលទៅក្នុងផ្ទះ ។ ហ្គ្រេសបានឱបប៉ា ហើយឱបគាត់យ៉ាងណែន ។ ឪពុកគាត់ក៏បានឱបគាត់វិញផងដែរ ។ វាជារឿងដ៏អស្ចារ្យដែលឪពុកគាត់បានត្រឡប់មកផ្ទះវិញ ។

មិនយូរប៉ុន្មានបន្ទាប់ពីរឿងនោះមក កញ្ចប់អាហារ សម្លៀកបំពាក់ និងថ្នាំពេទ្យបានចាប់ផ្ដើមមកដល់ប្រទេសហូឡង់ ។ ថ្នាក់ដឹកនាំសាសនាចក្រនៅទីក្រុងសលត៍ លេក បានបញ្ជូនគ្រឿងបរិក្ខារជាច្រើនដើម្បីជួយមនុស្សបន្ទាប់ពីសង្គ្រាម ។ ហ្គ្រេសថែមទាំងបានរ៉ូបថ្មីមួយផងដែរ ។ គាត់បានពាក់រ៉ូបដដែលៗអស់រយៈពេលប្រាំឆ្នាំហើយ ដូច្នេះគាត់សប្បាយចិត្តណាស់ដែលបានរ៉ូបថ្មីមួយ ។

ជាលើកទីមួយក្នុងរយៈពេលជាច្រើនឆ្នាំ ហ្គ្រេសមានអាហារគ្រប់គ្រាន់បរិភោគ ។ គណៈប្រធានបេសកកម្ម និងរដ្ឋាភិបាលនៅប្រទេសហូឡង់បានសម្រេចចិត្តចាប់ផ្ដើមគម្រោងដាំដំឡូងដើម្បីបានអាហារច្រើនថែមទៀត ។ សមាជិកសាសនាចក្របានដាំដំឡូងយ៉ាងច្រើននៅលើដីវាលក្បែរនោះ ។ នៅត្រឹមរដូវធ្លាក់ទឹកកក ពួកគេទទួលបានដំឡូងរាប់ពាន់ដើម្បីបរិភោគ ។

ហ្គ្រេសបានប្រាប់ប៉ាដោយចង្អុលទៅពន្លកដើមដំឡូងថា « មើលន៎ ! យើងនឹងមិនស្រេកឃ្លានទៀតទេ ! »

ប៉ាបានងក់ក្បាល តែពុំបានញញឹមទេ ។ គាត់បាននិយាយថា « ប៉ាបាននិយាយជាមួយប្រធានស្ប្រាកែ ។ គាត់បានប្រាប់ប៉ាថា ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេសអាល្លឺម៉ង់នៅតែស្រេកឃ្លាន ដូចយើងធ្លាប់ស្រេកឃ្លានផងដែរ ។ ពួកគេពុំបានទទួលជំនួយពីរដ្ឋាភិបាលដូចយើងឡើយ » ។ ប៉ាបានដាក់ដៃលើស្មារបស់ហ្គ្រេស ។ « ប្រធានស្ប្រាកែបានសួរ ប្រសិនបើយើងនឹងឲ្យដំឡូងរបស់យើងទៅពួកបរិសុទ្ធអាល្លឺម៉ង់ដែរឬអត់ ។

លះបង់ដំឡូងរបស់យើង ! » ហ្គ្រេសបានយំ ។ ប៉ុន្តែពួក *ណាស៊ីស* គឺមកពីប្រទេសអាល្លឺម៉ង់ ! « ប៉ា ពួកគេប្រហែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ប៉ុន្តែពួកគេនៅតែជាជនជាតិអាល្លឺម៉ង់ » ។

ប៉ាបាននិយាយថា « ប៉ាដឹងថា វាមិនមែនជារឿងងាយស្រួលទេ ។ ប៉ុន្តែពួកគេក៏ជាកូនរបស់ព្រះដែរ ។ ទ្រង់ស្រឡាញ់ពួកគេផងដែរ ។ ប៉ាបានអភ័យទោសឲ្យពួកគេដែលចាប់ប៉ាយកធ្វើជាឈ្លើយ ។ ព្រះអម្ចាស់អាចជួយយើងទាំងអស់គ្នាឲ្យអភ័យទោស » ។

ហ្គ្រេសបានសម្លឹងមើលទៅប៉ា ។ ប៉ាគឺជាមនុស្សម្នាក់ដ៏ក្លាហានបំផុតដែលនាងស្គាល់ ប៉ុន្តែនាងពុំដឹងថា តើនាងមានចិត្តក្លាហានដើម្បីអភ័យទោស

គំនូររូបភាពដោយ រ៉ែបេកា សុច



ដូចជាប៉ានាងបានធ្វើដែរអត់នោះទេ ។ បន្ទាប់មក នាងបានចាំពីគ្រូបង្រៀនម្នាក់របស់នាងនៅក្នុងសាលាអំឡុងពេលសង្គ្រាម ។ គ្រូបង្រៀនរបស់នាងបាននិយាយថា មិនមែនពួកអាល្លឺម៉ង់ទាំងអស់ជាពួកណាស៊ីសទេ ហើយពួកណាស៊ីសទាំងអស់ក៏មិនសុទ្ធតែជាទាហានអាក្រក់ដែរ ។ ហើយឥឡូវនេះ ក្មេងប្រុសស្រីនៅប្រទេសអាល្លឺម៉ង់កំពុងស្រេកឃ្លាន គឺដូចជាហ្វ្រេគសធ្លាប់ស្រេកឃ្លានដែរ ។

ហ្វ្រេគសបានដកដង្ហើមធំ ។ នាងបាននិយាយថា « កូនយល់ហើយ ។ ចូរឲ្យដំឡូងរបស់យើងទៅពួកគេចុះ » ។

ប៉ាបានឱបនាង ហើយញញឹម ។ « កូនគឺជាក្មេងស្រីដ៏ក្លាហានម្នាក់ ។ នេះជារឿងមួយដែលពិបាកធ្វើណាស់ ។ ប៉ុន្តែយើងគឺជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ហើយបងប្អូនប្រុសស្រីជនជាតិអាល្លឺម៉ង់របស់យើងនោះក៏ដូច្នោះដែរ ។

ហ្វ្រេគសបានញញឹម ។ កំហឹងដែលនាងមានក្នុងចិត្តបានរសាយបាត់អស់ ហើយនាងមានអារម្មណ៍ស្ងប់សុខ និងកក់ក្ដៅ ។ នាងអាចអភ័យទោសដល់ពួកអាល្លឺម៉ង់បាន ! ហើយព្រះយេស៊ូវអាចជួយនាងឲ្យស្រឡាញ់ពួកគេផងដែរ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ នូវ ជើស៊ី ស.រ.អា. ។*

ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេសហូឡង់បានឲ្យដំឡូង ៧០ តោន និងត្រីចំនួន ៩០ តោនឲ្យទៅពួកបរិសុទ្ធអាល្លឺម៉ង់ ។ ក្រោយមក នៅក្នុងឆ្នាំ ១៩៥៣ ពួកបរិសុទ្ធអាល្លឺម៉ង់បានបញ្ជូនគ្រឿងបរិក្ខារទៅឲ្យសមាជិកសាសនាចក្រនៅក្នុងប្រទេសហូឡង់បន្ទាប់ពីទឹកជំនន់ដ៏ធំមួយ ។

# ក្លឹបអាន
## ព្រះគម្ពីរមរមន

### សូមចូលរួម តាមរយៈការអានព្រះគម្ពីរមរមន !

អ្នកអាចអានដោយខ្លួនឯង ជាមួយក្រុមគ្រួសាររបស់អ្នក ឬជាមួយមិត្តភក្តិ ។ បន្ទាប់មក សូមផ្ញើរូបថតមួយដែលអ្នកកំពុងអានព្រះគម្ពីរមរមន ហើយប្រាប់យើងអំពីអ្វីដែលអ្នកបានរៀន ឬខគម្ពីរដែលអ្នកចូលចិត្តមកពីព្រះគម្ពីរមរមន ។ សូមផ្ញើវាតាមរយៈគេហទំព័រ liahona.lds.org ( សូមចុចលើ « Submit an Article » ) ។



**បទគម្ពីរសម្រាប់ខែនេះ ៖**

**មរ៉ូណៃ ១០:៤**

« . . . បើសិនជាអ្នករាល់គ្នា សូមសួរដោយចិត្តស្មោះសរ គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ នោះទ្រង់នឹងសម្ដែងសេចក្ដីពិតនៃការណ៍នេះដល់អ្នក ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » ។



រឿងដែលខ្ញុំពេញចិត្តនៅក្នុងព្រះគម្ពីរមរមនគឺនៅក្នុង នីហ្វៃទី ៣ ១៧ វាជារឿងអំពីព្រះយេស៊ូវប្រសិទ្ធពរដល់កុមារ ។ ខ្ញុំចូលចិត្តរឿងនេះ ដោយសារវាប្រាប់យើងអំពីសេចក្ដីស្រឡាញ់ដ៏ធំធេញដែលព្រះវរបិតាសួគ៌មានចំពោះយើង ។ ខ្ញុំអាចឃើញខ្លួនឯងនៅជាមួយក្មេងៗទាំងនោះ ហើយខ្ញុំស្រមៃថា ខ្ញុំកំពុងឈរនៅទីនោះ ។

**ប៉ាបូវ៉ា ដេ អាយុ ១១ ឆ្នាំ សាធារណៈរដ្ឋឆែក**



ខ្ញុំស្រឡាញ់ព្រះគម្ពីរមរមន ដោយសារវាជាព្រះគម្ពីរពិត ។ វាត្រូវបានសរសេរឡើងដោយពួកព្យាការី ។ វាជួយខ្ញុំឲ្យជ្រើសរើសត្រឹមត្រូវ ហើយនៅពេលខ្ញុំមានបញ្ហា វាបានជួយខ្ញុំ ។ ខ្ញុំជឿលើព្រះគម្ពីរនេះ ។

**ចាសុន អេស អាយុ ១០ ឆ្នាំ ទីក្រុងម៉ាហារ៉ាត្រា ប្រទេសឥណ្ឌា**

# ព្រះនាងអេសធើរមានចិត្តក្លាហាន

ព្រះនាងអេសធើរគឺជាម្ចាស់ក្សត្រីនៃស្រុកពើស៊ី ។ ស្ដេចពុំបានដឹងឡើយថា ព្រះនាងអេសធើរគឺជាសាសន៍យូដា ។ ស្ដេចមានមិត្តចិត្តអាក្រក់ម្នាក់ដែលស្អប់ពួកសាសន៍យូដា ។ គាត់បានបញ្ឆោតស្ដេចឲ្យមានបន្ទូលថា ពួកសាសន៍យូដាទាំងអស់នៅក្នុងដែនដីត្រូវយកទៅសម្លាប់ចោល ។ ព្រះនាងអេសធើរបានសម្រេចចិត្តទៅសូមស្ដេចឲ្យទុកជីវិតឲ្យប្រជាជនរបស់ព្រះនាង ។ ប៉ុន្តែព្រះនាងអាចនឹងត្រូវគេសម្លាប់ដោយសារការទៅបល្ល័ង្ករបស់ស្ដេចនោះ ។ ព្រះនាងអេសធើរបានសុំឲ្យពួកសាសន៍យូដាទាំងអស់តមអាហារសម្រាប់ព្រះនាង ។ ពេលព្រះនាងអេសធើរបានទៅបល្ល័ង្ករបស់ស្វាមីព្រះនាង នោះស្ដេចបានស្វាគមន៍ព្រះនាង ។ ព្រះនាងបានអញ្ជើញស្ដេច និងមិត្តភក្តិរបស់ទ្រង់សោយអាហារពេលល្ងាច ។ នៅទីនោះ ព្រះនាងបានទូលប្រាប់ពួកទ្រង់ថា ព្រះនាងគឺជាសាសន៍យូដា ។ ស្ដេចពុំអាចផ្លាស់ប្ដូរក្រឹត្យវិន័យបានឡើយ ប៉ុន្តែទ្រង់បានអនុញ្ញាតឲ្យពួកសាសន៍យូដាការពារខ្លួនពួកគេ ។ ដោយមានជំនួយពីព្រះ ព្រះនាងអេសធើរបានសង្គ្រោះប្រជាជនព្រះនាង !




*« ព្រះនាងអេសធើរ » រ៉េបេកា ស៊ី អាយុ ៨ ឆ្នាំ ទីក្រុងអារ៉ាហ្គោ ប្រទេសវេណេហ្ស៊ុអេឡា*

*សូមអានអំពីព្រះនាងអេសធើរនៅក្នុង នាងអេសធើរ ២–៨ ។*

រចនារូបភាពដោយ ឌីលីន ម៉ាស្ស




**ព្រះនាងអេសធើរមានចិត្តក្លាហាន និងជឿលើព្រះ ។**
**ខ្ញុំអាចមានចិត្តក្លាហាន ហើយការពារនូវអ្វីដែលត្រឹមត្រូវ !**

- ☐ សូមទន្ទេញផ្នែកចុងក្រោយគេនៃនាងអេសធើរ ៤:១៤ ។
- ☐ សូមមើលជំពូកទី ៤៥ នៃដំណើររឿងព្រះគម្ពីរសញ្ញាចាស់ នៅគេហទំព័រ scripturestories.lds.org ។
- ☐ ប្រសិនបើឪពុកម្ដាយរបស់អ្នកនិយាយថា អ្នកធំល្មមហើយ នោះសូមតមអាហារសម្រាប់នរណាម្នាក់ដែលអ្នកខ្វល់ខ្វាយអំពីគាត់ ។
- ☐ ខ្ញុំអាចមានចិត្តក្លាហានតាមរយៈ . . .

______________________________

______________________________

# ព្រះនាងអេសធើរ

ដោយ គីម វេប រីដ



នាងអេសធើរគឺជាម្ចាស់ក្សត្រី ។ ព្រះនាងបានរៀបការនឹងស្ដេចនៃស្រុកពើស៊ី ។



ស្ដេចនោះមានមិត្តម្នាក់ជាមនុស្សអាក្រក់ ។ មនុស្សអាក្រក់នោះបានបញ្ឆោតស្ដេចឲ្យបង្កើតក្រឹត្យវិន័យមួយដែលថា ពួកសាសន៍យូដាទាំងអស់ត្រូវយកទៅសម្លាប់ចោល ! ស្ដេចពុំបានដឹងឡើយថា ព្រះនាងអេសធើរដែលជាមហេសីរបស់ទ្រង់គឺជាសាសន៍យូដាទេ ។

រចនារូបភាពដោយ អាបរីល ស្តុត

ព្រះនាងអេសធើរបានសម្រេចចិត្តទៅសូមស្វាមីព្រះនាងដែលជាស្តេចឲ្យទុកជីវិតដល់ប្រជាជនរបស់ព្រះនាង ។ ប៉ុន្តែព្រះនាងបានបារម្ភថា ស្តេចនឹងខ្វាល់ ។ ព្រះនាងអេសធើរបានសុំឲ្យពួកសាសន៍យូដាទាំងអស់តមអាហារ និងអធិស្ឋានឲ្យព្រះនាង ។ បន្ទាប់មក ព្រះនាងអេសធើរបានចូលទៅគាល់ស្តេច ។ ស្តេចពុំបានខ្វាល់ទេ !





ព្រះនាងអេសធើរបានអញ្ជើញស្តេច និងមិត្តភក្តិរបស់ទ្រង់សោយអាហារពេលល្ងាច ។ នៅឯអាហារពេលល្ងាចនោះ ព្រះនាងអេសធើរបានប្រាប់ស្តេចថា *ព្រះនាង* គឺជាសាសន៍យូដា ។ ស្តេចបានខ្វាល់ដែលមិត្តរបស់ទ្រង់បានបញ្ឆោតទ្រង់ ។ ទ្រង់បានប្រាប់ពួកសាសន៍យូដាថា ពួកគេអាចការពារខ្លួនបាន ។ ព្រះនាងអេសធើរបានសង្គ្រោះជីវិតប្រជាជនរបស់ព្រះនាង !



យើងអាចទូលសូមជំនួយពីព្រះវរបិតាសួគ៌ ។
យើងអាចក្លាហាន និងមានចិត្តក្លាហានដូចព្រះនាងអេសធើរដែរ ។ ■

*ដកស្រង់ពី នាងអេសធើរ ២–៨ ។*

# ខ្ញុំអាចជួយអ្នកដទៃឲ្យទទួលអារម្មណ៍ថា ពួកគេត្រូវបានគេស្រឡាញ់



រូបភាពដោយ អាប៊ីល ស្ទុត



ដោយប្រធាន
ជេមស៍ អ៊ី ហ្វោស្ត
( ឆ្នាំ ១៩២០–២០០៧ )
ទីប្រឹក្សាទីពីរនៅក្នុង
គណៈប្រធានទីមួយ

# ការទ្រទ្រង់គាំទ្ររបស់យើង

*សេចក្ដីណែនាំខាងវិញ្ញាណក្នុងទំហំដ៏ធំមួយអាស្រ័យទៅលើភាពត្រូវគ្នាជាមួយនឹង . . . ពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។*



ខ្ញុំមានបំណងនិយាយអំពីតំណែងដ៏ពិសិដ្ឋនៃថ្នាក់ដឹកនាំបព្វជិតភាពទាំងនោះដែលត្រូវបាន « ហៅ ហើយរើស » ( គ. និង ស. ៥៥:១ ) ដើម្បីដឹកនាំសាសនាចក្រនៅជំនាន់នេះ ។ . . .

. . . បងប្អូនរបស់ខ្ញុំ [ នៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ] ដោយគ្មានការដោះសាអ្វីឡើយ គឺជាបុរសល្អ គួរឲ្យគោរព និងគួរឲ្យទុកចិត្ត ។ ខ្ញុំស្គាល់ចិត្តរបស់ពួកលោក ។ ពួកលោកគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ ។ បំណងប្រាថ្នាតែមួយគត់របស់ពួកលោកគឺធ្វើការក្នុងការហៅបម្រើដ៏អស្ចារ្យរបស់ពួកលោក និងស្ថាបនានគរព្រះនៅលើផែនដី ។ បងប្អូនប្រុសរបស់យើងដែលកំពុងបម្រើនៅជំនាន់នេះ និងពេលនេះគឺជាភស្ដុតាង ត្រូវបានសាកល្បង និងពិតស្មោះត្រង់ ។ . . . ដួងចិត្តរបស់ពួកលោកបរិសុទ្ធ បទពិសោធន៍របស់ពួកលោកគឺអស្ចារ្យ គំនិតពួកលោកក៏មោះមុត ហើយប្រាជ្ញាខាងវិញ្ញាណរបស់ពួកលោកក៏ជ្រៅជ្រះ ដែលវាគឺជាការលួងលោមមួយដែលនៅក្នុងវត្តមានរបស់ពួកលោក ។

. . . [ ពេលខ្ញុំត្រូវបានហៅ ខ្ញុំត្រូវបានទូន្មាន ] ថា រឿងដ៏សំខាន់បំផុតដែលខ្ញុំត្រូវធ្វើនោះគឺ ត្រូវនៅឲ្យចុះសម្រុងជាមួយពួកបងប្អូនប្រុសរបស់ខ្ញុំ ។ . . . នោះជាអ្វីដែលខ្ញុំចង់ធ្វើដោយអស់ពីដួងចិត្តរបស់ខ្ញុំ ។

. . . ខ្ញុំអាចនិយាយបានថា សេចក្ដីណែនាំខាងវិញ្ញាណក្នុងទំហំដ៏ធំមួយអាស្រ័យទៅលើភាពត្រូវគ្នាជាមួយនឹងប្រធានសាសនាចក្រ គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ — ជាអស់អ្នកដែលត្រូវបានគាំទ្រថា . . . ជាពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ ខ្ញុំពុំដឹងអំពីរបៀបដែលយើងអាចសង្ឃឹមថា បានចុះសម្រុងពេញលេញជាមួយនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់ឡើយ ប្រសិនបើយើងពុំចុះសម្រុងជាមួយនឹងប្រធានសាសនាចក្រ និងពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈផ្សេងទៀតនោះ ។ . . .

ការទូន្មានរបស់ខ្ញុំចំពោះសមាជិកសាសនាចក្រគឺឲ្យគាំទ្រដល់ប្រធានសាសនាចក្រ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងពួកអ្នកមានសិទ្ធិអំណាចទូទៅដទៃទៀតជាមួយនឹងដួងចិត្ត និងព្រលឹងរបស់ពួកគេទាំងមូល ។ ប្រសិនបើយើងធ្វើដូច្នេះ នោះយើងនឹងនៅក្នុងកំពង់ផែដ៏សុវត្ថិភាពមួយ ។

យើងក៏ចាំបាច់ត្រូវគាំទ្រ ហើយជួយដល់ថ្នាក់ដឹកនាំ ក្នុងមូលដ្ឋានរបស់យើង ដោយសារពួកគាត់ « ត្រូវបានហៅ និងជ្រើសរើស » ។ សមាជិកគ្រប់រូបនៃសាសនាចក្រនេះ អាចទទួលបានការប្រឹក្សាមកពីប៊ីស្សព ឬប្រធានសាខា ប្រធានស្តេក ឬប្រធានបេសកកម្ម និងប្រធានសាសនាចក្រ ព្រមទាំងសហការីរបស់លោក ។ បងប្អូនប្រុសទាំងនេះ ពុំមាននរណាម្នាក់សុំការហៅរបស់គាត់នេះទេ ។ គ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ ។ ប៉ុន្តែពួកលោកគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ បានហៅដោយទ្រង់តាមរយៈអ្នកទាំងឡាយដែលមានសិទ្ធិទទួលការបំផុសគំនិត ។ អ្នកទាំងឡាយដែលត្រូវបានហៅ គាំទ្រ និងញែកចេញគឺមានសិទ្ធិទទួលបានការទ្រទ្រង់គាំទ្ររបស់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០០៥ ។*

រចនារូបភាពមកពី GETTY IMAGES



*បុរសខ្វាក់ភ្នែកនៅឯស្រះស៊ីឡោម*
**ដោយ អ៊ីដមុន ប្លែរ លេតុន**

« *គាត់ឆ្លើយថា មានម្នាក់ឈ្មោះ យេស៊ូវ បានធ្វើភក់មកលាបភ្នែកខ្ញុំ រួចប្រាប់ឲ្យទៅលាងនៅស្រះស៊ីឡោម ខ្ញុំក៏ទៅលាង ហើយបានភ្លឺឡើង ។ . . . បើលោកនោះមិនមកពីព្រះទេ នោះលោកពុំអាចនឹងធ្វើអ្វីបានឡើយ* » ( *យ៉ូហាន ៩:១១, ៣៣* ) ។

អ៊ីដមុន ប្លែរ លេតុន ( ១៨៥២–១៩២២ ) *បុរសខ្វាក់ភ្នែកនៅឯស្រះស៊ីឡោម* ឆ្នាំ ១៨៧៩ គំនូរលាបប្រេង ទំហំ ៤០ x ៥០ ១/៤ អ៊ីញ ។ សារៈមន្ទីរសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ បានទិញដោយមូលនិធិដែលបានផ្ដល់ឲ្យដោយ ចាក អ៊ែរ វ៉ៃលែ ឆ្នាំ ២០១៩ ។

យុវមជ្ឈិមវ័យ

**ពិនិត្យមើល « មូលហេតុ » របស់អ្នក**

*តើអ្វីជាការជំរុញចិត្តរបស់អ្នក*
*ដើម្បីរស់នៅតាមដំណឹងល្អ ?*

៤៤





យុវវ័យ

របៀបដែលព្រះវិញ្ញាណបរិសុទ្ធ
អាចបង្រៀនអ្នក

៥០, ៥៦

ធ្វើការបច្ចុប្បន្ននេះសម្រាប់
អនាគតដែលអ្នកចង់បាន

៦២

សន្និសីទទូទៅ

របៀប ៥ យ៉ាងដើម្បីរៀនមក
ពីសន្និសីទ

៥០, ៥៤,
៥៨



CAMBODIAN

4 02147 54258 8


សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ